## ទិន្នន័យសំខាន់ៗប្រចាំឆ្នាំ២០០៨

| | |
|---|---|
| រដ្ឋសមាជិកចាប់ពី | ថ្ងៃទី ១ ខែមករា ឆ្នាំ ២០០០ |
| ប្រភេទគ្រាប់ផ្ទុះ | មីនប្រឆាំងមនុស្ស និងយានជំនិះ កូនគ្រាប់បែកតូចៗ និង សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម |
| ចំនួនផ្ទៃដីប៉ាន់ស្មានថាមានគ្រាប់មីន | ៦៤៩ គ.ម$^{២}$ នៃតំបន់មីនដែលគេរំពឹងថាត្រូវ ដោះមីនឱ្យអស់ ( ខែសីហា ឆ្នាំ ២០០៩) |
| ចំនួនជនរងគ្រោះឆ្នាំ ២០០៨ | ២៦៩នាក់ ( ឆ្នាំ២០០៧: ៣៥២នាក់) |
| ចំនួនអ្នកនៅរស់ក្រោយគ្រោះថ្នាក់មីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម(ERW) បានប៉ាន់ស្មាន | ៤៣ ៩២៦ នាក់ |
| មាត្រាទី ៥ ( ការបោសសំអាតតំបន់មានមីន) | ពេលផុតកំណត់ចុងក្រោយៈ ថ្ងៃទី ១ ខែមករា ឆ្នាំ ២០១០ |
| ផ្ទៃដីដោះមីននៅឆ្នាំ ២០០៨ | ៦៣.២៦ គ.ម$^{២}$ ( ឆ្នាំ២០០៧: ៥៥.៣១ គ.ម$^{២}$ ) |
| ចំនួនមនុស្សដែលទទួលបានការអប់រំពីគ្រោះថ្នាក់ដោយសារមីនក្នុងឆ្នាំ ២០០៨ | ៣៨០,៣០០ នាក់ |
| ដំណើរការនៃការជួយជនរងគ្រោះ បើប្រៀបធៀបនឹងទិសដៅ | នៅយឺតយ៉ាវ |
| ការគាំទ្រដល់សកម្មភាពដោះមីនក្នុងឆ្នាំ ២០០៨ | ថវិកាជំនួយអន្តរជាតិចំនួនៈ២៨ លានដុល្លា( ឆ្នាំ២០០៧: ៣០,៨ លានដុល្លា)<br>ថវិកាជាតិៈ១,៨ លានដុល្លា ( ឆ្នាំ២០០៧: ១,១៥ លានដុល្លា) |

## របាយការណ៍សកម្មភាពរយៈពេល១០ឆ្នាំ

ព្រះរាជាណាចក្រកម្ពុជា ក្លាយជារដ្ឋសមាជិកនៃសន្ធិសញ្ញាប្រឆាំងគ្រាប់មីននៅថ្ងៃទី១ខែមករាឆ្នាំ២០០០។ ឆ្នាំ១៩៩៩ ប្រទេសកម្ពុជាបានអនុម័តច្បាប់ជាតិស្តីពីការហាមឃាត់ការប្រើគ្រាប់មីន និងបានប្រកាសបំផ្លាញគ្រាប់មីនប្រឆាំងមនុស្សចំនួនឱ្យអស់៧១៩៩១គ្រាប់។ ប៉ុន្តែកម្ពុជានៅតែបន្តរកឃើញ និងបំផ្លាញគ្រាប់មីនរាប់ពាន់ បន្ថែមទៀតជារៀងរាល់ឆ្នាំដោយមានចំនួនជាង ១៣៣០០០គ្រាប់ រវាងឆ្នាំ ២០០០ដល់២០០៨។ ប្រទេសថៃ បានធ្វើការចោទប្រកាន់យ៉ាងធ្ងន់ធ្ងរដល់កម្ពុជាថា បានដាក់មីនថ្មីប្រឆាំងមនុស្សនៅតាមព្រំដែននៃប្រទេសកម្ពុជាក្នុងខែតុលា ឆ្នាំ២០០៨។ ប្រទេសកម្ពុជា បានធ្វើជាសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីបច្ចេកវិទ្យាសំរាប់កំចាត់មីនពី ឆ្នាំ១៩៩៩ ដល់ ឆ្នាំ២០០០ និង បានធ្វើជាសហអ្នករាយការណ៍ - បន្ទាប់មកជាសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីការបោសសំអាតមីន ការអប់រំពីគ្រោះថ្នាក់មីន និងបច្ចេកវិទ្យាសំរាប់កំចាត់មីនពីឆ្នាំ២០០២ ដល់ ឆ្នាំ២០០៤ ក៏ដូចជាសហអ្នកធ្វើរបាយការណ៍ និង ជាសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ ស្តីពីការជួយសង្គ្រោះជនរងគ្រោះ និង សមាហរណកម្មសង្គម-សេដ្ឋកិច្ច ពីឆ្នាំ២០០៦ ដល់ ឆ្នាំ២០០៨។ ប្រទេសកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំថ្នាក់តំបន់ស្តីពីការហាមប្រើប្រាស់គ្រាប់មីននៅឆ្នាំ ២០០៣ និង ឆ្នាំ២០០៧។

ប្រទេសកម្ពុជា នៅតែជាប្រទេសមួយក្នុងចំណោមប្រទេសដែលរងគ្រោះធ្ងន់ធ្ងរបំផុតដោយសារគ្រាប់មីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមនិងគ្រាប់បែកចង្កោមដែលនៅសេសសល់ផងដែរ។ ប៉ុន្តែផ្ទៃដីដោះមីនបានកើនឡើងយ៉ាងខ្លាំងក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ដោយគេបានប្រើប្រាស់វិធីសាស្ត្រនិងឧបករណ៍ថ្មីៗនៅពេលដែលផ្ទៃដីដែលកសិករយកទៅប្រើវិញនិងការលុបតំបន់ដីដែលគេសង្ស័យថាមានគ្រាប់មីនចោលតាមរយៈការអង្កេតស្រាវជ្រាវ ធ្វើឱ្យបរិមាណដីដែលគ្មានគ្រាប់មីនកើនឡើងយ៉ាងច្រើនតាមរយៈកម្មវិធីដោះមីន។ នៅខែមេសា ឆ្នាំ២០០៩ ប្រទេសកម្ពុជាបានដាក់សំណើរសុំពន្យាពេលនៃការដោះមីនរយៈពេល១០ឆ្នាំទៅមុខទៀត ដែលអាណត្តិស ១០មុន នឹងផុតកំណត់ នៅថ្ងៃទី១ ខែមករា ឆ្នាំ២០១០ តាមសន្ធិសញ្ញា។

យ៉ាងហោចណាស់ក៏មានអ្នករងគ្រោះថ្នាក់មីននិង សំណល់ជាតិផ្ទុះសល់ពីសង្គ្រាមចំនួន៧៣០០នាក់ នៅចន្លោះឆ្នាំ១៩៩៩ដល់ឆ្នាំ២០០៨ ក្នុងចំណោមអ្នករងគ្រោះសរុបជាង៦០០០០នាក់ចាប់តាំងពីឆ្នាំ១៩៧៩មក។ ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនជាច្រើនត្រូវបានធ្វើឡើងនៅកម្ពុជាក្នុងរយៈពេលជាង១០ឆ្នាំនេះ ដែលធ្វើដោយមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត និង ក្រសួងអប់រំ យុវជន និងកីឡា។ ក្នុងចន្លោះឆ្នាំនោះគេបានធ្វើការផ្លាស់ប្តូរវិធីពីការលើកកំពស់ការយល់ដឹងទៅជាការកាត់បន្ថយគ្រោះថ្នាក់ដោយការធ្វើសមាហរណកម្មកាន់តែច្រើនទៅក្នុងសកម្មភាពមីន និងភ្ជាប់ជាមួយការអភិវឌ្ឍន៍។ ការវាយតំលៃមួយនៅឆ្នាំ២០០៨ បានទទួលស្គាល់ពីជោគជ័យលើការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីននៅកម្ពុជា ប៉ុន្តែបានបញ្ជាក់ថាវិធីសាស្ត្រដែលមានគោលដៅបន្ថែមទៀត និងមានលក្ខណៈអន្តរវិស័យ រួមជាមួយការបង្កើនការទំនាក់ទំនងត្រូវតែធ្វើដើម្បីផ្លាស់ប្តូរឥរិយាបទ។

ចាប់ពីឆ្នាំ១៩៩៩ដល់ឆ្នាំ២០០៨ អ្នកដែលនៅមានជីវិតរស់ និងជនពិការដោយសារគ្រាប់មីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមមិនមានគ្រប់គ្រាន់សូម្បីតែតម្រូវការចាំបាច់ជាមូលដ្ឋានក៏ដោយ។ ជំនួយឧបត្ថម្ភត្រូវបានផ្តល់ស្ទើរតែទាំងស្រុងដោយអង្គការមិនមែនរដ្ឋាភិបាលដែលកំពុងតែប្រឈមមុខនឹងការនឿយណាយខ្លាំងឡើងពីម្ចាស់ជំនួយ។ ក្នុងន័យបំពេញតាមផែនការសកម្មភាពទីក្រុងណៃរ៉ូប៊ី (The Nairobi Action Plan)ប្រទេសកម្ពុជាបានបង្កើតផែនការជាតិសម្រាប់ជនពិការឆ្នាំ ២០០៩-២០១១ ក្រោយពេលការពិគ្រោះយោបល់រយៈពេលជិត ២ ឆ្នាំ។

## គោលនយោបាយលុបបំបាត់មីន

ព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើសន្ធិសញ្ញាហាមប្រើប្រាស់គ្រាប់មីននៅថ្ងៃ០៣ ខែធ្នូ ឆ្នាំ១៩៩៧ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ១៩៩៩ និងក្លាយជារដ្ឋសមាជិកនៃសន្ធិសញ្ញានេះនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០០០។ ច្បាប់អនុវត្តក្នុងស្រុក មានច្បាប់ហាមប្រាមការប្រើប្រាស់មីនប្រឆាំងមនុស្ស ត្រូវបានដាក់ឱ្យចូលជាធរមាននៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ ១៩៩៩។[1] ប្រទេសកម្ពុជាបានបញ្ជូនរបាយការណ៍មាត្រាទី ៧លើកទី ១០ នាឆ្នាំ ២០០៩ សម្រាប់ឆ្នាំសារពើពន្ធ ២០០៨។[2]

---

[1] The law bans the production, use, possession, transfer, trade, sale, import, and export of antipersonnel mines. It provides for criminal penalties, including fines and imprisonment for offenses committed by civilians or members of the police and the armed forces. It also provides for the destruction of mine stockpiles.

[2] The report is undated, but was submitted to the UN in April 2009. The report submitted in 2008 was also undated, covering calendar year 2007. Previous reports were submitted on 27 April 2007, 11 May 2006, 22 April 2005, 30 April 2004, 15 April 2003, 19 April 2002, 30 June 2001, and 26 June 2000.

កម្ពុជាបានចូលរួមក្នុងកិច្ចប្រជុំរដ្ឋសមាជិកលើកទី៩ ដែលគេប្រារព្ធធ្វើនៅទីក្រុងហ្សឺណែវ នាខែវិច្ឆិកា ឆ្នាំ២០០៨ ក្រោយពេលបញ្ចប់អាណត្តិរយៈពេល១ឆ្នាំ ជាសហប្រធានក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីការជួយសង្គ្រោះជនរងគ្រោះ និងសមាហរណកម្មសង្គម-សេដ្ឋកិច្ច។ ប្រទេសកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍ក្នុងកម្មវិធី ផ្លាស់ប្តូរទស្សនៈទូទៅ និងលើការប្រតិបត្តិតាមបទបញ្ញត្តិដោយធ្វើការបកស្រាយច្រើនលើការចោទប្រកាន់របស់ថៃលើការដាក់គ្រាប់មីនថ្មី (សូមអានផ្នែកខាងក្រោម)។ កម្ពុជាក៏បាននិយាយអំពីការជួយសង្គ្រោះជនរងគ្រោះ និងពេលកំណត់ចុងក្រោយនៃការបញ្ចប់ការបោសសំអាតមីននៅឆ្នាំ២០១០ និងការពន្យារពេលដោះមីនរបស់ចក្រភពអង់គ្លេស។

ប្រទេសកម្ពុជាចូលរួមក្នុងសិក្ខាសាលាស្តីពី **ការសម្រេចអោយបាននូវតំបន់អាស៊ីអាគ្នេយ៍គ្មានគ្រាប់មីន** នាទីក្រុងបាងកក នៅថ្ងៃទី១-៣ ខែមេសា ឆ្នាំ២០០៩។ នេះជាកិច្ចប្រជុំទីពីរក្នុងចំណោមកិច្ចប្រជុំក្នុងតំបន់ដើម្បីឈានទៅរកសន្និសីទបូកសរុបការងារមីនឡើងវិញលើកទី២។ ក្នុងពេលចូលរួមអន្តរប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៅខែឧសភាឆ្នាំ២០០៩ ប្រទេសកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍ស្តីពីជំនួយជួយដល់អ្នករស់រានជីវិតពីគ្រាប់មីន និងស្នើសុំពន្យាពេលដោះមីនឱ្យអស់តាមមាត្រាទី៥។ (សូមអានផ្នែកខាងក្រោម)

ប្រទេសកម្ពុជាមិនបានលើកឡើងក្នុងកិច្ចពិភាក្សាវែកញែកទូលំទូលាយដូចដែលភាគីរដ្ឋទាំងមូលបានចូលរួមធ្វើស្តីអំពីការបកស្រាយ និងការអនុវត្តន៍ដែលទាក់ទងទៅនឹងមាត្រាទី១ ទី២ និង ទី៣ ( ប្រតិបត្តិការយោធារួមជាមួយក្រុមឧទ្ទាម មីនប្រឆាំងរថក្រោះ ដែលងាយនឹងផ្ទុះឬមិនអាចប៉ះពាល់បាន និងមីនដែលអនុញ្ញាតឱ្យទុកសំរាប់ធ្វើការបណ្តុះបណ្តាលនោះឡើយ)។

ប្រទេសកម្ពុជា ជាភាគីនៃអនុសញ្ញាហាមប្រើប្រាស់អាវុធ (Convention on Conventional Weapons: CCW) និងការកែប្រែពង្រាងអនុស្សារណៈទី២ស្តីពីគ្រាប់មីន។ កម្ពុជាមិនបានធ្វើរបាយការណ៍តាមការស្នើរក្នុងមាត្រាទី១៣ របស់អនុស្សារណៈឡើយចាប់តាំងពីខែមេសាឆ្នាំ២០០៨។ កម្ពុជាមិនជាភាគីនៃអនុស្សារណៈទី៥ របស់អនុសញ្ញាស្តីពីការប្រើប្រាស់អាវុធទាក់ទងនឹងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមឡើយ។ រហូតដល់ថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩ នេះ ប្រទេសកម្ពុជាមិនបានចុះហត្ថលេខាលើអនុសញ្ញាស្តីពីគ្រាប់បែកចង្កោមឡើយ។[3]

### ***ការផលិត ការដឹកជញ្ជូន ការបំផ្លាញឃ្លាំងស្តុក និងការរក្សាមីន***

រដ្ឋាភិបាលកម្ពុជា បានរាយការណ៍ថាខ្លួនមិនមានឧបករណ៍សម្រាប់ការផលិតមីនប្រឆាំងមនុស្ស ហើយខ្លួនមិនបាននាំមីនប្រឆាំងមនុស្សចេញទៅក្រៅឡើយ។[4]

កងយោធពលខេមរភូមិន្ទបានកំទេចចោលនូវមីនប្រឆាំងមនុស្សដែលរក្សាទុកក្នុងឃ្លាំងចំនួន ៧១៩៩១គ្រាប់ ពីឆ្នាំ១៩៩៤ និង១៩៩៨ ហើយនាខែកុម្ភៈឆ្នាំ១៩៩៩ អគ្គបញ្ជាការរងកងយោធពលខេមរភូមិន្ទកម្ពុជាបានអះអាងជាផ្លូវការថាកងយោធពលខេមរភូមិន្ទ គ្មានឃ្លាំងស្តុកទុកមីនប្រឆាំងមនុស្សទៀតទេ។[5] នាឆ្នាំ២០០០ប្រទេសកម្ពុជាបានអោយដឹងពីឃ្លាំងស្តុកមីនប្រឆាំងមនុស្ស

---

[3] For details on cluster munitions policy and practice see Human Rights Watch and Landmine Action, *Banning Cluster Munitions: Government Policy and Practice*, Mines Action Canada, May 2009, pp. 193–195.
[4] Article 7 Report (for calendar year 2008), Forms D and E. In the 1970s Cambodia manufactured one type of antipersonnel mine, the KN-10 Claymore-type mine, and various armed groups made improvised mines in the past.
[5] See *Landmine Monitor Report 1999*, p. 391, for annual destruction totals.

១កន្លែង ដែលមានមីនប្រឆាំងមនុស្សចំនួន ២០៣៥គ្រាប់ គ្រប់គ្រងដោយប៉ូលីសជាតិ ។[6] ក្រោយមកទៀត គេបានប្រកាសថាគ្មានឃ្លាំងស្តុកមីនប្រឆាំងមនុស្សទៀតទេចាប់ពីឆ្នាំ ២០០១មក ។[7]

តែទោះជាដូចនេះក្តី ក៏អង្គភាពប៉ូលីសនិងកងយោធពលខេមរភូមិន្ទបន្តរកឃើញគ្រាប់មីនប្រឆាំងមនុស្សនិងអាវុធជាតិផ្ទុះដទៃៗទៀតជាច្រើននៅតំបន់ផ្សេងៗ និងប្រភពដទៃទៀតក្នុងទូទាំងប្រទេស ។ មានកន្លែងលាក់អាវុធជាច្រើនដែលបន្សល់ទុកដោយសង្គ្រាមអស់រយៈកាលប៉ុន្មានទសវត្សរ៍នេះ ។[8] ការដោះមីនដោយអ្នកភូមិ "ដោះមីនក្រៅផ្លូវការ" និង អ្នករកស៊ីលក់ដែកអេតចាយចាស់ៗ ក៏ចំណែកទទួលខុសត្រូវចំពោះការរក្សាទុកគ្រាប់មីនជាច្រើនដែលទើបរកឃើញផងដែរ ។

គ្រាប់មីនទាំងនោះ គួរតែត្រូវរាយការណ៍ទៅអាជ្ញាធរសកម្មភាពមីននិងសង្គ្រោះជនពិការដោយសាមីនកម្ពុជាៈ អាជ្ញាធរមីនកម្ពុជា (Cambodian Mine Action and Victim Assistance Authority:CMAA) និងប្រគល់ទៅឱ្យមជ្ឈមណ្ឌលកំចាត់មីនកម្ពុជាៈអង្គការស៊ីម៉ាក់(Cambodian Mine Action Centre:CMAC)ដើម្បីធ្វើការកំទេចចោល ។[9] នៅខែកុម្ភៈឆ្នាំ២០០៨ កម្ពុជាបានអះអាងថាខ្លួនបានបំផ្លាញជាបន្ទាន់នូវមីនដែលទើបនឹងរកឃើញថ្មីៗ ។[10]

កម្ពុជាបានប្រកាសថាគ្រាប់មីនបំផ្លាញមនុស្សសរុបចំនួន១៣៣៤៧៨គ្រាប់ ត្រូវបានគេរកឃើញនិងបំផ្លាញចោលក្នុងរវាងឆ្នាំ ២០០០ ដល់ ឆ្នាំ២០០៨ ដោយរួមទាំងគ្រាប់ចំនួន១៣៦៦៥គ្រាប់នៅឆ្នាំ ២០០៨ ដែរ (៩៦៩៨គ្រាប់ ដោយអង្គការស៊ីម៉ាក់, ២៧១៣គ្រាប់ ដោយអង្គការ HALO Trust និង ១២៥៤ គ្រាប់ ដោយអង្គការ Mines Advisory Group:MAG) ។[11] កម្ពុជាបានអះអាងថាគ្រាប់ទាំងនេះត្រូវបានរាយការណ៍ដោយសហគមន៏ក្នុងតំបន់ ។[12]

## *គ្រាប់មីនដែលគេរក្សាទុកសំរាប់ការស្រាវជ្រាវ និង ការហ្វឹកហ្វឺន*

ដូចឆ្នាំមុនៗដែរ ក្នុងរបាយការណ៍លើមាត្រាទី៧ សម្រាប់សកម្មភាពឆ្នាំ២០០៨របស់ខ្លួន ប្រទេសកម្ពុជាបានបង្ហាញថា ខ្លួនគ្មានគ្រាប់មីនប្រឆាំងមនុស្សដែលរក្សាទុកក្នុងគោលបំណងបណ្តុះបណ្តាលនិងការអភិវឌ្ឍឡើយ ។[13] តែទោះជាយ៉ាងនេះក្តី ប្រទេសកម្ពុជាក៏បានរាយការណ៍ពីការផ្ទេរគ្រាប់មីនសម្រាប់ការហ្វឹកហ្វឺន និងកិច្ចការអភិវឌ្ឍន៏ទៅកាន់មជ្ឈមណ្ឌលបណ្តុះបណ្តាលជារៀងរាល់ឆ្នាំ ។[14] គេបានរាយការណ៏ថានៅឆ្នាំ២០០៨ ប្រទេសកម្ពុជាបានផ្ទេរគ្រាប់មីនប្រឆាំងមនុស្សចំនួន៥១៩គ្រាប់ ក្នុងគោលបំណងហ្វឹកហ្វឺនដោយបានមកពីប្រភពផ្សេងៗ និងអង្គភាពដោះមីនរបស់អង្គការស៊ីម៉ាក់ ដែលរកឃើញនៅក្នុងតំបន់មានមីន ។[15]

---

[6] Article 7 Report, Form B, 26 June 2000.
[7] Article 7 Report (for calendar year 2008), Form F. This has been repeated since 2004.
[8] Ibid.
[9] Ibid.
[10] See *Landmine Monitor Report 2008*, p. 206.
[11] Article 7 Report (for calendar year 2008), Form G. Mines destroyed in previous years included: 8,739 in 2000; 7,357 in 2001; 13,509 in 2002; 9,207 in 2003; 15,446 in 2004; 16,878 in 2005; 23,409 in 2006; and 20,268 in 2007.
[12] Article 7 Report (for calendar year 2008), Form G.
[13] Ibid, Form D1a.
[14] Cambodia reported in 2007 that 594 mines were transferred for development and training. See Article 7 Report (for calendar year 2007), Form D2. Cambodia has reported a total of 3,450 mines transferred for training purposes from 1998–2007.
[15] Article 7 Report (for calendar year 2008), Form D2.

នេះជាលើកទីមួយហើយដែលប្រទេសកម្ពុជាបានធ្វើការបញ្ជាក់យ៉ាងច្បាស់ថា គ្រាប់មីនដែលប្រើសម្រាប់ការហ្វឹកហ្វឺនទាំងនេះត្រូវបានដោះពីក្នុងដីដោយអ្នកដោះមីន ហើយមិនមែនជារបស់ដែលរកឃើញថ្មីឡើយ ។

កម្ពុជាមិនទាន់បានធ្វើការរាយការណ៍ជាក់លាក់លំអិតណាស្តីពីបំណងពិតប្រាកដ និងការប្រើប្រាស់គ្រាប់មីនសម្រាប់ការហ្វឹកហ្វឺនឡើយ - ដែលនេះជាជំហានព្រមព្រាងដោយរដ្ឋភាគីក្នុងសន្និសីទបូកសរុបការងារឡើងវិញលើកទី១ នៅឆ្នាំ២០០៤។ កម្ពុជាមិនបានប្រើប្រាស់ទម្រង់ D សម្រាប់ការរាយការណ៍ពីគ្រាប់មីនរក្សាទុក ដែលរដ្ឋភាគីព្រមព្រៀងនៅឆ្នាំ២០០៥ ឡើយ ។

***ការប្រើប្រាស់គ្រាប់មីន***

ចាប់ពីពេលដែលកម្ពុជាចុះហត្ថលេខាលើសន្ធិសញ្ញាហាមប្រាមការប្រើគ្រាប់មីននៅឆ្នាំ១៩៩៧ រហូតមកដល់ឆ្នាំ២០០៨ កម្ពុជាពុំដែលរងការចោទប្រកាន់ជាក់លាក់ណាមួយលើការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ដោយកងកម្លាំងរដ្ឋាភិបាលឡើយ ។

នៅថ្ងៃទី៦ ខែតុលា ឆ្នាំ២០០៨ កងកម្លាំងល្បាតព្រៃប៉ារ៉ាថៃម្នាក់បានដើរជាន់គ្រាប់មីនប្រឆាំងមនុស្សនៅពេលដើរល្បាតព្រៃក្នុងតំបន់ជម្លោះរវាងថៃ និងកម្ពុជា ក្បែរតំបន់បេតិកភណ្ឌពិភពលោកប្រាសាទព្រះវិហារ ។ ទាហានទីពីរបានជាន់មីនពេលព្យាយាមចូលទៅជួយអ្នករបួសទី១ ។ អ្នកទាំងពីរបានបាត់បង់ជើងរបស់ខ្លួន ។ ហេតុការណ៍នេះកើតឡើង៣ថ្ងៃក្រោយពេលមានការបាញ់បោះដាក់គ្នារវាងទ័ពថៃ និងកម្ពុជានៅទីតាំងដដែល ។

ភាគីថៃអះអាងថាតំបន់នោះនៅពេលមុនមិនមានមីនឡើយ ។ មជ្ឈមណ្ឌលសកម្មភាពមីនថៃ (TMAC) បានបញ្ជូនមនុស្សមួយក្រុមទៅស៊ើបអង្កេត ហើយបានរកឃើញថានោះជាគ្រាប់មីនប្រឆាំងមនុស្សប្រភេទ PMN2 ។ TMAC បានបញ្ជាក់ថាគ្រាប់មីននោះត្រូវបានដាក់កប់ថ្មីៗ ។ ការរកឃើញថ្មីថែមទៀតត្រូវបានគេចុះផ្សាយនៅលើគេហទំព័ររបស់ក្រសួងការបរទេសថៃ ។[16]

អជ្ញាធរកម្ពុជាបានអះអាងថាការស៊ើបអង្កេតរបស់ថៃលើហេតុការណ៍នេះជាការឈ្លានពានជាឯកតោភាគី គឺនៅលើទឹកដីកម្ពុជាដោយមិនមានការយល់ព្រមឬការចូលរួមរបស់កម្ពុជា ហើយបានថ្កោលទោសលើសកម្មភាពនេះ ។ ក្រសួងការបរទេសកម្ពុជាបានអះអាងថាក្រុមល្បាតព្រៃថៃបានឈ្លានពានចូលទឹកដីកម្ពុជាក្នុងតំបន់ដែលដឹងថាមានគ្រាប់មីនប្រឆាំងមនុស្ស និងរងគ្រោះដោយគ្រាប់មីនដែលបង្កប់ក្នុងពេលជម្លោះប្រដាប់អាវុធពីពេលមុន ។[17]

អ្នកសម្របសម្រួលរបស់អង្គការយុទ្ធនាការលុបបំបាត់គ្រាប់មីនរបស់ថៃ ( TCBL ) បានចុះទៅមើលដល់កន្លែងកើតហេតុតាមការអញ្ជើញរបស់ TMAC និងក្រសួងការបរទេសថៃ ។ នាងបានកត់សំគាល់ថា " គ្រាប់មីនដែលរកឃើញនៅកន្លែងកើតហេតុពុំមានស្លាកស្នាមច្រេះឡើយ ។ លេខសំគាល់នៅលើគ្រាប់មីនត្រូវបានគេមើលឃើញច្បាស់ ហើយមិនមានលក្ខណៈថាត្រូវបានទុកចោលនៅខាងក្រៅយូរឡើយ ។ អ្នកភូមិបានប្រាប់ខ្ញុំថាពួកគាត់ដើរកាត់តាមផ្លូវដែលកើតហេតុនោះជាប្រចាំ ។"[18]

---

[16] Thailand Ministry of Foreign Affairs, "Diplomatic Corps briefed on Thailand-Cambodia Border Incidents," Press release, 4 February 2009, www.mfa.go.th.

[17] Cambodian Ministry of Foreign Affairs and International Cooperation, "Statement of the Spokesman of the Ministry of Foreign Affairs and International Cooperation," Press release, 17 October 2008, www.mfaic.gov.kh and Cambodian Ministry of Foreign Affairs and International Cooperation, "MFA.IC Note," 23 October 2008, www.mfaic.gov.kh.

[18] Interview with Emilie Ketudat, Coordinator, TCBL, Bangkok, 18 October 2008.

ប្រទេសថៃបានអះអាងថាកងយោធពលខេមរភូមិន្ទថៃមិនដែលមានគ្រាប់មីនប្រភេទ PMN2ឡើយ។[19] របាយការណ៍តម្លាភាពប្រចាំឆ្នាំរបស់កម្ពុជាបញ្ជាក់ថាគ្រាប់មីនប្រភេទ PMN2 ត្រូវបានគេរកឃើញជាសាមញ្ញទៅ ហើយក្នុងពេលប្រតិបត្តិការដោះមីន។[20] របាយការណ៍នេះក៏និយាយផងដែរអំពីគំនរគ្រាប់មីនប្រភេទPMN2 ក្នុងពេលអតីតកាល។[21]

នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៨ មន្ត្រីតំណាងរបស់ក្រសួងការបរទេស ក្រសួងការពារជាតិ និង TMAC របស់ថៃបានជួបប្រជុំជាមួយក្រុមបេសកកម្មហាមប្រើប្រាស់គ្រាប់មីនអន្តរជាតិ-ថៃ (ICBL/TCBL) និងបានបង្ហាញនូវព័តិមានដែលថៃបានស៊ើបអង្កេតលើហេតុការណ៍នោះ។ ក្រោយមកថៃបានបង្ហាញព័តិមាននេះក្នុងកិច្ចប្រជុំលើកទី៩ នៃរដ្ឋសមាជិកនៅទីក្រុងហ្សឺណែវ កាលពីខែវិច្ឆិកា។[22]

កម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍ជាច្រើនដងទៅលើហេតុការណ៍នោះក្នុងកិច្ចប្រជុំលើកទី៩របស់រដ្ឋសមាជិក។ កម្ពុជាបានអះអាងថា "យើងមានការសោកស្តាយជាខ្លាំងដែលទទួលរងការចោទប្រកាន់ថាប្រទេសកម្ពុជាបានបំពានលើកាតព្វកិច្ចរបស់ខ្លួនចែងក្នុងអនុសញ្ញាទីក្រុងអុតាវ៉ាដោយការដាក់គ្រាប់មីនថ្មីតាមព្រំដែនកម្ពុជា-ថៃ។ សម្រាប់ជាប្រទេសមួយដែលរងការបាត់បង់យ៉ាងធ្ងន់ធ្ងរពីគ្រាប់មីន ការដែលចោទថាយើងបានរំលោភលើកាតព្វកិច្ចជាមូលដ្ឋាន ចែងក្នុងអនុសញ្ញានោះ វាជារឿងដែលគួរឱ្យភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ក្នុងភាសាដែលនិយាយអោយងាយស្តាប់នោះ គឺថាយើងសូមបដិសេធចំពោះការលើកឡើងនោះ។ កម្ពុជាបានសរសេរលិខិតផ្លូវការពីរច្បាប់តាមរយៈអង្គភាពគាំទ្រការ អនុវត្តអនុសញ្ញាលុបបំបាត់មីនប្រឆាំងមនុស្សដើម្បីធ្វើការស្រាយបំភ្លឺ ហើយចំណែកឯក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជាបានផ្ញើរលិខិតឆ្លើយឆ្លងជាទ្វេភាគីកាលពីសប្តាហ៍មុន ដោយឆ្លើយតបចំពោះការចោទប្រកាន់នោះ។"[23]

កម្ពុជាក៏បាននិយាយថា "ដោយការចោទប្រកាន់នេះមានភាពធ្ងន់ធ្ងរ និងភាពចាំបាច់សម្រាប់កម្ពុជាក្នុងការអនុវត្តតាមច្បាប់អន្តរជាតិភ្លាមៗនោះ រាជរដ្ឋាភិបាលកម្ពុជាក៏បានបង្កើតគណៈកម្មការស្វែងរកការពិតមួយ ដើម្បីពិនិត្យឡើងវិញលើស្ថានភាពយ៉ាងម៉ត់ចត់រយៈពេល៣ថ្ងៃ ក្រោយពេលទទួលបានសំណើរសុំបំភ្លឺពីប្រទេសថៃ។ គណៈកម្មការនោះនឹងបញ្ចប់ការងាររបស់ខ្លួនក្នុងរយៈពេលដ៏ខ្លីខាងមុខនេះហើយយើងខ្ញុំនឹងចែកជូនការរកឃើញនោះទៅអោយប្រទេសថៃ និងភាគីពាក់ព័ន្ធនិងអ្នកមានចំណាប់អារម្មណ៍។ ជាការបញ្ជាក់ជូនទៅដល់អង្គប្រជុំ ខ្ញុំសូមបញ្ជាក់ថាហេតុការណ៍នោះបានកើតឡើងក្នុងតំបន់ដែលបញ្ជាក់ថានៅមានមីនក្នុងទឹកដីកម្ពុជា។"[24] ក្រោយមកប្រទេសកម្ពុជា មិនបានបញ្ចេញរបាយការណ៍របស់គណៈកម្មការស្វែងរកការពិតនោះ ជាសាធាណៈឡើយ។

---

[19] Thailand Ministry of Foreign Affairs, "Diplomatic Corps briefed on Thailand-Cambodia Border Incidents," 4 February 2009, www.mfa.go.th. Thailand's Article 7 report submitted in April 2008 stated that the Royal Thai Army retained 10 "PMN2" mines. However, its April 2009 report records that the Royal Thai Army retained 10 "PMN" mines; reports from 2004–2006 also cite "PMN."

[20] Article 7 Report (for calendar year 2008), Form F, and earlier reports.

[21] Article 7 Report, Form D, 15 April 2003.

[22] Thailand Ministry of Foreign Affairs, "A Decade of Commitment: Thailand and the Mine Ban Convention," material made available to 9MSP delegates, November 2008.

[23] Statement by Amb. Sam Sotha, Head of Cambodian Delegation, Ninth Meeting of States Parties, Geneva, 24 November 2008.

[24] Ibid.

តាមរយៈភស្តុតាងដែលអាចរកបានថា ហេតុការណ៍គ្រោះថ្នាក់នេះមានជាប់ពាក់ព័ន្ធនឹងការប្រើប្រាស់គ្រាប់មីនថ្មី ប្រឆាំងមនុស្ស ប៉ុន្តែក្រុមត្រួតពិនិត្យមីន មិនមានលទ្ធភាពកំណត់ថានរណាជាអ្នកទទួលខុសត្រូវចំពោះការប្រើប្រាស់នោះទេ។ តាមក្រុមអ្នកត្រួតពិនិត្យមីនទទួលស្គាល់ថា គឺរដ្ឋសមាជិកផ្សេងទៀត មិនបានយកចិត្តទុកដាក់រកដំណោះស្រាយចំពោះបញ្ហារវាងថៃ និងកម្ពុជានេះឡើយ។

នៅថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០០៩ ទាហានថៃម្នាក់ទៀតត្រូវបានគេរាយការណ៍ថារងរបួសដោយសារគ្រាប់មីនប្រឆាំងមនុស្សមួយគ្រាប់នៅកន្លែងដដែលក្នុងពេលមានជម្លោះប្រដាប់អាវុធរវាងប្រទេសទាំងពីរនេះ។[25]

## ទំហំរបស់បញ្ហា

### *ការបំផ្លាញ*

សង្គ្រាមរយៈពេលជិត ៣ ទសវត្សរ៍បានធ្វើអោយកម្ពុជាក្លាយជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដែលរងគ្រោះយ៉ាងធ្ងន់ធ្ងរដោយគ្រាប់មីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម (ERW)។ ក្រោយរយៈពេលជាង ១៥ ឆ្នាំ នៃប្រតិបត្តិការដោះមីនដោយមនុស្សធម៌ ការគម្រាមកំហែងដោយគ្រាប់មីនមានច្រើននៅក្នុងស្រុក២១ក្នុង៦ខេត្តតាមព្រំដែនប៉ែកពាយ័ព្យជាប់ប្រទេសថៃ ក្នុងនោះរួមទាំងតំបន់ក-៥ (K-5) ដែលមានបណ្តោយ១០៤៦គ.ម។ មីនទាំងនោះបានដាក់ដោយរដ្ឋាភិបាលដែលគាំទ្រដោយវៀតណាមក្នុងពាក់កណ្តាលទសវត្សរ៍ឆ្នាំ១៩៨០ ក្នុងគោលបំណងការពារព្រំដែនពីការជ្រៀតចូលរបស់ក្រុមទាហានទ័ពព្រៃដែលប្រឆាំងនឹងរបបនោះហើយមានទីតាំងនៅតាមព្រំដែនថៃ។ វាជាតំបន់ដែលរងការបំផ្លាញយ៉ាងខ្លាំងដែលមានរហូតដល់២៤០០គ្រាប់ ក្នុងរយៈចម្ងាយ ១ គ.ម។[26]

យុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលរួមមានគ្រាប់បែកចង្កោម និងអាវុធជាតិផ្ទុះដែលគេបោះបង់ចោលត្រូវបានគេប្រទះឃើញនៅទូទាំងប្រទេស។ ក្នុងពេលសង្គ្រាមវៀតណាម សហរដ្ឋអាមេរិចបានទម្លាក់គ្រាប់បែកជាងមួយលានតោន (១ កោដគ.ក) នៃកូនគ្រាប់បែកតូចៗយ៉ាងហោចណាស់២៦លានគ្រាប់ មកលើទឹកដីកម្ពុជា ដែលគ្រាប់នោះភាគច្រើនគឺ BLU-24, BLU-26 និង BLU-61។ គ្រាប់បែកនេះត្រូវបានប៉ាន់ស្មានថាមានរវាង ១.៩ លាន និង ៥.៨ លាន ដែលភាគច្រើនស្ថិតនៅតំបន់អាគ្នេយ៍ និងពាយ័ព្យដែលពុំសូវមានមនុស្សរស់នៅតាមបណ្តោយព្រំដែនវៀតណាម។[27] យ៉ាងណាក្តី ការសិក្សាពីសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមនៅកម្ពុជានាឆ្នាំ២០០៦ ត្រូវបានគេរកឃើញថាមានប្រមាណជាង៨០ភាគរយ នៃអាវុធយុទ្ធភណ្ឌដែលកំទេចចោលជាកាំភ្លើងធំ និងគ្រាប់រំសេវ និងតិចជាង ២០ ភាគរយ ជាយុទ្ធភណ្ឌដែលទម្លាក់ពីលើយន្តហោះ។[28]

---

[25] "Cambodia, Thai border clash leaves two dead," *Agence France-Presse* (Phnom Penh), 2 April 2009.

[26] HALO, "Mine clearance in Cambodia–2009," January 2009, p. 8.

[27] South East Asia Air Sortie Database, cited in Dave McCracken, "National Explosive Remnants of War Study, Cambodia," NPA in collaboration with CMAA, Phnom Penh, March 2006, p. 15; Human Rights Watch, "Cluster Munitions in the Asia-Pacific Region," April 2008, www.hb¤ .org; and HI, "Fatal Footprint: The Global Human Impact of Cluster Munitions," November 2006, p. 11.

[28] Interview with Dave McCracken, Consultant, NPA, Phnom Penh, 21 March 2006.

មកដល់ឆ្នាំ២០០៩ ប្រទេសកម្ពុជានៅមិនទាន់ធ្វើការកំណត់ឱ្យបានពេញលេញនូវទំហំនៃការប៉ះពាល់ដោយសារគ្រាប់មីនឡើយ។ ខែមេសា ឆ្នាំ២០០៩ ប្រទេសកម្ពុជាបានធ្វើសំណើរលើកដំបូងសុំពន្យារពេលដោះមីនឱ្យអស់ទៅតាមមាត្រាទី៥ នៃសន្ធិសញ្ញាហាមប្រើប្រាស់មីនប្រឆាំងមនុស្ស ដែលក្នុងសំណើរនោះបានលើកឡើងថាដីប្រមាណ ៦៧២ គ.ម២ នៅតែមានគ្រាប់មីនដែលត្រូវតែដោះមីនទាំងស្រុង រីឯដី ១៨៦៤ គ.ម២ ទៀត ត្រូវការប្រកាសឱ្យដឹងតាមលក្ខណៈបច្ចេកទេស និងមិនមែនបច្ចេកទេសដើម្បីកំណត់ថា មានគ្រាប់មីនទៀតឬអត់ និងផ្ទៃដី ២០០៨ គ.ម២ តាមរយៈការលុបចោលថាលែងមានគ្រាប់មីនពីទិន្នន័យ។[29] យ៉ាងណាក្តី របាយការណ៍នោះក៏បានបង្ហាញដែរថា ទិន្នន័យបច្ចុប្បន្ន " បង្ហាញពីកន្លែងសង្ស័យមានមីនដែលគេដឹងថាតំបន់ដែលមានគ្រោះថ្នាក់ខ្លាំងនិងមានទិន្នន័យមិនត្រឹមត្រូវ"។[30] សំណើរដែលកែប្រែបានដាក់ជូននៅខែ សីហា ឆ្នាំ ២០០៩ បានកំណត់ថាតំបន់ដែលត្រូវដោះមីនមានទំហំ ៦៤៨.៨ គ.ម២ ប៉ុន្តែក្រុមអ្នកពាក់ព័ន្ធមានជំនឿថាការធ្វើអង្កេតមូលដ្ឋានមួយចាប់ផ្តើមនៅខែសីហា ឆ្នាំ២០០៨ នឹងអាចមើលឃើញចំនួនធ្លាក់ចុះនេះ។[31]

យុទ្ធសាស្ត្រជាតិស្តីពីសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ដែលបោះពុម្ពផ្សាយដោយអាជ្ញាធរមីនកម្ពុជា (CMAA) នាខែមករា ឆ្នាំ២០០៨ បាននិយាយថាការប៉ាន់ប្រមាណនៅឆ្នាំ២០០៤ ថាប្រទេសកម្ពុជាមាន " ចំការមីនអាទិភាពដែលត្រូវដោះផ្លូវការនោះ" មានចំនួន ៤២៧គ.ម២ ត្រូវបាន "ទទួលស្គាល់ពិតប្រាកដតាមរយៈទំនោរការងារកន្លងមក បើទោះជាតំបន់នេះមួយចំនួនត្រូវបន្តកំណត់បន្ថែមទៀតតាមរយៈការប្រឹងប្រែងកាត់បន្ថយតំបន់មានគ្រាប់មីនសព្វថ្ងៃ "។[32]

ក្នុងរយៈពេល ៣ ឆ្នាំ ក្រោយនេះ អង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការដោះមីនបានចង្អុលបង្ហាញថាមានដីទំហំជាង ១០០០គ.ម២ នៃដីដែលការស្រាវជ្រាវកម្រិត១ បានបង្ហាញថាជាតំបន់សង្ស័យមានមីនត្រូវប្រជាជនយកទៅប្រើប្រាស់វិញហើយ។ បែបនេះហើយទើបអាជ្ញាធរមីនកម្ពុជា បានដកតំបន់នេះចេញពីក្រុមដីដែលត្រូវដោះមីនក្នុងបញ្ជីទិន្នន័យ។[33] ការប៉ាន់ប្រមាណដែលច្បាស់លាស់ជាងនេះសង្ឃឹមថានឹងទទួលបានពីការអង្កេតមូលដ្ឋានដោយអង្គការមិនមែនរដ្ឋាភិបាលនៅតាមស្រុកចំនួន២១ដែលមានអត្រានៃអ្នកគ្រោះថ្នាក់ដោយគ្រាប់មីនច្រើនជាងគេក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលការងារនេះបានចាប់ផ្តើមនៅខែសីហា ឆ្នាំ ២០០៨ និង ត្រូវបញ្ចប់ក្នុងរយៈពេល១ឆ្នាំ។[34]

### ***អត្រានៃអ្នកគ្រោះថ្នាក់***[35]

នៅឆ្នាំ២០០៨ ប្រព័ន្ធទិន្នន័យជនរងគ្រោះដោយសារមីននិងគ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា (CMVIS) បានកត់ត្រានូវចំនួនអ្នកគ្រោះថ្នាក់ដោយសារមីនថ្មីមានចំនួន ២៦៩នាក់ នៅកម្ពុជា (ស្លាប់៤៧នាក់- របួស២២២នាក់) ក្នុងអត្រាគ្រោះថ្នាក់ដែលកើតឡើងចំនួន១៥៤ករណី។ នេះជាការធ្លាក់ចុះនៃចំនួនអ្នកគ្រោះថ្នាក់ចំនួន២៤ភាគរយ បើប្រៀបធៀបទៅនឹងឆ្នាំ២០០៧

[29] Article 5 deadline Extension Request, 30 April 2009, p. 48.
[30] Ibid, p. 44.
[31] Article 5 deadline Extension Request (Revision), 24 August 2009, p. 41.
[32] CMAA, "National Strategy on Explosive Remnants of War," Phnom Penh, January 2008, p. 4.
[33] Statement of Cambodia, Standing Committee on Mine Clearance, Mine Risk Education and Mine Action Technologies, Geneva, 5 June 2008.
[34] Email from Pascal Rapillard, Policy and External Relations, GICHD, 4 September 2009.
[35] Unless noted othERWise, casualty data 1979–May 2009 provided by Cheng Lo, Data Management Officer, CMVIS, 19 June 2009.

(មាន៣៥២នាក់) និងបញ្ជាក់ពីទំនោរធ្លាក់ចុះនៃអ្នកគ្រោះថ្នាក់ចាប់ផ្តើមនៅឆ្នាំ២០០៦។ ហេតុផលដែលនាំអោយមានការធ្លាក់ចុះជាបន្តបន្ទាប់រួមមានទាំងការចូលរួមរបស់សហគមន៍ក្នុងសកម្មភាពមីន និងការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន។[36]

អ្នករងគ្រោះភាគច្រើនជាជនស៊ីវិល (២៥១ នាក់) ក្នុងនោះបុរស ១៣៦ នាក់ កុមារា ៧៥ នាក់ កុមារី ២២ នាក់ និងស្ត្រី ១៨ នាក់។ អ្នករងគ្រោះ ៧ នាក់ជាបុគ្គលិកដោះមីន (ដែលសុទ្ធតែជាបុរសទាំងអស់) ។ ៦ នាក់ រងគ្រោះក្នុងពេលដោះមីនប្រឆាំងមនុស្ស និង ម្នាក់នៅពេលសម្រាកពីការងារ។ អ្នករងគ្រោះ ៩ នាក់ ជាទាហាន ដោយរួមទាំងទាហានថៃ ៣ នាក់ក្នុងហេតុការណ៍២លើកនៅខេត្តព្រះវិហារ និង២នាក់ជាប៉ូលីស។ សញ្ជាតិរបស់អ្នករងគ្រោះមីនម្នាក់មិនត្រូវគេបានដឹងឡើយ រីឯអ្នកផ្សេងទៀតជាជនជាតិកម្ពុជា។ ជាទូទៅទៅហើយតាំងពីឆ្នាំ២០០១មក[37] គ្រោះថ្នាក់មីនភាគច្រើនបង្កដោយគ្រាប់មីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម (មាន១៨៦នាក់ឬ៥៤%) ដោយរួមទាំង ៧ករណី បង្កដោយគ្រាប់មិនទាន់ផ្ទុះ។ គ្រាប់មីនប្រឆាំងមនុស្សបង្កអោយគ្រោះថ្នាក់ដល់មនុស្សចំនួន៧២ករណី ដោយគ្រាប់មីនប្រឆាំងយានយន្តចំនួន៤៥ករណី ដោយគ្រាប់ផ្ទុះដែលកែច្នៃដោយជនរងគ្រោះខ្លួនឯងមាន ៥ ករណី និង ដោយឧបករណ៍ដែលមិនស្គាល់មាន ១ ករណី។

ជាងពាក់កណ្តាលនៃជនរងគ្រោះដោយសារសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមជាកុមារ : ដែលមានកុមារា ៦៥ នាក់ ( ឬ ៨៦% ជាក្មេងតូច) និង កុមារី ១១នាក់។ ៣ភាគ៤ នៃកុមារដែលជាជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមកើតមាននៅពេលគេចាប់កាន់លេងមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម (មាន៣៨ នាក់ ) ឬ ឈរនៅក្បែរមើលគេលេងគ្រាប់នេះ (១៩នាក់)។ សរុបមក មានជនស៊ីវិលរងគ្រោះចំនួន ៧៦ នាក់ ដោយសារលេងគ្រាប់ (មីននិង សំណល់ជាតិផ្ទុះសល់ពីសង្គ្រាមចំនួន៦៤នាក់ គ្រាប់មីន៧នាក់ និងឧបករណ៍បំផ្ទុះកែច្នៃ៥នាក់) និងមានអ្នករងគ្រោះចំនួន៥០នាក់ រងគ្រោះដោយសារឈរមើលគេលេងគ្រាប់ (គ្រាប់មីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម៣២នាក់ និងគ្រាប់មីន១៨នាក់)។ មានមូលហេតុជាច្រើនដែលនាំឱ្យមានការប៉ះពាល់/លេងគ្រាប់នោះដូចជា: ការលេងប្រលែង/ការចង់ដឹងចង់លឺ ដែលជាទូទៅគឺគេគប់គ្រាប់លេង (៥១ ករណី) ប្រើសម្រាប់ការនេសាទ (១០ ករណី) យកទៅលក់ជាអេតចាយ (៧ ករណី) បោសសំអាតទីដីអោយមានសុវត្ថិភាព (៥ ករណី) និងយកទៅធ្វើជាអាវុធច្នៃ (៣ ករណី)។ ប្រព័ន្ធទិន្នន័យជនរងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា (CMVIS) បង្ហាញថាអ្នករងគ្រោះដោយឧបករណ៍កែច្នៃមាន២ករណី កើតឡើង ដោយសារការប៉ះពាល់ឧបករណ៍នោះនៅពេលនេសាទត្រី និង ៣ ករណីទៀតកើតឡើងដោយសារយកគ្រាប់កែច្នៃនោះទៅធ្វើជាអាវុធ។

សកម្មភាពជាទូទៅបំផុតដែលនាំអោយកើតមានហេតុការណ៍នេះគឺការធ្វើដំណើរ (មាន ៣៣ ករណី) ការកាប់ឆ្ការដីយកទៅប្រើប្រាស់ (២៣ករណី) ឬ រកអុស (១៦ ករណី )។ ករណីគ្រោះថ្នាក់ចំពោះប្រជាជនកើតឡើងនៅក្នុង ឬ នៅក្បែរតំបន់ដែលគេប្រកបរបររកចិញ្ចឹមជីវិត: តំបន់ភូមិស្ថាន/ បង្កើតថ្មី (៧៧ ករណី) តំបន់កសិកម្ម (៦២ ករណី) ចំការដំណាំ (៣៩ ករណី) និងចំការស្មៅ (៣៤ ករណី)។ ករណីរងគ្រោះ ១១ ដងកើតឡើងនៅលើ ឬ ក្បែរតំបន់លេនដ្ឋានយោធា។ គេពុំឃើញមានគ្រោះថ្នាក់ចំពោះជនស៊ីវិលឬយោធាកើតឡើងនៅលើតំបន់ដោះមីនឡើយ។ ពុំមានរបាយការណ៍ពីគ្រោះថ្នាក់កើតឡើងដោយ

---

[36] CMAC, "Integrated Work Plan 2009," Phnom Penh, 20 February 2009, p. 44.
[37] CMVIS, "Annual Report 2007," Phnom Penh, August 2008, p. 18.

សារការ "ដោះមីនក្រៅក្របខណ្ឌឡើយ" នេះប្រហែលជាមកពីសកម្មភាពបែបនេះមានការធ្លាក់ចុះដោយសារមានការដាក់ទោសពិន័យឬ ក៏មានការរាយការណ៍តិចតួចដោយសារមានការដាក់ទោសពិន័យ ។

ការគ្រោះថ្នាក់ដោយសារមីនកើតមានចំនួន ១៩ខេត្តក្នុងចំណោម២៤ខេត្ត ក្នុងនោះរួមទាំងមាន២ខេត្ត ដែលមិនមានអ្នកគ្រោះថ្នាក់ក្នុងឆ្នាំ ២០០៧ (ខេត្តកំពង់ចាម និង ព្រៃវែង) ។ គ្រោះថ្នាក់ដោយសារមីនមាននៅក្នុង ៨ ខេត្ត ។[38] ខេត្តចំនួន ៤ ដែលមានអ្នកគ្រោះថ្នាក់ដោយសារមីននៅឆ្នាំ២០០៧ មិនបានកត់ត្រាអ្នកគ្រោះថ្នាក់នៅឆ្នាំ២០០៨ ឡើយ (មានខេត្តកំពត ក្រុងព្រះសីហនុ ភ្នំពេញ និងខេត្តស្ទឹងត្រែង) ។ យ៉ាងណាក្តី នៅឆ្នាំ ២០០៧ គ្រាន់តែខេត្ត ២ ប៉ុណ្ណោះមានអត្រាគ្រោះថ្នាក់ចំនួន ៤៤ % នៃគ្រោះថ្នាក់សរុប- បាត់ដំបង ( ៣២% ឬ ៨៧ នាក់ ដែលនេះជាចំនួនលើសឆ្នាំ ២០០៧ ដែលមាន ៨២ នាក់) បន្ទាប់មកខេត្តបន្ទាយមានជ័យ (មាន៣១នាក់ តិចជាងឆ្នាំ២០០៧ ដែលមាន៥៥ នាក់) ។ សម្រាប់ឆ្នាំ២០០៧ នេះផងដែរ ខេត្តផ្សេងទៀតដែលមានអ្នកគ្រោះថ្នាក់ចំនួន ២០ ឬ ច្រើនជាងនេះ មានគឺខេត្ត ឧត្តរមានជ័យ (២៧នាក់) ក្រុងប៉ៃលិន (២២នាក់) និងខេត្តព្រះវិហារ (២២នាក់) ។ បរិមាណគ្រោះថ្នាក់ដែលធ្លាក់ចុះច្រើនគួរអោយកត់សំគាល់មាននៅសៀមរាប (១៤នាក់ ដែលពីមុនមាន ៣២ នាក់) ។

សរុបមក៦៣% នៃអ្នកគ្រោះថ្នាក់នោះត្រូវបានគេរាយការណ៍ថាធ្លាប់បានទទួលការអប់រំពីគ្រោះដោយសារមីនបើប្រៀបធៀបទៅឆ្នាំ ២០០៧ មាន ៨៣% ។

ចំនួនអ្នកគ្រោះថ្នាក់ដែលមានក្នុងរបាយការណ៍បានធ្លាក់ចុះនៅឆ្នាំ ២០០៩ ដែលមាន ១២៨ នាក់ ( ១៩ នាក់ស្លាប់ និង ១០៩ នាក់រងរបួស) គិតមកត្រឹមចុងខែឧសភា ។ ចំនួនគ្រោះថ្នាក់នៅក្នុងពេលដដែលនៅឆ្នាំ ២០០៨ មានចំនួន ១៥២ នាក់ ។ អ្នករងគ្រោះថ្នាក់១២នាក់ជាទាហាន ក្នុងនោះរួមទាំងទាហានថៃ២នាក់និងអ្នកដោះមីន២នាក់ដែរ ។ សំណល់ជាតិផ្ទុះសល់ពីសង្គ្រាមបង្កឱ្យមានគ្រោះថ្នាក់ចំនួន ៦០ នាក់ ( ២៣ នាក់បានប៉ះពាល់/លេងគ្រាប់ និង ១២នាក់ឈរមើល) ដោយមីនប្រឆាំងមនុស្សមាន ៤៨ នាក់ ដោយមីនប្រឆាំងយានយន្តមាន ១៧ នាក់ និងដោយឧបករណ៍កែឆ្នៃសម្រាប់បំផ្ទុះមាន ៣ នាក់ ។

***សេចក្តីសង្ខេបការខាតសម្រាប់រយៈពេល១០ឆ្នាំ***

គិតមកត្រឹមថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០៩ ប្រព័ន្ធទិន្នន័យជនរងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា (CMVIS) បានកត់ត្រាករណីគ្រោះថ្នាក់ដោយសារមីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមចំនួន ៦៣៤០២នាក់: ១៩៤៧៦ នាក់ស្លាប់ និង ៤៣៩២៦នាក់ រងរបួស តាំងពីឆ្នាំ១៩៧៩មក ។ ក្នុងចំណោមអ្នកទាំងនេះ មាន៧៣០០នាក់ត្រូវបានកត់ត្រាក្នុងរវាងឆ្នាំ ១៩៩៩ ដល់ ២០០៨ ដោយរួមទាំងមាន ១៣៨៥ នាក់ស្លាប់ និង ៥៩១៥ នាក់រងរបួស ។[39] ប្រមាណ ១៤% នៃអ្នករងគ្រោះត្រូវបាត់បង់ដៃ និង/ឬជើង និង៨៤%បណ្តាលមកពីគ្រាប់មីនសុទ្ធសាធ ។[40] នៅរវាងឆ្នាំ ២០០០ និង ២០០៥ អត្រាគ្រោះថ្នាក់ស្ថិតក្នុង

[38] Banteay Meanchey, Battambang, Krong Pailing, Mondol Kiri, Otdar Meanchey, Preah Vihar, Pursat, and Svay Rieng.

[39] 1999: 1,153; 2000: 858; 2001: 826; 2002: 847; 2003: 772; 2004: 898; 2005: 875; 2006: 450; 2007: 352; and 2008: 269. See also, Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 9 (mentioning 63,217 casualties between 1979 and August 2008).

[40] Ibid.

កម្រិតមួយថេរដដែល ប៉ុន្តែមានការធ្លាក់ចុះយ៉ាងខ្លាំងចំនួន៥០%នៅឆ្នាំ២០០៦ ហើយចាប់ពីពេលនោះមកក៏បានបន្តធ្លាក់ចុះរហូត។ ការធ្លាក់ចុះនោះត្រូវបានគេពិពណ៌នាថាដោយសារលក្ខណ្ឌរដូវកាល អំណោយផល ឱកាសសម្រាប់បង្កើនស្ថានភាពសេដ្ឋកិច្ចប្រសើរឡើង និងការចូលរួមក្នុងការងារសហគមន៍មានច្រើនក្នុងការធ្វើផែនការសកម្មភាព និងដៅអាទិភាពដោះមីន។ បន្ថែមលើសនេះទៅទៀត ការត្រួតពិនិត្យលើអាជីវកម្មអេតចាយ និងការដោះមីនក្រៅផ្លូវការនៅខេត្តខ្លះ ក៏ជាកត្តាជួយផងដែរ។[41] គេពុំឃើញមានការសិក្សាតាមដានរឿងនេះឡើយ ប៉ុន្តែគេបានសន្និដ្ឋានថា ការដោះមីន និងការកំណត់អាទិភាពតំបន់ដោះមីនបានជួយយ៉ាងច្រើនបំផុតដល់ការធ្លាក់ចុះនេះ។[42]

ក្រុមមនុស្សដែលរងគ្រោះខ្លាំងជាងគេនៅចន្លោះឆ្នាំ ១៩៩៩ និង ២០០៨ មានបុរស (៤៥៤៤ នាក់) កុមារា (១៨២៣ នាក់) ស្ត្រី (៥២០ នាក់) និងកុមារី ( ៤១៣ នាក់)។ អ្នករងគ្រោះភាគច្រើនជាជនស៊ីវិល ( ៣៩៧៣ នាក់ ) ១៩១ នាក់ជាកងរក្សាសន្តិសុខ ១០៦ នាក់ជាអ្នកដោះមីន ២៨ នាក់ជាអ្នកដោះមីនពុំមានឯកទេស និង ៦២ នាក់ ជាក្រុមផ្សេងដែលគេពុំដឹង។ សម្រាប់មនុស្សចំនួន ២៩៤០ នាក់ដែលថាស្ថិតក្នុងក្រុមយោធា-ស៊ីវិល មិនត្រូវបានគេកត់ត្រាអោយច្បាស់ឡើយ ប៉ុន្តែសកម្មភាពរបស់គេបង្ហាញថាមានតែ ១៩២ នាក់ប៉ុណ្ណោះ ដែលពាក់ព័ន្ធជាយោធា ធ្វើការដោះមីនឬ សកម្មភាពដទៃទៀត និងមាន ៩៥១នាក់ជាកុមារី ឬ ស្ត្រី។ ដូច្នេះ គេអាចសន្មត់បានថាមានមនុស្សរហូតដល់ ៦៧២១ នាក់ (៩២% )ជាជនស៊ីវិល។

ជនរងគ្រោះចំនួនពាក់កណ្តាលបណ្តាលមកពីមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម (៣៦៧៦នាក់) ដែលក្នុងនោះរួមទាំងអ្នករងគ្រោះដោយគ្រាប់រំសេវតូចៗមាន១៥៩នាក់ផងដែរ។ ទំនងបំផុតដែលថាជនរងគ្រោះដោយគ្រាប់បែកតូចតាចមិនត្រូវបានគេរាយការណ៍ពេញលេញឡើយ ដោយហេតុថាប្រព័ន្ធទិន្នន័យជនរងគ្រោះដោយសារមីននិងគ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា ទើបតែចាប់ផ្តើមដាក់ក្រុមជនរងគ្រោះប្រភេទនេះ ចេញពីជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមក្នុងខែកញ្ញា ឆ្នាំ ២០០៦នេះប៉ុណ្ណោះ។[43] ជនរងគ្រោះដោយសារមីនប្រឆាំងមនុស្សមានចំនួន១៩៧០នាក់ (២៧%) ដោយមីនប្រឆាំងមនុស្សចំនួន ៦៩០ នាក់ ដោយមីនដែលគេមិនដឹងប្រភេទចំនួន ៨២២ នាក់ ដោយគ្រាប់កែឆ្នៃមាន ១៤១ នាក់ និង ដោយឧបករណ៍ដែលគេមិនដឹងប្រភេទមាន១នាក់។ សកម្មភាពភាគច្រើនដែលនាំឱ្យមានការគ្រោះថ្នាក់នោះមានៈ ការប៉ះពាល់មីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ( ២៥៦៥ នាក់ក្នុងនោះមាន ១០៧៥ នាក់ជាកុមារា) ធ្វើស្រែចំការ (១០៤៥ នាក់) ធ្វើ ដំណើរមាន (៩៤៣ នាក់) និងអ្នកឈរមើល (៨២៣ នាក់)។ គ្រោះថ្នាក់នេះមាននៅគ្រប់ខេត្តទាំងអស់នៅកម្ពុជា ប៉ុន្តែភាគច្រើននៅខេត្តបាត់ដំបង (១៩៤២ នាក់) បន្ទាយមានជ័យ (១១៧២ នាក់) ឧត្តរមានជ័យ (៦៩០ នាក់) ក្រុងប៉ៃលិនមាន (៦១២ នាក់) និងព្រះវិហារ (៤៥៧ នាក់)។ គ្រោះថ្នាក់ភាគច្រើនកើតឡើងនៅក្នុងភូមិ ឬ តំបន់ដែលគេកាប់ឆ្ការថ្មី (២០៥៧ នាក់) ឬ វាលស្រែ (១០៨២ នាក់)។

ព័ត៌មានត្រឹមត្រូវអំពីចំនួនជនពិការនៅកម្ពុជា និងស្ថានភាពរស់នៅរបស់គេមានមិនគ្រប់គ្រាន់ឡើយ។ ព័ត៌មានដែលមានកំណត់ត្រូវបានគេដាក់បញ្ចូលក្នុងការធ្វើជំរឿនឆ្នាំ ២០០៨ ប៉ុន្តែព័ត៌មាននេះមិនត្រូវបានគេដាក់ផ្សាយចែកចាយឡើយរហូតមក

---

41 See *Landmine Monitor Report 2007*, p. 229.
42 Interview with Chhiv Lim, Project Manager, CMVIS, Kampong Thom, 9 April 2009.
43 HI, *Circle of Impact: The Fatal Footprint of Cluster Munitions on People and Communities*, Brussels, May 2007, p. 23.

ដល់ខែកក្កដា ឆ្នាំ ២០០៩ នេះទៅហើយ ។ នៅដើមឆ្នាំ ២០០៩ វិទ្យាស្ថានជាតិស្ថិតិបានបង្កើតទម្រង់តេស្តមួយសម្រាប់ការអង្កេតសាកល្បងមួយទៅលើពិការភាព ។ បើសមស្រប ទម្រង់នេះនឹងអាចយកទៅប្រើជាឧបករណ៍សម្រាប់អង្កេតថ្នាក់ជាតិលើពិការភាព ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។[44]

***សណ្ឋានគ្រោះថ្នាក់ដោយសារមីន***

ពលរដ្ឋទូទៅប្រឈមមុខនឹងគ្រោះថ្នាក់ដោយសារមីននៅតំបន់ប៉ែកពាយព្យ័និងឧត្តរ ដែលជាតំបន់ព្រំដែនជាប់ប្រទេសថៃ និងគ្រោះថ្នាក់ដោយយុទ្ធភណ្ឌមិនទាន់ផ្ទុះក្នុងតំបន់ទាំងនេះ និងបណ្តាខេត្តប៉ែកនិរតីជាប់ព្រំដែនប្រទេសវៀតណាម ។[45] តំបន់ទាំងនេះភាគច្រើនមិនទាន់ដាក់សម្គាល់កំណត់តំបន់មីនឡើយ ។[46]

ហេតុការណ៍គ្រោះថ្នាក់ទាំងនេះ បណ្តាលមកពីការប៉ះពាល់ដោយមិនដឹងខ្លួនក្នុងពេលប្រកបរបររកស៊ីដូចជាការធ្វើចំការ និងកាប់ព្រៃ[47] និងដោយការចាប់កាន់យុទ្ធភណ្ឌមិនទាន់ផ្ទុះដោយចេតនា ជាពិសេសចំពោះក្មេងជំទង់ប្រុស។ ។ មនុស្សទូទៅរំកិលយុទ្ធភណ្ឌមិនទាន់ផ្ទុះទៅកាន់កន្លែងដែលគេគិតថាមានសុវត្ថិភាព ។ ការដើររើសអេតចាយក៏នៅតែជាបញ្ហាដ៏ធំមួយ បើទោះជាមានច្បាប់ប្រឆាំងនឹងការប្រមូលគរទុកលោហៈធាតុក៏ដោយ ។ ចំណែកឯការធ្លាក់ចុះនៃតំលៃអេតចាយក៏អាចថាមានផលជាវិជ្ជមានទៅលើស្ថានភាពនេះដែរ ។[48] យុវជនដែលឈប់រៀនជាក្រុមដែលងាយរងគ្រោះខ្លាំងជាងគេ ។[49]

កំណើនប្រជាជន និងតម្រូវការសម្រាប់កសិកម្មបន្តក៏ជម្រុញអោយមនុស្សទៅរកតំបន់ដែលរងគ្រោះដោយមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ។[50] តំបន់ខាងកើតទន្លេមេគង្គក្លាយជាតំបន់អាទិភាពខ្ពស់សម្រាប់ការអប់រំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន ពីព្រោះតំបន់នោះបើកទូលាយសម្រាប់ការអភិវឌ្ឍ និងធ្វើអោយមនុស្សនាំគ្នាទៅរស់នៅទីនោះ ។[51]

***ផលវិបាកលើសង្គម-សេដ្ឋកិច្ច***

បើទោះជាមានការធ្លាក់ចុះយ៉ាងខ្លាំងនៃគ្រោះថ្នាក់មីនក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មី។នេះ ក៏ដោយបញ្ហាគ្រាប់មីន និងគ្រាប់មិនទាន់ផ្ទុះសល់ពីសង្គ្រាម នៅកម្ពុជានៅតែជាឧបសគ្គដ៏ធំចំពោះការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច ។ យោងទៅតាមអាជ្ញាធរមីនកម្ពុជា គ្រាប់មីននិងគ្រាប់មិនទាន់ផ្ទុះ ដែលនៅសេសសល់ពីសង្គ្រាម" ជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់ជីវភាពរស់នៅរបស់ពលរដ្ឋនៅជនបទដោយការរាំងស្ទះចំពោះការទៅរកធនធានដើម្បីផលិត ទីផ្សារ និងសេវាសង្គម ដីកសិកម្ម និងលំនៅដ្ឋាន ធារាសាស្ត្រ ផ្លូវថ្នល់ ផ្លូវទៅរកប្រភពទឹក មណ្ឌលសុខភាព សាលារៀន និងហេដ្ឋារចនាសម្ព័ន្ធជនបទ ។ ដោយសារគ្រាប់មីននេះដាក់ក្បែរទីតាំង

---

[44] Interview with Po Mao, Deputy Director, Department of Social Affairs Statistics, Ministry of Planning, Phnom Penh, 6 April 2009.
[45] Response to Landmine Monitor questionnaire by Ruth Bottomley, Community Liaison Manager Southeast Asia, MAG, 6 July 2009.
[46] Interview with Oum Sang Onn, Director of Planning and Operations, CMAC, in Geneva, 28 April 2009.
[47] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008; and response to Landmine Monitor questionnaire by Ruth Bottomley, MAG, 6 July 2009.
[48] Interview with Oum Sang Onn, CMAC, in Geneva, 28 April 2009; and response to Landmine Monitor questionnaire by Ruth Bottomley, MAG, 6 July 2009.
[49] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008.
[50] Response to Landmine Monitor questionnaire by Ruth Bottomley, MAG, 6 July 2009; and interview with Oum Sang Onn, CMAC, in Geneva, 28 April 2009.
[51] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008, p. 7.

តំបន់ប្រាសាទបុរាណ គ្រាប់មីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ក៏បានជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរដល់សកម្មភាពសេដ្ឋកិច្ច និងការអភិវឌ្ឍន៍ទេសចរណ៍ ដែលជាប្រភពចំណូលយ៉ាងធំរបស់កម្ពុជាផងដែរ ។[52]

## ការគ្រប់គ្រង និងសម្របសម្រួលកម្មវិធីមីន

### *សកម្មភាពមីន*

អាជ្ញាធរមីនកម្ពុជា(CMAA)ដែលបង្កើតឡើងនៅខែកញ្ញា ឆ្នាំ២000 ជាអ្នកគ្រប់គ្រង និងសម្របសម្រួលសកម្មភាពមីន ដែលពីមុនជាតួនាទីនេះជារបស់អង្គការស៊ីម៉ាក់ ។[53] អាជ្ញាធរមីនកម្ពុជាមាន៦នាយកដ្ឋាន ដែលទទួលខុសត្រូវលើការអនុវត្តតាមច្បាប់និងការទទួលស្គាល់គុណភាពលើប្រតិបត្តិករទាំងអស់ រៀបចំផែនការយុទ្ធសាស្ត្រ គ្រប់គ្រងទិន្នន័យនិងគ្រប់គ្រងគុណភាព ។[54] លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រធាននៃអាជ្ញាធរមីនកម្ពុជា និងមានទេសរដ្ឋមន្ត្រីក្នុងរដ្ឋាភិបាល១រូប (រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី) **ប្រាក់ សុខុន** មាននាទីជាអនុប្រធានទី២របស់ អាជ្ញាធរមីនកម្ពុជាកាលពីឆ្នាំ២០០៥ ដែលដឹកនាំការពិភាក្សាជាមួយម្ចាស់ជំនួយ និងមាននាទីជាប្រធានក្រុមការងារបច្ចេកទេសរវាងរដ្ឋាភិបាលនិងម្ចាស់ជំនួយសំរាប់ការបោសសំអាតមីន ។[55]

ការគ្រប់គ្រងប្រចាំថ្ងៃរបស់អាជ្ញាធរមីនកម្ពុជា ជាបន្ទុករបស់អគ្គលេខាធិការ ។ ក្នុងខែ មករា ឆ្នាំ ២០០៨ រដ្ឋាភិបាលបានតែងតាំងលោក សម សុត្ថា ដែលជាអគ្គលេខាធិការ ជាតំណែងអគ្គរាជទូតរបស់កម្ពុជាស្តីពីការងារមីន និងគ្រាប់បែកចង្កោម ។[56] យ៉ាងណាក្តី នៅខែ ធ្នូ ឆ្នាំ ២០០៨ លោកនាយករដ្ឋមន្ត្រី **ហ៊ុន សែន** បានជំនួសគាត់ក្នុងមុខតំណែងដោយ លោក **ជុំ ប៊ុនរ៉ុង** អតីតអគ្គនាយកមូលនិធិសង្គម ដែលពុំមានបទពិសោធន៍ផ្នែកសកម្មភាពមីនឡើយ ។[57]

### *ការអប់រំពីគ្រោះថ្នាក់ដោយសារមីន*

អាជ្ញាធរមីនកម្ពុជា ក៏ជាអ្នកគ្រប់គ្រងនិងសម្របសម្រួលការអប់រំពីគ្រោះថ្នាក់ដោយសារមីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។ ការសិក្សាវាយតំលៃពីខាងក្រៅមួយដែលធ្វើដោយអង្គការយូនីសេហ្វ (UNICEF) នៅខែតុលា ឆ្នាំ២០០៨ ដើម្បីពិនិត្យមើលលើសមត្ថភាពដែលត្រូវការសម្រាប់ឱ្យរដ្ឋាភិបាលធ្វើការសម្របសម្រួលអន្តរកាលនៃការអនុវត្តកម្មវិធីជាតិ និង ដើម្បីផ្តល់យោបល់ដល់ការពិនិត្យឡើងវិញលើយុទ្ធសាស្ត្រ ។[58]

---

52 CMAA, "National Strategy on Explosive Remnants of War," Phnom Penh, January 2008, p. 6.

53 CMAC is the leading national demining operator, but does not exercise the wider responsibilities associated with the term "center." Set up in 1992, CMAC was assigned the role of coordinator in the mid-1990s. It surrendered this function in a restructuring of mine action in 2000 that separated the roles of regulator and implementing agency and led to the creation of the CMAA.

54 "A Study of the Development of National Mine Action Legislation," GICHD, November 2004, pp. 64–66. The departments are: regulation and legislation, planning, monitoring and database, VA, coordination and public relations, administration, personnel and logistics, and finance.

55 See *Landmine Monitor Report 2006*, pp. 249–250. Prak Sokhonn is now the only vice-president of CMAA. Email from Pascal Rapillard, GICHD, 4 September 2009.

56 Technical Working Group for Mine Action, "Summary Report," Meeting, 19 February 2008, pp. 3–4; and interview with Amb. Sam Sotha, Secretary-General, CMAA, in Geneva, 3 June 2008.

57 Sam Rith, "Demining head loses two posts in reshuffle," *Phnom Penh Post*, 30 December 2008, khmernz.blogspot.com.

58 "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008.

ការសម្របសម្រួលកិច្ចប្រជុំនៃក្រុមការងារបច្ចេកទេសសម្រាប់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន (MRE-TWG) ធ្វើឡើងនៅកម្រិតជាតិ រីឯក្រុមប្រតិបត្តិករជួបគ្នាជាញឹកញាប់ដើម្បីធ្វើអោយខ្លឹមសារកាន់តែច្បាស់។[59] ក្រុមការងារបច្ចេកទេសសម្រាប់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន រួមមានសមាជិកជាអ្នកពាក់ព័ន្ធមកពីស្ថាប័នរដ្ឋាភិបាល ក្រុមប្រតិបត្តិករ និងដៃគូអភិវឌ្ឍន៍។ ការវាយតំលៃរបស់អាជ្ញាធរមីន/យូនីសេហ្វ (CMAA/UNICEF) បានបង្ហាញថាជាទូទៅការសម្របសម្រួលមានភាពល្អ បើទោះជាការសម្របសម្រួលរបស់ អាជ្ញាធរមីនកម្ពុជានៅមានលក្ខណៈផ្លូវការតិចជាងសព្វដងក៏នៅមានផលផងដែរ។[60]

សកម្មភាពអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីនត្រូវបានគេតាមដានផ្ទៃក្នុងដោយក្រុមប្រតិបត្តិករបុគ្គលនិងពីខាងក្រៅដោយអាជ្ញាធរមីនកម្ពុជា។ យ៉ាងណាក្តី ការសិក្សាវាយតំលៃរបស់ CMAA/UNICEF បានរកឃើញថា " សូចនាករយុទ្ធសាស្ត្រ និងកម្មវិធីទាំងឡាយមានតែបរិមាណ តែពុំបានកំណត់ក្រុមគោលដៅច្បាស់លាស់ ហើយផ្តោតជាចម្បងទៅលើសកម្មភាព និងផលិតភាពរបស់កម្មវិធី ជាជាងបម្រែបម្រួលលើឥរិយាបថ និងលទ្ធផល។"[61]

***ការផ្តល់ជំនួយដល់ជនរងគ្រោះ***

អាជ្ញាធរមីនកម្ពុជា បានប្រគល់ការងារសម្របសម្រួលក្នុងការជួយដល់ជនរងគ្រោះទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ តាមរយៈអនុក្រិត្យឆ្នាំ ២០០១។[62] នៅខែមេសា ឆ្នាំ២០០៩ ដំណើរការនេះបានចាប់ផ្តើមធ្វើការផ្លាស់ប្តូរគណៈកម្មធិការអចិន្ត្រៃយ៍ ស្តីពីជំនួយដល់ជនរងគ្រោះដោយសារមីន ទៅជាគណៈកម្មាធិការជាតិសម្របសម្រួលជនពិការ (NDCC)។ ការងាររបស់គណៈកម្មាធិការនឹងត្រូវបានពង្រីកពីការងារសម្របសម្រួលផែនការជួយជនរងគ្រោះថ្នាក់មីនទៅជាការងារសម្របសម្រួលទូទៅសម្រាប់ផ្នែកពិការភាព។ NDCC នឹងដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ជាលេខាធិការដ្ឋាន រីឯក្រសួងពាក់ព័ន្ធ អ្នកផ្តល់សេវាកម្ម និងអង្គការជនពិការជាសមាជិក។[63] NDCC បានយល់ព្រមដោយសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** នៅខែដើមខែសីហា[64] បើទោះជាសមាជិកទាំងឡាយបានជួបប្រជុំមុនពេលទទួលបានការអនុម័តនេះក៏ដោយ។ យ៉ាងណាក្តី ការសម្របសម្រួលការងារពិតប្រាកដរវាងក្រសួងពាក់ព័ន្ធ ស្ថិតក្នុងកម្រិតមួយមានកំណត់ និងមានកាន់តែតិចតួចថែមទៀតរវាងអាជ្ញាធរមីនកម្ពុជា និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា។[65]

---

[59] Interview with Oum Sang Onn, CMAC, in Geneva, 28 April 2009; and response to Landmine Monitor questionnaire by Ruth Bottomley, MAG, 6 July 2009.
[60] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008.
[61] Ibid, p. 11.
[62] Interview with Thong Vinal, Executive Director, DAC, Phnom Penh, 10 April 2009.
[63] NDCC Terms of Reference, distributed at the Steering Committee for Landmine Victim Assistance meeting, MoSVY, Phnom Penh, 10 April 2009.
[64] Email from Sheree Bailey, Victim Assistance Specialist, Implementation Support Unit, GICHD, 6 September 2009.
[65] Email from Teresa Carney, Programme Coordinator, ARC, 3 July 2009; email from Ket Chanto, Education Program Manager, WVC, Phnom Penh, 14 July 2009; and interview with and email from Ngin Saorath, Executive Director, CDPO, Phnom Penh, 7 April and 13 July 2009.

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ទទួលខុសត្រូវលើការងារជនពិការជាទូទៅ ដោយផ្តោតទៅលើវិធីសាស្រ្តរួមបញ្ចូលការងារជួយដល់ជនរងគ្រោះថ្នាក់មីនទៅក្នុងរចនាសម្ពន្ធ័ទូទៅរបស់ខ្លួន។[66] ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាបានផ្តល់ការទទួលខុសត្រូវឱ្យទៅតាមមន្ទីរស្រុកនិងខេត្ត។ ទោះជាយ៉ាងណា ដោយសារតែការងារមុនគេផ្តោតទៅលើអតីតយុទ្ធជនមួយមុខនោះរចនាសម្ពន្ធ័របស់ក្រសួងនៅគ្រប់ជាន់ថ្នាក់ មិនមានលទ្ធភាពគ្រប់គ្រាន់ក្នុងការដោះស្រាយបញ្ហាពិការភាពដ៏ទូលំទូលាយនោះឡើយ។ បណ្តាញមន្ទីររបស់ខ្លួន" ជាញឹកញាប់មិនមានធនធានគ្រប់គ្រាន់ ខ្វះបទពិសោធន៍ ឬ ស្ទាក់ស្ទើរក្នុងការអនុវត្តសេចក្តីណែនាំរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា"។[67] ទំហំទឹកចិត្តធ្វើការងាររបស់មន្ទីរនៅតាមមូលដ្ឋានមានផ្សេងៗគ្នា។[68]

DAC និងក្រុមការងារផ្សេងៗទៀត ដែលរួមមានប្រតិបត្តិករជាតិ និងអន្តរជាតិ និងទីប្រឹក្សារបស់ខ្លួន បានផ្តល់យោបល់ផ្នែកបច្ចេកទេសទៅអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ប៉ុន្តែតាំងពីឆ្នាំ២០០៦ មកស្ថាប័ននេះមានសមត្ថភាពកំណត់ក្នុងការធ្វើការងារនេះ។[69]

***ការប្រមូល និងគ្រប់គ្រងទិន្នន័យ***

នៅឆ្នាំ ២០០៨ CMAA បានដាក់អាទិភាពលើការកែលម្អប្រពន្ធ័ទិន្នន័យរបស់ខ្លួនអោយបានល្អ តាមរយៈជំនួយបច្ចេកទេសពីជំនួយរបស់ពលរដ្ឋន័រវេ (NPA)។ ការងារនេះជាតម្រូវការសារវន្តសម្រាប់រៀបចំផែនការយុទ្ធសាស្រ្តរយៈពេល ១០ឆ្នាំថ្មីមួយ។ ផែនការបង្កើតក្នុងន័យដាក់អមជាមួយសំណើរសុំពន្យារពេលដោះមីនតាមមាត្រាទី៥ នៃសន្ធិសញ្ញាហាមប្រាមការប្រើប្រាស់មីន (សូមមើលសេចក្តីសង្ខេបលើការប្រឹងប្រែងអនុវត្តតាមមាត្រាទិ ៥ ខាងក្រោមនេះ)។[70]

ការសិក្សាវាយតំលៃមួយធ្វើឡើងដោយក្រុមអ្នកស្ម័គ្រចិត្តអន្តរជាតិអូស្រ្តាលីនាឆ្នាំ២០០៧ ត្រូវបានគេរកឃើញថាមិនមានបទដ្ឋានសម្រាប់ការចងក្រងឯកសារ ឬ ការធ្វើរបាយការណ៍ឡើយ។ គេរកឃើញថាការងារនេះមានភាពផ្សេងគ្នារវាងប្រតិបត្តិករនិមួយៗនិងរកឃើញដែរថាCMAAមានការលំបាកក្នុងការប្រមូលដាក់ទិន្នន័យតែមួយដែលមិនអាចយកទៅប្រើប្រាស់បាននិងទ្បេងទាត់ពេលវេលា។ អ្នកផ្តល់ទិន្នន័យដោយឡែកៗមានវិធីសាស្រ្តក្នុងការគ្រប់គ្រងទិន្នន័យល្អប៉ុន្តែគេធ្វើការផ្សេងៗគ្នា។ លើសពីនោះទៅទៀត កងយោធពលខេមរភូមិន្ទ ប៉ូលីស និងប្រតិបត្តិករពាណិជ្ជកម្ម" មិនបានធ្វើរបាយការណ៍អំពីការបោសសំអាត ឬ យុទ្ធភណ្ឌមិនទាន់ផ្ទុះដែលគេដោះបានឱ្យទៅ CMAA បានទ្បេងទាត់ឡើយ"។[71] នៅខែមិថុនា ឆ្នាំ២០០៨ ប្រតិបត្តិករបានចាប់

[66] Interview with Teresa Carney, ARC, Phnom Penh, 6 April 2009; and interview with Bruno Leclercq, Country Director, HI-B, Phnom Penh, 10 April 2009.
[67] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 8.
[68] Interview with Sok Sophorn, Manager Rehabilitation Center, HI-B, Siem Reap, 8 April 2009; email from Meas Vicheth, Project Manager, Operations Enfants du Cambodge (OEC), 10 July 2009.
[69] See *Landmine Monitor Report 2008*, p. 222; interview with Teresa Carney, ARC, Phnom Penh, 6 April 2009; and interview with Bruno Leclercq, HI-B, Phnom Penh, 10 April 2009.
[70] Interview with Amb. Sam Sotha, CMAA, in Geneva, 2 June 2008; and interview with Steve Munroe, Mine Action Programme Manager, UNDP, Phnom Penh, 28 April 2008.
[71] Australian Volunteers International, "Recommendations for a Collective Information Management Strategy for the Cambodian ERW Action Sector, (Draft)," Phnom Penh, May 2007, pp. 1–7.

ផ្តើមធ្វើរបាយការណ៍លើទិន្នន័យសំអាតមីនទៅឱ្យ CMAA ដោយប្រើប្រាស់ទម្រង់បទដ្ឋានដែលត្រូវបានដាក់ពិនិត្យសារឡើងវិញនៅឆ្នាំ ២០០៩ ។[72]

គិតមកដល់ឆ្នាំ២០០៧ CMAA បានធ្វើប្រតិបត្តិការដោយប្រើប្រាស់ទិន្នន័យដែលខ្លួនបានបង្កើតដោយប្រើទម្រង់ចាស់របស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានសម្រាប់សកម្មភាពកំចាត់មីន (IMSMA) ។ ក្នុងឆ្នាំ២០០៧ CMAA បានបញ្ចូលកម្មវិធី IMSMA ថ្មីបំផុត ហើយបុគ្គលិកទាំងឡាយទទួលការបណ្តុះបណ្តាលពីមជ្ឈមណ្ឌលដោះមីនមនុស្សធម៌អន្តរជាតិក្រុងហ្សឺណែវ (GICHD) ប៉ុន្តែប្រព័ន្ធថ្មីនេះមានការលំបាកក្នុងការទទួលយកទិន្នន័យថ្មី ។ ជាលទ្ធផលជំនួយរបស់ប្រជាជនន័រវេ (NPA) បានជួយរៀបចំបង្កើតបច្ចុប្បន្នភាពទិន្នន័យដីមានគ្រាប់មីនថ្មីនៅឆ្នាំ២០០៨ ដោយប្រើប្រាស់កម្មវិធីថ្មី (Microsoft Access)[73] ។ មកដល់ខែសីហា ឆ្នាំ២០០៨ ជំនួយរបស់ប្រជាជនណ័រវេសបានកែសម្រួល និងបញ្ចូលរាល់ទិន្នន័យដែលមានទាំងអស់ ប៉ុន្តែអាជ្ញាធរមីនកម្ពុជា នៅតែបន្តមានការលំបាកក្នុងការផ្តល់នូវការវាយតំលៃពេញលេញលើដីមានមីន ដោយមូលហេតុថាមានការបាត់បង់ និងតួលេខខុសគ្នាពីទិន្នន័យក្នុងវិធីសាស្ត្រអង្កេត និងការកំណត់ប្រភេទទិន្នន័យរបស់ប្រតិបត្តិករលើបទអន្តរាគមន៍ដោះមីនផ្សេងៗ ។[74]

ទិន្នន័យអំពីការអប់រំអំពីគ្រោះថ្នាក់ដោយសារមីនរក្សាទុកតែនៅលើក្រដាសនៅឡើយ ហើយការសិក្សាវាយតំលៃរបស់ CMAA/UNICEF បានផ្តល់យោបល់អោយបញ្ចូលទិន្នន័យអំពីការអប់រំអំពីគ្រោះថ្នាក់ដោយសារមីនទៅក្នុងប្រព័ន្ធទិន្នន័យកណ្តាលរបស់ CMAA ដើម្បីសម្របសម្រួលការអនុវត្តដែលមានលក្ខណៈរួមជាងមុន ។[75]

ប្រព័ន្ធទិន្នន័យជនរងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា (CMVIS) បានកត់ត្រាទិន្នន័យតាំងពីឆ្នាំ ១៩៩៤មក ។ ចំនួនជនរងគ្រោះត្រូវបានគេរាយការណ៍តាមរយៈបុគ្គលិកបណ្តាញរបស់កាកបាទក្រហមកម្ពុជានិងអ្នកប្រមូលទិន្នន័យនៃ CMVIS ដែលមាននៅតាមលំដាប់ស្រុកនិងខេត្តនិងបញ្ចូលទៅក្នុងទិន្នន័យ ។ នៅចន្លោះឆ្នាំ១៩៩៩-២០០៨ ការប្រមូលទិន្នន័យ CMVIS មានគ្រប់គ្រាន់ ហើយគេបានធ្វើការកែលម្អលើប្រពន្ធ័ទិន្នន័យថ្មីនេះនាចុងឆ្នាំ ២០០៧ ។[76] ទិន្នន័យរបស់ CMVIS ត្រូវបានប្រើសម្រាប់ការធ្វើផែនការ និងកំណត់អាទិភាពលើការងារជួយសង្គ្រោះជនរងគ្រោះ ការអប់រំជនរងគ្រោះ ការដោះមីន និងការសម្អាតគ្រាប់យុទ្ធភណ្ឌមិនទាន់ផ្ទុះ ។ គេបានរៀបចំចែកចាយជារបាយការណ៍ប្រចាំឆ្នាំ និងប្រចាំខែយ៉ាងទូលំទូលាយ ។[77]

អង្គការជនពិការអន្តរជាតិ ប៊ែលហ្សិក ( HI-B ) បានបញ្ចប់ជំនួយបច្ចេកទេសដល់ CMVIS នៅចុង ខែ មិថុនា ឆ្នាំ ២០០៩ និងមានផែនការបញ្ចប់ជំនួយផ្នែកហិរញ្ញវត្ថុនៅចុងឆ្នាំ២០០៩[78] ដោយលើកឡើងថា CMVIS គួរតែ ចាប់ផ្តើមគ្រប់គ្រងបន្តិចម្តងៗដោយដៃគូថ្នាក់ជាតិ ។ អង្គការជនពិការអន្តរជាតិ ប៊ែលហ្សិក(HI-B ) បានលើកឡើងថានៅឆ្នាំ២០០៧ និង ២០០៨

[72] Interview with Arleen Engeset, Advisor, IMSMA in Southeast Asia, NPA, Phnom Penh, 30 March 2009.
[73] Interviews with Rune Engeset, Regional Program Manager, NPA, Phnom Penh, 28 April 2008; and Amb. Sam Sotha, CMAA, in Geneva, 2 June 2008.
[74] Interview with Arleen Engeset, NPA, Phnom Penh, 30 March 2009.
[75] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008, pp. 7, 8.
[76] See *Landmine Monitor Report 2008*, p. 216.
[77] CMVIS, "Annual Report 2007," Phnom Penh, August 2008, pp. 9–11.
[78] Email from Chhiv Lim, CMVIS, 13 July 2009.

សមភាគីកម្ពុជាមានការអល់អែកក្នុងការទទួលយកសមាហរណកម្មការងារនេះ។[79] នៅខែមេសា ឆ្នាំ ២០០៩ កាកបាទក្រហមកម្ពុជា និង អាជ្ញាធរមីនកម្ពុជាបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា ដើម្បីធានាអោយមាននិរន្តភាព និងការធ្វើសមាហរណកម្ម CMVIS ចូលក្នុងសកម្មភាពកំចាត់មីន។[80] ប៉ុន្តែ គេបានធ្វើការកត់សំគាល់ឃើញថា" កាកបាទក្រហមកម្ពុជាចាំបាច់ត្រូវមានជំនាញដើម្បីរក្សាបទដ្ឋានដែល CMVIS អនុវត្តបច្ចុប្បន្ន។"[81]

HI-B បន្តអះអាងថាការធ្លាក់ចុះជាបន្តបន្ទាប់នៃចំនួនអ្នកគ្រោះថ្នាក់បានបង្ហាញអំពីការថយចុះនៃតម្រូវការក្នុងការប្រមូលទិន្នន័យ។ អង្គការនេះបានបន្ថែមថាសម្រាប់ការងារទិន្នន័យ CMVIS គេគួរតែផ្តោតទៅលើចំនុចសំខាន់ស្នូលនៃការងារប្រមូលទិន្នន័យជនរងគ្រោះ ហើយគេមិនត្រូវអនុវត្តការអង្កេតលើសេវាកម្មជំនួយដល់ជនរងគ្រោះ ឬ សកម្មភាពអប់រំពីគ្រោះថ្នាក់ដោយមីន និងសកម្មភាពជំនួយដល់ជនរងគ្រោះទេ។ បែបនេះទើបបានជាគេអាចដឹងមុនពីការកាត់បន្ថយបុគ្គលិកសម្រាប់ការងារ CMVIS។[82] តាមរយៈទិន្នន័យ CMVIS គេកត់សំគាល់ឃើញថាចំនួនអ្នករងគ្រោះបានធ្លាក់ចុះ ប៉ុន្តែ ទំហំដីដែលគេត្រូវដោះមីននៅតែដដែល ដែលនាំឱ្យមានការលំបាកក្នុងការបន្តធ្វើការលើគ្រប់តំបន់ទូទាំងប្រទេស និងរក្សាទំនាក់ទំនងជាមួយក្រុមការងារគោលនៅសហគមន៍។ បញ្ហាសំខាន់នោះគឺថាអ្នកប្រមូលទិន្នន័យនៅតំបន់ខេត្តមួយចំនួនមិនសូវស្គាល់ស្ថានភាពសហគមន៍នោះច្បាស់លាស់ឡើយ ដែលនេះជាញឹកញាប់បណ្តាលអោយសហគមន៍នោះផ្តល់ព័ត៌មានបានតិចតួច។ តាមរយៈទិន្នន័យ CMVIS គេក៏កត់សំគាល់ឃើញថាការពឹងផ្អែកកាន់តែច្រើនឡើងលើអ្នកស្ម័គ្រចិត្តនឹងអាចប៉ះពាល់ដល់គុណភាពនៃទិន្នន័យដែលបានប្រមូលនៅពេលខាងមុខ។ ប៉ុន្តែទិន្នន័យនេះមិនបានលើកឡើងថានឹងមានការផ្តល់របាយការណ៍មិនពេញលេញច្រើននោះទេ។[83]

នៅខែមេសា ឆ្នាំ២០០៧ ដោយអនុលោមទៅតាមផ្នែកមួយនៃការព្រមព្រៀងជាមួយអង្គការHI-B ទិន្នន័យ CMVIS បានចាប់ផ្តើមធ្វើការអង្កេតលើអ្នកនៅមានជីវិតរស់ពីគ្រាប់មីនដើម្បីប្រមូលទិន្នន័យពីការផ្តល់ជំនួយដែលគេទទួលបាន និងសូចនករសង្គម-សេដ្ឋកិច្ច។ អង្គការ HI-B បានស្វែងយល់ឃើញថាព័ត៌មាននេះបានមាននៅកន្លែងមួយផ្សេង ហើយការដែលយកចិត្តទុកដាក់តែទៅលើអ្នកមានជីវិតរស់ពីគ្រាប់មីន និងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមជារឿងរើសអើងមួយ និង ក្រោយមកក៏បានធ្វើការដកជំនួយគាំទ្របច្ចេកទេសនៅខែសីហា ឆ្នាំ ២០០៨។[84] គិតត្រឹមខែ កក្កដា ឆ្នាំ ២០០៩ ការអង្កេតនោះនៅតែមិនអាចយកមកអនុវត្តបានដោយគេរង់ចាំការកែលម្អបញ្ជីសំនួរ។[85] យ៉ាងណាក្តី ប្រតិបត្តិករផ្សេងៗទៀតបានលើកឡើងដដែលៗថា ព័ត៌មាននេះត្រូវការដើម្បីបម្រើអោយមានជំនួយដល់ជនរងគ្រោះដ៏មានប្រសិទ្ធភាព និងថាការប្រមូល "ព័ត៌មានគឺដើម្បីធ្វើការវាយតំលៃ ជាបន្តបន្ទាប់លើស្ថានភាពជីវិតរស់នៅរបស់អ្នកនៅមានជីវិតពីគ្រាប់មីន និង សេវាកម្មផ្តល់ជំនួយដល់ពួកគេដែលទទួលបាន" និងជា

---

79 Interview with Hugo Hotte, Mine Action Project Coordinator, HI-B, Phnom Penh, 7 April 2009.
80 Interview with Chan Rotha, Deputy Secretary-General, CMAA, Phnom Penh, 6 April 2009.
81 Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 10.
82 Interview with Hugo Hotte, HI-B, Phnom Penh, 7 April 2009.
83 Interview with Chhiv Lim, CMVIS, Kampong Thom, 9 April 2009.
84 Interview with Hugo Hotte, HI-B, Phnom Penh, 7 April 2009; and emails from Hugo Hotte, 18 March and 7 September 2009.
85 Email from Chhiv Lim, CMVIS, 13 July 2009.

ទិសដៅសំខាន់មួយក្នុងផែនការជំនួយជនរងគ្រោះថ្នាក់មីននៅកម្ពុជាឆ្នាំ២០០៩-២០១១។[86] ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក៏បានសុំយោបល់ពីទិន្នន័យ CMVIS លើការគ្រប់គ្រងទិន្នន័យពិការភាព។[87]

ក្រុមប្រតិបត្តិករកម្មវិធីសកម្មភាពមីន

| ប្រតិបត្តិករជាតិ និងសកម្មភាព | ការដោះមីន | ការអប់រំពីគ្រោះថ្នាក់ដោយមីន | ការប្រមូលទិន្នន័យលើជនរងគ្រោះ | ជំនួយលើជនរងគ្រោះ |
|---|---|---|---|---|
| អង្គការ AAR | | | | X |
| អង្គការ CDMD | | | | X |
| អង្គការ Capacity Building of People with Disabilities in Community Organizations | | | | X |
| អង្គការ CDPO | | | | X |
| អង្គការ CMAC | X | X | | |
| CMVIS | | X | X | X |
| អង្គការ CRC | | X | X | X |
| អង្គការ DDSP | | | | X |
| ក្រសួងអបរំ យុវជន និងកីឡា | | X | | |
| ប៉ូលីសជាតិ | | X | | |
| កងយោធិពលខេមរភូមិន្ទ | X | X | | |
| អង្គការទស្សនៈពិភពលោកកម្ពុជា | | X | | X |
| **ប្រតិបត្តិករជាតិ និងសកម្មភាព** | **ការដោះមីន** | **ការអប់រំពីគ្រោះថ្នាក់ដោយមីន** | **ការប្រមូលទិន្នន័យលើជនរងគ្រោះ** | **ជំនួយលើជនរងគ្រោះ** |
| កាកបាទក្រហមកម្ពុជា | | | | X |
| អង្គការ Cambodia Trust | | | | X |
| អង្គការ Cambodian War Amputees Rehabilitation Society | | | | X |
| អង្គការ Economic and Social Relaunch of | | | | X |

[86] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 11; interview with Chan Rotha, CMAA, Phnom Penh, 6 April 2009; and interview with Plong Chhaya, Child Protection Officer, UNICEF, Phnom Penh, 7 April 2009.
[87] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 10.

| | | | | |
|---|---|---|---|---|
| Northwest Provinces in Cambodia | | | | |
| Emergency | | | | X |
| អង្គការ HALO Trust | X | X | | |
| អង្គការជនពិការអន្តរជាតិ បែលហ្សិក | | X | X | X |
| អង្គការជនពិការអន្តរជាតិ បារាំង | | | | X |
| កាកបាទក្រហមអន្តរជាតិ | | | | X |
| អង្គការ Mines Advisory Group | X | X | | |
| អង្គការ Jesuit Service Cambodia | | | | X |
| អង្គការ Opération Enfants du Cambodge | | | | X |
| អង្គការ Spirit of Soccer | | X | | |
| អង្គការ Veterans International | | | | X |

***ផែនការ***

*ផែនការយុទ្ធសាស្ត្រស្តីពីសកម្មភាពមីន*

ដោយបានទទួលការគាំទ្រពីអ្នកពាក់ព័ន្ធផ្សេងទៀត CMAA បានរៀបចំយុទ្ធសាស្ត្រសកម្មភាពមីនថ្នាក់ជាតិថ្មីមួយនៅឆ្នាំ២០០៩ ស្របជាមួយនឹងការរៀបចំសំណើរពន្យាពេលដោះមីនតាមកាលកំណត់ក្នុងមាត្រាទី៥។ យុទ្ធសាស្ត្រនោះគម្រោងនឹងមានបញ្ចូលរបៀបវារៈសម្រាប់ការប្រើប្រាស់ជំនួយអោយមានតម្លាភាព ក្នុងនោះមានដូចជា: " យុទ្ធសាស្ត្រគ្រឹះស្តីពីសកម្មភាពមីន" ដែលបានពង្រាងឡើង ដោយមានកិច្ចសហការពី GICHD។ "យុទ្ធសាស្ត្ររួម " ដើម្បីការងារដោះមីន សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម និងការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន ព្រមទាំងមានផែនការសកម្មភាពជាតិ សម្រាប់ជនពិការ និងសំណើរសុំពន្យាពេលដោះមីន។ CMAA រំពឹងថានឹងដាក់បង្ហាញយុទ្ធសាស្ត្រនោះនៅឯសន្និសីទបូកសរុបការងារលើកទី២ ស្តីពីសន្ធិសញ្ញាហាមប្រើប្រាស់មីននៅខែ វិច្ឆិកា-ធ្នូ ឆ្នាំ ២០០៩ខាងមុខនេះ។[88]

CMAA បានបង្កើតក្រុមការងារដើម្បីធ្វើពង្រាងយុទ្ធសាស្ត្រក្រោមការដឹកនាំរបស់អគ្គលេខាធិការរងលោក ព្រំ សុភមង្គលនិងមានអ្នកចូលរួមជាតំណាងមកពីអង្គការ UNDP, ក្រុមប្រតិបត្តិករ,អង្គការមិនមែនរដ្ឋាភិបាល, មជ្ឈមណ្ឌលជាតិសម្រាប់ការរក្សាសន្តិភាព និងក្រុមបច្ចេកទេស៦ក្រុម ដែលក្រុមទាំងនេះជួបប្រជុំគ្នាតែក្នុងពេលចាំបាច់ និងបានចាប់ផ្តើមងាកមកធ្វើការលើយុទ្ធសាស្ត្រជាតិសកម្មភាពមីន (NMAS) នាខែមិថុនា ឆ្នាំ ២០០៩។ ក្រុមការងារត្រូវរាយការណ៍ជូនគណៈកម្មការត្រួតពិនិត្យដែលដឹកនាំដោយអគ្គលេខាធិការអាជ្ញាធរមីនកម្ពុជា ឯកឧត្តម ជុំ ប៊ុនរ៉ុង។[89]

---

[88] Statement by Chum Bun Rong, Secretary-General, CMAA, NMAS workshop, Phnom Penh, 6 July 2009.

[89] CMAA, "Plan for the development of a National Mine Action Strategy," Phnom Penh, undated but June 2009, p. 3; and telephone interview with Melissa Sabatier, Mine Action Program Manager, UNDP, 13 July 2009. The six TRGs were for: Demining (survey, marking, and clearance); Information Management; Mine Risk Education; Victim Assistance; Gender; and Monitoring and Evaluation.

សំណើរលើកដំបូងស្តីពីការពន្យាពេលដោះមីនអនុវត្តតាមមាត្រាទី៥របស់កម្ពុជា ដែលបានបញ្ជូននៅខែមេសា ឆ្នាំ២០០៩ បានទទួលស្គាល់នូវបញ្ហាក្នុងការធ្វើផែនការលំអិត នៅពេលដែលមិនមានទិន្នន័យច្បាស់លាស់លើបញ្ហាដីមានមីននៅសេសសល់។ ទោះយ៉ាងណា សំណើរនោះបានលើកឡើងនូវគំនិតផ្តួចផ្តើមមួយចំនួនដែលត្រូវពិនិត្យនិងបំពេញៈ[90]

- ការអង្កេតមូលដ្ឋាន ដែលចាប់ផ្តើមនៅខែ សីហា ឆ្នាំ ២០០៩ ដោយផ្តោតការយកចិត្តទុកដាក់លើស្រុកចំនួន ២១ ដែលរងគ្រោះខ្លាំង ដែលត្រូវបញ្ចប់នៅឆ្នាំ ២០១០ និងត្រូវបញ្ចប់ទូទាំងប្រទេសនៅត្រឹមឆ្នាំ ២០១២។
- ការបង្កើតបទដ្ឋានថ្នាក់ជាតិស្តីពីការដាក់ដីថាលែងមានមីន ( CMAS 15) ដែលចាត់ទុកថាជា "សកម្មភាពសំខាន់ " ដែលនឹងនាំអោយមានផលិតភាពកើតឡើង។
- ការដាក់បង្ហាញដីដែលគ្មានមីនតាមរយៈការដោះមីនដោយក្រុមប្រតិបត្តិករដែលនឹងប្រើធនធានភាគច្រើនរបស់ខ្លួនក្នុងស្រុករងគ្រោះខ្លាំងទាំង ២១ និងយកចិត្តទុកដាក់ "ជាខ្លាំងលើ" ការដោះមីនសម្រាប់តំបន់ដែលស្ថិតក្នុងក្រុម **ក** (តាមរយៈសំណើរសុំពន្យាពេលនោះ ដីប្រមាណ ៤៧០ គ.ម² នឹងត្រូវដោះមីនឱ្យអស់នៅត្រឹមឆ្នាំ ២០១៩ ដោយល្បឿនដោះ មីន ៤០ គ.ម² ក្នុង១ឆ្នាំ ចាប់ពីឆ្នាំ ២០១១ និងផលិតភាពដោះមីននឹងកើនឡើង ២០% ក្នុង១ឆ្នាំ ) និង
- ធ្វើពង្រាងយុទ្ធសាស្ត្រជាតិសកម្មភាពមីនគ្រប់វិស័យនិងលើកកំពស់ដំណើរការធ្វើផែនការ និងការដាក់តំបន់អាទិភាព។

អាជ្ញាធរមីនកម្ពុជា បានបោះពុម្ពផ្សាយយុទ្ធសាស្ត្រជាតិស្តីពីកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមនាខែ មករា ឆ្នាំ២០០៨ ដែលមានទស្សនៈវិស័យថាៈ " នៅត្រឹមឆ្នាំ២០១៥ ប្រទេសកម្ពុជានឹងក្លាយជាប្រទេសមួយដែលសំណល់ជាតិផ្ទុះសល់ពី សង្គ្រាមលែងជាការគម្រាមកំហែងបន្ទាន់ដល់ពលរដ្ឋស៊ីវិល (ការឆ្ពោះទៅរកការរងគ្រោះថ្នាក់មីនត្រឹមកម្រិតសូន្យ) និងជាកន្លែងដែលមានធនធានជាតិអាចរកបានសម្រាប់ដោះស្រាយបញ្ហាសេសសល់នៃផលប៉ះពាល់ដោយសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម តាមរយៈបណ្តាញរាយការណ៍ប្រកបដោយប្រសិទ្ធភាពនិងអន្តរគមន៍/បំផ្លាញចោលដោយសមស្របក្រោមការសម្របសម្រួល និងចាត់ចែងរបស់រដ្ឋាភិបាល "។[91] យុទ្ធសាស្ត្រស្តីពីសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមមិនត្រូវបានយកមកអនុវត្តឡើយ ប៉ុន្តែគេរំពឹងថានឹងដាក់បញ្ចូលជាផ្នែកមួយស្តីពី សំណល់ជាតិផ្ទុះសល់ពីសង្គ្រាមទៅក្នុងយុទ្ធសាស្ត្រជាតិសកម្មភាពមីនថ្មី។[92] យុទ្ធសាស្ត្រនោះបានផ្តល់អនុសាសន៍ថាកម្ពុជាគួរតែធ្វើសច្ចាប័នអនុស្សារណៈទី៥ នៃអនុសញ្ញាស្តីពីការប្រើប្រាស់អាវុធ ដែលនេះនឹងជម្រុញទឹកចិត្តកម្ពុជាអោយបោសសំអាតសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមអស់។[93]

យុទ្ធសាស្ត្រនោះបានកំណត់ឱ្យ CMAA ជាអាជ្ញាធរគ្រប់គ្រង និងធ្វើគោលនយោបាយសម្រាប់សកម្មភាពមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម។ គោលដៅរយៈពេលខ្លីរួមមានៈ

[90] Article 5 deadline Extension Request (Revision), 24 August 2009, pp. 53–54.
[91] CMAA, "National Strategy on Explosive Remnants of War," Phnom Penh, January 2008, p. 9.
[92] Telephone interview with Melissa Sabatier, UNDP, 13 July 2009.
[93] CMAA, "National Strategy on Explosive Remnants of War," Phnom Penh, January 2008, p. 12.

- បង្កើនសមត្ថភាពរបស់កងយោធពលខេមរភូមិន្ទក្នុងការធ្វើជា" ប្រតិបត្តិករជាតិស្តីពីសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម"
- បង្កើនសមត្ថភាពឆ្លើយតបដោះស្រាយបញ្ហារបស់ អង្គការស៊ីម៉ាក់ តាមរយៈការបង្កើនចំនួនក្រុមយុទ្ធភណ្ឌមិនទាន់ផ្ទុះ ពង្រឹងជំនាញ ដោយរួមទាំងការបំបែកជាក្រុមតូចៗ។
- សាកល្បង និងពង្រីកប្រព័ន្ធឆ្លើយតបដោយមានបញ្ចូលប៉ូលីស បណ្តាញសហគមន៍ និងក្រុមប្រតិបត្តិករ។
- កន្លែងរក្សាគ្រាប់រំសេវផ្ទុះដែលមានសុវត្ថិភាព និង
- កាត់បន្ថយចំនួនជនរងគ្រោះដោយសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមប្រចាំឆ្នាំមកត្រឹម១១៥នាក់នៅឆ្នាំ២០១០។[94]

នៅត្រឹមឆ្នាំ ២០១៥ យុទ្ធសាស្ត្រនោះបានស្នើរអោយៈ

- បង្កើត "មជ្ឈមណ្ឌលជាតិស្តីពីសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម" ជាកន្លែងផ្ទុកនូវឯកទេស និងជាមជ្ឈមណ្ឌលបណ្តុះបណ្តាល ដែលអាចលែងទទួលជំនួយពីបរទេស។
- មានសមត្ថភាពអន្តរាគមន៍ថ្នាក់ជាតិដែលផ្តល់ដោយកងយោធពលខេមរភូមិន្ទ" ដែលជាបញ្ហាអាទិភាពក្នុងការបោសសំអាតសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម សម្រាប់ហេដ្ឋារចនាសម្ពន្ធ័ជាតិធំៗ " និងតាមរយៈការកែទម្រង់អង្គការស៊ីម៉ាក់" ឱ្យផ្តោតការយកចិត្តទុកដាក់ឆ្លើយតបនឹងបញ្ហានៃសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ដោយស្ថាប័ននេះបានធ្វើសមាហរណកម្មទាំងស្រុងទៅក្នុងរដ្ឋាភិបាល និងប្រើប្រាស់ថវិកាជាតិ។"
- ទិន្នន័យកណ្តាលដែលមានទីតាំងនៅក្នុងអាជ្ញាធរមីនកម្ពុជា និង
- ការធានា និងគ្រប់គ្រងគុណភាពដោយអាជ្ញាធរមីនកម្ពុជា។[95]

### *ផែនការអប់រំពីគ្រោះថ្នាក់ដោយមីន*

យុទ្ធសាស្ត្រស្តីពីការអប់រំពីគ្រោះថ្នាក់មីនឆ្នាំ ២០០៦-២០១២ មានគោលដៅកាត់បន្ថយចំនួនអ្នកគ្រោះថ្នាក់តាមរយៈការផ្តល់អំណាចដល់សហគមន៍រងគ្រោះក្នុងការស្វែងរកវិធីសាស្ត្រកាត់បន្ថយ/អប់រំពីគ្រោះថ្នាក់ដោយមីនដែលមានប្រសិទ្ធភាព និងសមស្រប និងរួមបញ្ចូលការប្រឹងប្រែងទាំងនេះដែលនឹងមានសកម្មភាពអភិវឌ្ឍន៍ និងមនុស្សធម៌ដែលទូលំទូលាយជាងនេះរួមទាំងការផ្តល់ជំនួយដល់ជនរងគ្រោះដោយគ្រាប់មីន។[96]

### *ផែនការផ្តល់ជំនួយដល់ជនរងគ្រោះ*

ផែនការសកម្មភាពជាតិសម្រាប់ជនពិការ ដោយរួមទាំងអ្នករស់រានជីវិតរស់ពីគ្រាប់មីន/ សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ឆ្នាំ ២០០៩-២០១១ ជាផែនការផ្តល់ជំនួយដល់ជនរងគ្រោះរបស់កម្ពុជា។ ផែនការនេះបង្កើតឡើងជាផ្នែកមួយនៃការប្រឹងប្រែង

[94] Ibid, pp. 12–13.
[95] Ibid, pp. 13–14.
[96] See *Landmine Monitor Report 2008*, p. 217.

របស់កម្ពុជាចំពោះដំណើរការផ្តល់ជំនួយដល់ជនរងគ្រោះទាំង២៦ប្រទេស (សូមអានផ្នែកជំនួយដល់ជនរងគ្រោះខាងក្រោម)។ ដំណើរការពង្រាងនេះបានចាប់ផ្តើមនៅខែកក្កដា ឆ្នាំ២០០៧ នៅក្រោមការសម្របសម្រួលរបស់អ្នកពិគ្រោះយោបល់អន្តរជាតិ និង ក្រោយមកអ្នកសម្របសម្រួលជាតិក្នុងគម្រោងដែលគាំទ្រដោយភ្នាក់ជំនួយអន្តរជាតិប្រទេសអូស្ត្រាលី (AUSAID) តាមរយៈ កាកបាទក្រហមអូស្ត្រាលី (ARC) និងត្រូវបញ្ចប់នៅខែកុម្ភៈ ឆ្នាំ ២០០៩។ ផែនការនេះត្រូវបានអនុម័តដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និង CMAA នៅខែ មេសា ឆ្នាំ ២០០៩ និងលោកនាយករដ្ឋមន្ត្រីនៅខែ សីហា ឆ្នាំ២០០៩។[97] សម្រាប់ផែនការនេះ ត្រូវបានគេដាក់បង្ហាញលើកដំបូងផងដែរនៅឯកិច្ចប្រជុំលើកទី៩ របស់រដ្ឋសមាជិកនៅខែ វិច្ឆិកា ឆ្នាំ ២០០៨ គឺពីឆ្នាំ ២០០៨-២០១១។[98]

ផែនការនោះត្រូវបានបង្កើតឡើងដោយមានការពិភាក្សាយ៉ាងទូលំទូលាយជាមួយអ្នកពាក់ព័ន្ធ និងតាមរយៈការប្រជុំក្រុមគោលដៅ។ គោលដៅមួយក្នុងចំណោមគោលដៅចំបង៧នោះ គឺត្រូវពង្រឹងសមត្ថភាពក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ដោយធ្វើការផ្សាភ្ជាប់ជាមួយ " សកម្មភាពផ្ទាល់ និងកសាងទំនាក់ទំនងឬរឹងមាំ....ជាមួយអតិថិជនមិនថាគេជា អ្នកនៅមានជីវិតរស់ពីគ្រាប់មីន ឬ សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ឬ ជនពិការ ក្រុមតស៊ូមតិ ឬ ជាភ្នាក់ងារអនុវត្តអង្គការ មិនមែនរដ្ឋាភិបាលឡើយ"។[99] ផែនការនេះរួមមានទិសដៅនិងផែនការសម្រាប់ការប្រមូលទិន្នន័យ,ការថែទាំសុខភាព,ការស្តារនីតិសម្បទា,ការគាំទ្រផ្នែកចិត្តផ្លូវចិត្ត, សមាហរណកម្មសេដ្ឋកិច្ច, និងច្បាប់និងគោលនយោបាយសាធារណៈ ហើយផែនការនេះបាន រុញការទទួលខុសត្រូវទៅក្រសួងពាក់ព័ន្ធ។ ផែនការនេះមិនបានលើកឡើងពីតួនាទីរបស់ក្រុមប្រឹក្សាសកម្មភាពជនពិការ និង អាជ្ញាធរមីន បានច្បាស់លាស់ឡើយ។[100]

អ្នកពាក់ព័ន្ធដែលមិនមែនជាសមាជិករដ្ឋាភិបាលបានប៉ាន់ស្មានថាផែនការនោះមិនអំណោយផលដល់សកម្មភាពជាក់ស្តែង និងផែនការផ្សេងៗដោយមានភាពទូលំទូលាយខ្លាំងពេក មិនច្បាស់លាស់ និងកន្លែងខ្លះមិនជាក់ស្តែងជាពិសេសដោយសារតែកម្រិត នៃការទទួលខុសត្រូវអោយទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដែលសមត្ថភាពនៅមានកំណត់។[101]

ការតាមដានផែនការនេះនឹងត្រូវធ្វើឡើងតាមរយៈទស្សនៈកិច្ចទៅកាន់ក្រសួងពាក់ព័ន្ធនិងក្រុមប្រតិបត្តិករ។ ការប្រឹង ប្រែងនេះចាប់ផ្តើមនៅឆ្នាំ២០០៩ ដើម្បីបំពេញរបាយការណ៍ដែលបង្កើតដោយសហប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពីជំនួយ ដល់ជនរងគ្រោះ និងការធ្វើសមាហរណកម្មសង្គមសេដ្ឋកិច្ចសម្រាប់មហាសន្និបាទបូកសរុបការងារមីនលើកទី២។[102]

---

97 Notes from Steering Committee for Landmine Victim Assistance meeting, MoSVY, Phnom Penh, 10 April 2009.
98 Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2008−2011," November 2008.
99 Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 8.
100 Ibid.
101 Interviews with Josefina McAndrew, Country Representative, Volunteers International (VI), Phnom Penh, 6 April 2009; Bruno Leclercq, HI-B, Phnom Penh, 10 April 2009; Yann Drouet, Head of Physical Rehabilitation Project, ICRC, Phnom Penh, 7 April 2009; CDPO, Phnom Penh, 7 April 2009; UNICEF, Phnom Penh, 7 April 2009; and Sam Oeurn Pok, Managing Director, CWARS, Phnom Penh, 5 April 2009.
102 Email from Teresa Carney, ARC, 3 July 2009.

បន្ថែមលើផែនការជួយជនរងគ្រោះឆ្នាំ ២០០៩-២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា និងអ្នកផ្តល់សេវាកម្មស្តារនីតិសម្បទាអន្តរជាតិ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នានៅខែមិថុនា ឆ្នាំ២០០៨ ដែលដាក់ថាក្រសួងទទួលខុសត្រូវជាបន្តិចម្តងៗលើផ្នែកហិរញ្ញវត្ថុទាំងអស់ក្នុងផ្នែកសេវាកម្មនីតិសម្បទានៅឆ្នាំ ២០១១។[103]

អាជ្ញាធរមីនកម្ពុជាបានបង្ហាញពីចំណាប់អារម្មណ៍ចូលរួមធ្វើការលើផ្នែកជំនួយដល់ជនរងគ្រោះ ប៉ុន្តែបានលើកឡើងថាខ្លួនមិនមានធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ឡើយ។[104] នាយកដ្ឋានជំនួយជនរងគ្រោះដោយសារមីនរបស់អាជ្ញាធរមីនកម្ពុជាទទួលខុសត្រូវក្នុងការផ្តល់របាយការណ៍ជាប្រចាំលើការងារជួយដល់ជនរងគ្រោះ។ នៅឆ្នាំ២០០៧ ក្រុមប្រឹក្សាសកម្មភាពជនពិការត្រូវបានផ្ទេរឱ្យទទួលខុសត្រូវលើការចងក្រងរបាយការណ៍ប្រចាំឆ្នាំស្តីពីជំនួយដល់ជនរងគ្រោះដោយសារមីន។ របាយការណ៍បានរៀបចំសម្រាប់ឆ្នាំ២០០៧ ប៉ុន្តែវាមិនមានសម្រាប់ឆ្នាំផ្សេងទៀតឡើយ។ អាជ្ញាធរមីនកម្ពុជា បានលើកឡើងថានេះដោយសារតែកង្វះខាតទិន្នន័យ ដែលផ្តល់ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រុមប្រឹក្សាសកម្មភាពជនពិការ។[105]

*ការធ្វើសមាហរណកម្មសកម្មភាពមីនដោយមានការកែប្រែ និងអភិវឌ្ឍន៍*

"យុទ្ធសាស្ត្រចតុកោណ" របស់រដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវការងាររដ្ឋាភិបាលក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិក្នុងឆ្នាំ ២០០៤-២០០៨ ដោយដៅយកការអភិវឌ្ឍកសិកម្មជា "ចតុកោណទីមួយ" និងការដោះមីនជាផ្នែកមួយនៃការអភិវឌ្ឍវិស័យកសិកម្ម។[106] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ២០០៦-២០១០ ដោយផ្អែកទៅតាមយុទ្ធសាស្ត្រចតុកោណ យកការអភិវឌ្ឍជនបទជាអាទិភាពដែលជាវិធីមួយលឿនបំផុតក្នុងការកាត់បន្ថយភាពក្រីក្រនិងទទួលស្គាល់ថាការដោះមីនជា" ផ្នែកសំខាន់បំផុតក្នុងការធ្វើអោយដីដាំដុះមានសុវត្ថិភាពសម្រាប់ការដាំដុះ និងការពារការស្លាប់ និងពិការភាពមួយជីវិតដែលបណ្តាលមកពីរបួសធ្ងន់ធ្ងរ។" វារួមទាំងការដោះមីន ការលុបបំបាត់យុទ្ធភណ្ឌមិនទាន់ផ្ទុះ និងការជួយដល់ជនរងគ្រោះដោយគ្រាប់មីន នៅក្នុងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជាផងដែរ។[107] ទេសរដ្ឋមន្ត្រី ប្រាក់ សុខុន មានប្រសាសន៍នៅខែ កក្កដា ឆ្នាំ ២០០៩ ថា យុទ្ធសាស្ត្រជាតិសកម្មភាពមីន នឹងដើរស្របទៅតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ឆ្នាំ ២០០៩-២០១៣។[108]

ការសិក្សាមួយនៃ GICHD បានរាយការណ៍ថា "គឺមានកុងសង់ស៊ីសក្នុងចំណោមក្រសួង ស្ថាប័ននានា ដែលយល់ថាកម្មវិធីសកម្មភាពមីនគួរតែចាប់ផ្តើម "បញ្ជ្រាបចូល" ដោយខ្លួនឯង (ដូចជា ការប្រើប្រាស់ប្រពន្ធ័រដ្ឋ ដែលបង្កើតនៅថ្នាក់ជាតិ ខេត្ត និងឃុំសម្រាប់ការធ្វើផែនការដាក់អាទិភាព។ល។ ជាជាងការបង្កើតយន្តការ 'តែមួយ/ដោយឡែក' សម្រាប់សកម្មភាពមីន"។[109]

---

[103] See *Landmine Monitor Report 2008*, p. 223.
[104] Interview with Chum Bun Rong, CMAA, Phnom Penh, 6 April 2009.
[105] Interview with Chan Rotha, CMAA, Phnom Penh, 6 April 2009.
[106] "The Rectangular Strategy: Royal Government's Economic Policy Agenda," Council for the Development of Cambodia, www.cdc-crdb.gov.kh.
[107] "National Strategic Development Plan, 2006-10," Phnom Penh, undated but 2006, pp. 6, 20, 36.
[108] CMAA, "Minutes from Stakeholders' Workshop on a National Mine Action Strategy," Phnom Penh, undated but July 2009, p. 3.
[109] Ted Paterson, Chan Rotha, and Mao Vanna, "Toward a new mine action strategy for Cambodia," GICHD, Geneva, August 2008, p. i.

យន្តការជាក់ស្តែងសម្រាប់ការធ្វើសមាហរណកម្មសកម្មភាពមីន និងតម្រូវការសហគមន៍ដែលធំទូលាយជាងមុននោះគឺសំដៅលើអង្គភាពផែនការសកម្មភាពមីន (MAPUs), ទាំង៨ ដែលទទួលខុសត្រូវធ្វើផែនការ និងការដាក់អាទិភាពលើការដោះមីនតាមការណែនាំនៃអនុក្រឹត្យចេញនៅខែវិច្ឆិកាឆ្នាំ២០០៤ និងសេចក្តីណែនាំផ្នែកប្រតិបត្តិដែលអាជ្ញាធរមីនដាក់ចេញនៅខែកុម្ភៈឆ្នាំ២០០៧។[110] ការិយាល័យផែនការសកម្មភាពមីនធ្វើការជាមួយអាជ្ញាធរក្នុងតំបន់ដើម្បីកំណត់សហគមន៍អាទិភាព និងធ្វើការជាមួយប្រតិបត្តិករក្នុងការរៀបចំតារាងការងារប្រចាំឆ្នាំ ដែលត្រូវបានពិនិត្យនិងអនុម័តដោយក្រុមប្រឹក្សាសកម្មភាពមីនថ្នាក់ខេត្ត។ សកម្មភាពមីននៅតាមខេត្តដែលពុំមានការិយាល័យផែនការសកម្មភាពមីនត្រូវបានធ្វើការតាមការសម្របសម្រួលជាមួយអាជ្ញាធរខេត្ត។

ប្រតិបត្តិករបង្ហាញពីការគាំទ្រចំពោះប្រព័ន្ធ MAPU ដែលតាមរយៈប្រព័ន្ធនេះគេក៏បានស្នើរដាក់កំណត់ទីកន្លែងសម្រាប់ដោះមីន និងធ្វើការជ្រើសរើសការងារសម្រាប់ឆ្នាំបន្ទាប់ក្នុងកិច្ចពិភាក្សាជាមួយ MAPUs ។ ប៉ុន្តែពួកគេក៏បានសម្តែងការបារម្ភថាអង្គភាពទាំងនោះមិនមានធនធានគ្រប់គ្រាន់ ហើយគេបានលើកឡើងនូវលទ្ធភាពនៃនិរន្តភាពក្រោយពេលទទួលបានការគាំទ្របណ្តុះបណ្តាលពីអ្នកស្ម័គ្រចិត្តអន្តរជាតិប្រទេសអូស្ត្រាលីដែលត្រូវបញ្ចប់នៅពាក់កណ្តាលឆ្នាំ ២០០៨។[111]

អង្គការ HALO ក៏បានលើកឡើងថាភាពផ្ទុយគ្នារវាងគោលការណ៍ណែនាំឆ្នាំ ២០០៧ ដែលលើកឡើងថាការដោះមីនគួរកំណត់គោលដៅលើ "តំបន់ដែលរងគ្រោះខ្លាំងបំផុត" រីឯ MAPU យល់ថាផ្តោតការងារទៅលើការជ្រើសរើសតាមសណ្ឋាននៃផលប៉ះពាល់ផ្នែកសេដ្ឋកិច្ច-សង្គម។ អង្គការ HALO កត់សំគាល់ឃើញថាតំបន់ខ្សែក្រវ៉ាត់ **ក៥** ជាកន្លែងដែលមានមីនច្រើនបំផុត ប៉ុន្តែផ្នែកណាដែលនៅមិនជិតសហគមន៍ "កំពុងត្រូវបានដកចេញពីផែនការការងាររបស់ MAPU (បើទោះជាមានគ្រោះថ្នាក់កើតឡើងច្រើនក៏ដោយ) ដោយយកចិត្តទុកដាក់លើតំបន់ដែលមើលទៅមានប្រយោជន៍ក្រោយពេលដោះមីនរួចប៉ុណ្ណោះ។"[112]

គោលដៅអភិវឌ្ឍន៍សហវត្សរ៍របស់កម្ពុជា និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០០៦-២០១០ បានភ្ជាប់ការងារសកម្មភាពមីនទៅនឹងការកាត់បន្ថយភាពក្រីក្រ ហើយផែនការទាំងពីរគាំទ្រសកម្មភាពធ្វើសមាហរណកម្មអ្នកដែលមានជីវិតរស់ដោយគ្រាប់មីន/គ្រាប់ផ្ទុះដែលនៅសេសសល់ពីសង្គ្រាម។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក៏មានបំណងកាត់បន្ថយគ្រោះថ្នាក់ដោយគ្រាប់មីនមកត្រឹមកម្រិតសូន្យផងដែរនៅឆ្នាំ២០២០។ យ៉ាងណាក្តី ផែនការនេះមិនបាននិយាយអំពីសកម្មភាពឬផ្តោតទៅលើជនពិការ (រួមទាំងអ្នកនៅមានជីវិតរស់ពីគ្រាប់មីន) ឡើយ។[113]

---

[110] See *Landmine Monitor Report 2007*, p. 223.
[111] HALO, "Mine clearance in Cambodia–2009," January 2009, p. 9.
[112] HALO, "Mine clearance in Cambodia–2008," 2008, p. 9.
[113] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 6.

## ***ភាពម្ចាស់ការរបស់រដ្ឋាភិបាល***

*ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសកម្មភាពមីន និងជួយដល់ជនរងគ្រោះថ្នាក់មីន*

ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះសកម្មភាពមីនត្រូវបានឆ្លុះបញ្ចាំងដោយនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ដែលជាប្រធានរបស់អាជ្ញាធរមីនកម្ពុជា និងយោងទៅលើសកម្មភាពមីនដែលមាននៅក្នុងផែនការអភិវឌ្ឍន៍ជាតិ ។[114] របាយការណ៍អំពីតម្រូវឱ្យមានយុទ្ធសាស្ត្រសកម្មភាពមីនថ្មី ដែលលើកឡើងដោយ GICHD រកឃើញថា " មានការគាំទ្រយ៉ាងខ្លាំងរបស់អ្នកពាក់ព័ន្ធផ្នែកសកម្មភាពមីន និងស្ថាប័ន/ ក្រសួងរដ្ឋ ។" [115]

លទ្ធភាពរបស់រដ្ឋក្នុងការបំពេញការងារជួយដល់ជនរងគ្រោះដោយសារមីន/ជនពិការស្ថិតនៅ "ក្នុងភាពក្មេងខ្ចី" នេះបើតាមការសិក្សាវាយតំលៃរបស់អង្គការមិនមែនរដ្ឋាភិបាលមួយ ។[116] ការបំពេញតាមផែនការជួយជនរងគ្រោះ ២០០៩-២០១១ ពឹងទាំងស្រុងលើលទ្ធភាពឬសមត្ថភាពនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្នុងការដើរតួនាទីជាអ្នកដឹកនាំ។ អ្នកពាក់ព័ន្ធមើលឃើញថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានការចូលរួមច្រើនឡើង ប៉ុន្តែមានការព្រួយបារម្ភថា ពិការភាពនៅតែមិនមែនជាបញ្ហាអាទិភាព ។[117] គេក៏បានកត់សំគាល់ឃើញថា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់ និងមិនមានសបុគ្គលិកគ្រប់គ្រាន់។ ប៉ុន្តែក្រសួងមានទីប្រឹក្សាផ្នែកពិការភាព ដែលគាំទ្រដោយ AUSAID ហើយបានចាប់ផ្តើមធ្វើការងារនៅថ្ងៃទី ១ ខែ កក្កដា ឆ្នាំ ២០០៩។[118] ការចូលរួមរបស់ក្រសួងនានាក៏នៅមានកម្រិត ។[119]

ក្រុមប្រឹក្សាសកម្មភាពជនពិការ បានលើកឡើងថានៅខែឧសភា ឆ្នាំ ២០០៩ ថវិកាជាតិសម្រាប់ផ្នែកពិការភាពនៅមានកម្រិតទាបនៅឡើយ ហើយ " រចនាសម្ព័ន្ធនេះនៅខ្វះខាតធនធានមនុស្ស និងសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីឆ្លើយតបទៅនឹងតម្រូវការលើវិស័យពិការភាព ។"[120]

នៅឆ្នាំ ២០០៧-២០០៨ កាកបាតក្រហមអូស្ត្រាលី (ដែលទទួលមូលនិធិពី AusAID ) បានផ្តល់ការគាំទ្រយ៉ាងច្រើនដល់ការសម្របសម្រួលលើការប្រឹងប្រែងជួយជនរងគ្រោះដោយសារមីន/ជនពិការ ដើម្បីឱ្យមានយន្តការចូលរួមនិងសកម្មភាពឡើងវិញដែលមិនដំណើរការឱ្យស្ថិតក្រោមក្រុមប្រឹក្សាសកម្មភាពជនពិការ ។[121] អង្គការជនពិការអន្តរជាតិបារាំង និងអង្គការ

114 Statement by Senior Minister Prak Sokhonn, "Minutes from Stakeholders' Workshop on a National Mine Action Strategy," Phnom Penh, 6–7 July 2009.
115 Ted Paterson, Chan Rotha, and Mao Vanna, "Toward a new mine action strategy for Cambodia," GICHD, Geneva, August 2008, p. i.
116 Email from Teresa Carney, ARC, 3 July 2009.
117 Interviews with VI, Phnom Penh, 6 April 2009; HI-B, Phnom Penh, 10 April 2009; CDPO, Phnom Penh, 7 April 2009; UNICEF, Phnom Penh, 7 April 2009; CWARS, Phnom Penh, 5 April 2009; and Huoy Socheat, Director, AAR, Phnom Penh, 6 April 2009.
118 Email from Sheree Bailey, ISU, GICHD, 6 September 2009.
119 Interview with and email from Teresa Carney, ARC, Phnom Penh, 6 April and 3 July 2009.
120 Statement by Thong Vinal, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 26 May 2009.
121 DAC, "Annual Report 2007," Phnom Penh, 2008, pp. 11–22; Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 7; and *Landmine Monitor Report 2008*, p. 222.

ជនពិការអន្តរជាតិបែលហ្ស៊ិក ( HI-F និង HI-B) បានបន្តការគាំទ្រដល់ក្រុមប្រឹក្សាសកម្មភាពជនពិការ តាមរយៈគម្រោងផ្សេងៗនៅឆ្នាំ ២០០៨ ក្នុងការប្រឹងប្រែងរក្សាស្ថាប័នសម្របសម្រួលលើវិស័យពិការភាពមួយនេះ ។[122]

អ្នកពាក់ព័ន្ធទាំងអស់យល់ស្របថាការផ្តល់សេវាកម្មស្ទើរតែទាំងស្រុងធ្វើដោយអង្គការមិនមែនរដ្ឋាភិបាល និង អង្គការជនពិការហើយលក្ខណៈនេះនឹងមិនមានអ្វីផ្លាស់ប្តូរឡើយ ។ គេបានកត់សំគាល់ឃើញថាទោះបីជាក្រោយពេលបញ្ចប់ផែនការជំនួយជនរងគ្រោះដោយសារមីននៅឆ្នាំ២០១១ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងមិនមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ក្នុងការធ្វើការងារជួយជនរងគ្រោះដោយសារមីន/ជនពិការ ។[123] ប្រតិបត្តិករជាច្រើនលើកឡើងអំពីភាពនឿយណាយរបស់ម្ចាស់ជំនួយ និងការកើនឡើងនៃបញ្ហាថវិកា ដែលធ្វើអោយគេលំបាកក្នុងការរក្សាកម្រិតនៃប្រតិបត្តិការនៅកម្ពុជា ក្នុងរយៈពេលមធ្យមនិងវែង ។[124] សំខាន់ដូចគ្នានេះដែរ គេបារម្ភលើការប្រែប្រួល និងនិរន្តរភាពនៃក្រុមសកម្មភាពជនពិការ ដែលពឹងផ្អែកលើថវិកាពីខាងក្រៅទាំងស្រុង លុះត្រាតែមានការកើនឡើងនៃការរួមចំណែកពីថវិកាជាតិ ។[125]

*ការគ្រប់គ្រងសកម្មភាពមីនជាតិ*

អាជ្ញាធរមីនកម្ពុជា ដែលបានការគាំទ្រពីភ្នាក់ងារអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) និងបានធ្វើការយ៉ាងជិតស្និទជាមួយអ្នកពាក់ព័ន្ធ ជាការស្ថាប័នបង្គោលសម្រាប់សកម្មភាពមីន និងការបង្កើតយុទ្ធសាស្រ្តជាតិស្តីពីសកម្មភាពមីន ។ អត្ថបទគោលគំនិតមួយដែលផ្សព្វផ្សាយនៅខែមិថុនា ឆ្នាំ២០០៩ បាននិយាយថាយុទ្ធសាស្រ្តជាតិស្តីពីសកម្មភាពមីនគួរដាក់បញ្ចូល" វិធានការជាក់លាក់ក្នុងការលើកកំពស់ភាពម្ចាស់ការរបស់រដ្ឋាភិបាល និងលទ្ធភាពដោះស្រាយបញ្ហាមីន /សំណល់ជាតិផ្ទុះសល់ពីសង្រ្គាមរបស់កម្ពុជាក្នុងរយៈពេលយូរ ។" [126]

*បញ្ញត្តិទាក់ទងនឹងសកម្មភាពមីនជាតិ*

ព្រះរាជក្រិត្យចុះថ្ងៃទី ៤ ខែ កញ្ញា ឆ្នាំ ២០០០ និងអនុក្រិត្យចុះថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០១ លើកឡើងពីតួនាទី និងការទទួលខុសត្រូវរបស់អាជ្ញាធរមីនកម្ពុជា ។ អនុក្រិត្យឆ្នាំ ២០០១ក៏បានបញ្ជាក់អំពីតួនាទីរបស់អង្គការស៊ីម៉ាក់ ថាជាអ្នកផ្តល់សេវាកម្ម ។[127]

*បទដ្ឋានសកម្មភាពមីនជាតិ/នីតិវិធីប្រតិបត្តិអចិន្រ្តៃយ៍*

អាជ្ញាធរមីនកម្ពុជា បានពង្រាងបទដ្ឋានសកម្មភាពមីនកម្ពុជាចំនួន ២៩ ជំពូក ដែលក្នុងនោះ ៥ ជំពូកដំបូងបានចូលជាធរមាននៅខែសីហា ឆ្នាំ ២០០៦ ដែលនិយាយអំពីការទទួលស្គាល់គុណភាព និងការផ្តល់អាជ្ញាប័ណ្ណ ការតាមដានស្ថាប័នដោះមីន ការរក្សាទុក ការដឹកជញ្ជូន និងការប៉ះពាល់គ្រឿងផ្ទុះ និងការរាយការណ៍អំពីករណីផ្ទុះមីន ។ ៦ ជំពូកទៀត និយាយបញ្ហាផ្សេងៗ ដែលរួមមានបទដ្ឋានសម្រាប់ការដោះមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ ត្រូវបានអនុម័ត និងចូលជាធរមាននៅខែកុម្ភៈ ឆ្នាំ ២០០៧ ។

[122] Email from Marie-Pierre Guicherd, South East Asia Desk Officer, HI-F, 4 September 2009.
[123] Interview with Teresa Carney, ARC, Phnom Penh, 6 April 2009.
[124] Interviews with HI-B, Phnom Penh, 10 April 2009; UNICEF, Phnom Penh, 7 April 2007; VI, Phnom Penh, 6 April 2009; and CWARS, Phnom Penh, 5 April 2009.
[125] Interviews ARC, Phnom Penh, 6 April 2009; and UNICEF, Phnom Penh, 7 April 2009.
[126] CMAA, "Plan for the Development of a National Mine Action Strategy," undated but June 2009, p.2.
[127] For details of legislation regarding the CMAA and CMAC, see GICHD, "A Study of the Development of Mine Action Legislation," Geneva, 2004, pp. 64–66.

គិតត្រឹមខែ មេសា ឆ្នាំ ២០០៩ ពីរជំពូកនិយាយអំពីការកំណត់ និងការស្រាវជ្រាវចំការមីនមូលដ្ឋាន ត្រូវបានអនុម័តសម្រាប់ការងារបច្ចុប្បន្ន។ មួយជំពូកនិយាយអំពីការដោះមីនដោយម៉ាស៊ីនកំពុងរង់ចាំការអនុម័ត រីឯ ១៥ ជំពូកទៀតស្ថិតក្នុងលក្ខណៈពង្រាងនៅឡើយ។[128] នៅឆ្នាំ២០០៩ គេបានចាប់ផ្តើមធ្វើការលើពង្រាងបទដ្ឋានសម្រាប់ដីដោះមីនរួចសម្រាប់ប្រើប្រាស់។[129] គេមានពង្រាងបទដ្ឋានជាតិសម្រាប់ការអប់រំពីគ្រោះថ្នាក់មីន ប៉ុន្តែមកដល់ខែមេសា ឆ្នាំ២០០៩ បទដ្ឋាននេះនៅមិនទាន់បញ្ចប់នៅឡើយ។[130]

## ការដោះមីន និងការបោសសំអាតមីនក្នុងតំបន់ជម្លោះ

ការដោះមីនត្រូវបានធ្វើឡើងដោយអង្គការចំនួនបី គឺមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ស៊ីម៉ាក់ (CMAC), អង្គការ HALO និងអង្គការ MAG ដែលធ្វើប្រតិបត្តិការនៅកម្ពុជាតាំងពីទសវត្សរ៍ឆ្នាំ៩០មកម្លេះ។ អាជ្ញាធរមីនកម្ពុជា ចាប់ផ្តើមបានផ្តល់អាជ្ញាប័ណ្ណដល់អង្គភាពប្រតិបត្តិការដោះមីននៅឆ្នាំ២០០៦ និងទទួលស្គាល់ប្រតិបត្តិករទាំងបី នាខែតុលា ឆ្នាំ២០០៦។ ឆ្នាំ២០០៧ អង្គការស៊ីម៉ាក់ បានចាប់ផ្តើមប្រតិបត្តិការដោះមីន ឱ្យក្រុមហ៊ុនរុករករ៉ែប្រទេសអូស្ត្រាលីហៅថា BHP Billiton ដែលបានធ្វើការចុះរុករកពពួករ៉ែបុកស៊ីតនៅតំបន់ភាគឦសាន នៃខេត្តមណ្ឌលគិរី នៅខែមេសា ឆ្នាំ២០០៩ មជ្ឈមណ្ឌលស៊ីម៉ាក់បានរាយការណ៍ថា គេបានបញ្ចប់ជាស្ថាពរនូវកិច្ចសន្យារបស់គេ ហើយគ្រាប់មីននៅតំបន់ដែលខ្លួនបានចុះប្រតិបត្តិការនោះត្រូវបានបោសសំអាតទាំងស្រុង។[131]

អាជ្ញាធរមីនកម្ពុជា ក៏បានទទួលស្គាល់ផងដែរនូវក្រុមហ៊ុនដោះមីនអន្តរជាតិចំនួនបីគឺ BACTEC, Milsearch (International), Phoenix PCL និងក្រុមហ៊ុនកម្ពុជាមួយគឺក្រុមហ៊ុនសេវាកម្មដោះមីននៅកម្ពុជា (Cambodian Demining Service)។[132] ក្រុមហ៊ុន BACTEC ផ្តល់នូវការគាំទ្រជាចំបងទៅដល់ក្រុមហ៊ុនរុករក រ៉ែ។[133]

រហូតមកដល់ខែកក្កដា ឆ្នាំ២០០៩ កងយោធពលខេមរភូមិន្ទ (RCAF) នៅមិនទាន់បានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណទទួលស្គាល់គុណភាពនៅឡើយទេ ប៉ុន្តែដោយមានការគាំទ្រពីលោកនាយករដ្ឋមន្ត្រី កងយោធពលខេមរភូមិន្ទបានធ្វើប្រតិបត្តិការដោះមីនក្នុងនាមអោយក្រសួងនានាក្នុងរដ្ឋាភិបាលដោយក្រោមការគាំទ្រជាចំបងនៃគំរោងស្តារហេដ្ឋារចនាសម្ព័ន្ធ។[134] កិច្ចពិភាក្សាត្រូវបានគេធ្វើឡើងជាមួយអាជ្ញាធរមីនកម្ពុជា ស្តីពីការទទួលស្គាល់ជាផ្លូវការដែលយ៉ាងហោចណាស់ក៏មានវិស្វករដោះមីនខ្លះនៃកងយោធពលខេមរភូមិន្ទដែរ។ សំណើរសុំពន្យាពេលដោះមីនតាមមាត្រាទី៥ នៃសន្ធិសញ្ញាហាមប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ជាលើកដំបូងរបស់កម្ពុជា បានព្យាករណ៍ថាកងយោធពលខេមរភូមិន្ទធ្វើការបោសសំអាតមីនបានជាង ១ភាគ៣ នៃ

---

128 Article 5 deadline Extension Request, 30 April 2009, Annex 5, p. 73; and see *Landmine Monitor Report 2008*, p. 208.

129 Telephone interview with Melissa Sabatier, UNDP, 13 July 2009.

130 Interview with Oum Sang Onn, CMAC, in Geneva, 28 April 2009.

131 Nguon Sovann, "Demining completed for BHP," *Phnom Penh Post*, 2 April 2009, www.phnompenhpost.com.

132 CMAA, "Mine Action Achievements Report 2007 and Work Plan 2008," p. 8, received by email from Tong Try, Project Officer, CMAA, 18 August 2008, p. 8. The CMAA reported that of the four companies only BACTEC was active.

133 Interview with Burt Kearney, General Manager, Asia, BACTEC, Phnom Penh, 30 April 2008.

134 See *Landmine Monitor Report 2007*, p. 221.

ផ្ទៃដីដែលនៅសល់មានគ្រាប់មីន ប៉ុន្តែសំណើរដែលបានកែប្រែបានកាត់បន្ថយការព្យាករណ៍នោះ។ ទោះបីជាយ៉ាងណាក៏ដោយ សំណើរនោះបានសរសេរថា ការទទួលស្គាល់គុណភាពដោះមីនរបស់កងយោធពលខេមរភូមិន្ទនឹងធ្វើឱ្យមានការរួមចំណែកដ៏សំខាន់មួយក្នុងការបង្កើនទូវផលិតភាពការងារដោះមីន ដូចជា “ត្រូវបានគេមើលឃើញថាជាអាទិភាពដ៏សំខាន់សំរាប់អាជ្ញាធរមីនកម្ពុជា។” សំណើរនោះរួមមានការទទួលស្គាល់គុណភាពការងារដោះមីនរបស់កងយោធពលខេមរភូមិន្ទ ជាគោលដៅសំខាន់ដែលនឹងត្រូវសំរេចអោយបាននៅក្នុងឆ្នាំ២០០៩។[135]

វិស្វកររបស់កងយោធពលខេមរភូមិន្ទ ក៏បានចូលរួមក្នុងប្រតិបត្តិការដោះមីនក្នុងបេសកម្មអង្គការសហប្រជាជាតិនៅក្នុងប្រទេសស៊ូដង់ចាប់តាំងពីឆ្នាំ២០០៦មកម្ល៉េះដោយធ្វើការផ្លាស់ក្រុមគ្នាជារៀងរាល់ឆ្នាំ។[136] ក្រុមទីបីដែលមានវិស្វករចូលរួមត្រូវបានបញ្ជូនទៅនៅខែមិថុនាឆ្នាំ២០០៨[137] និងក្រុមទីបួនដែលមានអ្នកជំនាញដោះមីនចំនួន៩២នាក់ត្រូវបានគ្រោងនឹងបញ្ជូនទៅប្រទេសស៊ូដង់នៅខែមិថុនាឆ្នាំ២០០៩។[138] កម្ពុជាក៏បានប្រកាសនៅខែមីនាឆ្នាំ២០០៩ផងដែរថា ខ្លួននឹងបញ្ជូនកងទ័ពទៅប្រទេស Chad និងសាធារណរដ្ឋអាហ្វ្រិកកណ្តាល (Central African Republic) ដើម្បីជួយដោះមីនក្រោមការគាំទ្រពីអង្គការសហប្រជាជាតិផ្នែកប្រតិបត្តិការរក្សាសន្តិភាពផងដែរ។[139]

***ការកំណត់តំបន់ដែលមានគ្រោះថ្នាក់មីនច្រើន***

ដូចគ្នានឹងការរៀបចំសំណើក្នុងមាត្រាទី៥ដែរ អាជ្ញាធរមីនកម្ពុជា (CMAA) និងក្រុមអ្នកចុះប្រតិបត្តិការបានទទួលស្គាល់នូវតំរូវការស្រាវជ្រាវចំការមីនមូលដ្ឋាន ដើម្បីផ្តល់នូវទិន្នន័យអោយកាន់តែអាចទុកចិត្តបាន ដើម្បីកំណត់នូវទំហំប៉ះពាល់ដោយគ្រាប់មីនដែលនៅសល់ និងការបង្កគ្រោះថ្នាក់ដោយសារសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម និងធ្វើការរៀបចំអាទិភាពដីសំរាប់ដោះមីន។ សំណើដែលបានគូសបញ្ជាក់នោះគ្រោងនឹងធ្វើការស្រាវជ្រាវជាពីរដំណាក់កាល។ ដំណាក់កាលទី១គឺគ្របដណ្តប់លើ២១ស្រុក ដែលមានចំនួន៩៣ភាគរយនៃចំនួនអ្នកស្លាប់និងរងរបួសដោយសារគ្រាប់មីនកំឡុងពេល៥ឆ្នាំមុន។ ការស្រាវជ្រាវដំណាក់កាលទីមួយចាប់ផ្តើមនៅខែសីហាឆ្នាំ២០០៩ ហើយគ្រោងនឹងចំណាយរយៈពេល១ឆ្នាំដើម្បីបញ្ចប់។[140] ដំណាក់កាលទីពីរគ្របដណ្តប់លើតំបន់ដែលនៅសល់ដែលនឹងបញ្ចប់នៅឆ្នាំ២០១២។ ប្រតិបត្តិករដោះមីនបានយល់ស្របទៅនឹងលទ្ធផលនៃការស្រាវជ្រាវដែលនឹងជំនួសការព្យាករណ៍ពីពេលមុនតាមការស្រាវជ្រាវពីផលប៉ះពាល់របស់គ្រាប់មីនកម្រិត១ (LIS)។[141]

---

[135] Telephone interview with Melissa Sabatier, UNDP, 13 July 2009; Article 5 deadline Extension Request, 30 April 2009, pp. 59–60; and Article 5 deadline Extension Request (Revision) 24 August 2009, p. 54.
[136] See *Landmine Monitor Report 2008*, p. 211.
[137] “2nd batch of Cambodian deminers return from UN peacekeeping missions in Sudan,” *Xinhua* (Phnom Penh), 10 June 2008, news.xinhuanet.com.
[138] “Cambodia to send fresh soldiers for de-mining operation,” *Sudan Tribune,* 22 May 2009, www.sudantribune.com.
[139] Associated Press, “Cambodian troops for Africa,” *Straits Times*, 24 March 2009, www.straitstimes.com; and CMAA, “Minutes from Stakeholders’ Workshop on a National Mine Action Strategy,” undated but July 2009.
[140] Article 5 deadline Extension Request (Revision), 24 August 2009, p. 6.
[141] Article 5 deadline Extension Request, 30 April 2009, pp. 55–56.

មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា គ្រោងនឹងធ្វើការស្រាជ្រាវមូលដ្ឋានលើដីមានមីនដែលមានចំនួន១៣ក្រុមសំរាប់១៣ស្រុក អង្គការ HALO មាន៦ក្រុមសំរាប់៦ស្រុក និងអង្គការ MAG មាន២ក្រុម សំរាប់២ ស្រុក។[142]

ការស្រាវជ្រាវមូលដ្ឋាននេះត្រូវបានគេយល់ឃើញថាជាឱកាសដ៏សំខាន់មួយដើម្បីអោយដឹងទិន្នន័យខ្វះខាតដែលមានស្ដីពីគ្រោះថ្នាក់មីននិងប្រតិបត្តិការដោះមីន និងបង្ហាញពីកម្រងទិន្នន័យសុីគ្នាដំបូងចាប់តាំងពីមានការចាប់ផ្តើមសកម្មភាពដោះមីននៅកម្ពុជា( មើលផ្នែកការប្រមូលនឹងគ្រប់គ្រងទិន្នន័យខាងលើ) ។ អាជ្ញាធរមីនកម្ពុជានិងប្រតិបត្តិករដោះមីន បានរៀបចំត្រួសត្រាយផ្លូវសម្រាប់ការស្រាវជ្រាវដោយយល់ព្រមទៅនឹងបទដ្ឋានប្រតិបត្តិការអចិន្ត្រៃយ៍, ទំរង់របាយការណ៍ស្រាវជ្រាវ និងប្រពន្ធ័ចំណាត់ថ្នាក់ដីដែលរងការប៉ះពាល់និងសង្ស័យដោយមានការយល់ព្រមពីអាជ្ញាធរមីនកម្ពុជានិងប្រតិបត្តិករដោះមីន។[143] ទាំងអស់នេះបានផ្តល់នូវគោលនយោបាយសំរាប់គំរោងនិងអាទិភាពជាយុទ្ធសាស្ត្រ និងសំរាប់ដំណើរការបញ្ចេញ និងធ្វើចំណាត់ថ្នាក់ប្រភេទដីថាមានមីនឬគ្មានមីន។[144] ប្រតិបត្តិករបានចាប់ផ្តើមធ្វើការស្រាវជ្រាវសាកល្បងចុះដល់ការដ្ឋាន ដើម្បីធ្វើតេស្តនូវវិធីសាស្ត្រស្រាវជ្រាវនៅថ្ងៃទី៦ខែកក្កដា ឆ្នាំ២០០៩។[145]

យោងតាមការធ្វើចំណាត់ថ្នាក់ ដីនឹងត្រូវបានចាត់ថ្នាក់ជា :

- *តំបន់ដែលមានមីន* រួមមានដីដែលហាប់ណែនប្រមូលផ្តុំដោយគ្រាប់មីនប្រឆាំងមនុស្ស (A1). ដីលាយឡំគ្នាទាំងគ្រាប់មីនប្រឆាំងមនុស្សនិងគ្រាប់មីនប្រឆាំងនឹងយានយន្ត (A2), ដីត្រឹមតែគ្រាប់មីនប្រឆាំងយានយន្ត (A3), ឬក៏ដីមានគ្រាប់មីនរាយប៉ាយ ឬក៏បង្កអសន្តិសុខដល់មនុស្ស (A4) ។
- *ការគំរាមកំហែងពីកាកសំណល់គ្រាប់ដែលបន្សល់ទុក* រួមមានសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម (B1) ឬក៏ដីដែលគ្មានការពិនិត្យត្រឹមត្រូវថាមានគ្រាប់មីនឬអត់ (B2) ឬក៏
- *សភាពចុងក្រោយ* រួមមានដីប្រកាសថាអាចប្រើប្រាស់បានសំរាប់ធ្វើការបង្កបង្កើនផលក្នុងរយៈពេលបីឆ្នាំ ឬច្រើនជាងនេះដោយគ្មានគ្រោះថ្នាក់ឬក៏ភស្តុតាងបង្ហាញថាគ្មានគ្រោះថ្នាក់ ឬមានគ្រាប់មីន (C1), ដីដាក់ឱ្យប្រើប្រាស់ដោយការអង្កេត (C2), ដីដែលបានបោសសំអាតមីនរួច (C3) និង"ដីគ្មានមីន" (គ្មានការចង្អុលបង្ហាញពីសហគមន៍មូលដ្ឋាន ឬការស្រាវជ្រាវពីមុនមក) (C4) ។

រូបមន្តនេះត្រូវការយកចិត្តទុកដាក់ដល់ឧបករណ៍បោសសំអាតមីនលើដីដែលចាត់ចំណាត់ថ្នាក់ដូចជា A1ឬA2 និងមានការអង្កេតបន្ថែមនៃដីប្រភេទ A3 និង A4 ថែមទៀតមុនពេលធ្វើការដាក់ពង្រាយក្រុមបោសសំអាត។ រូបមន្តបានសរសេរថា ឧបករណ៍បោសសំអាតមីនគួរតែពង្រាយទៅដីចំណាត់ថ្នាក់ B ដែលមានតំរូវការពីសហគមន៍ និងមិនគួរដាក់ពង្រាយទៅដីក្នុងចំណាត់ថ្នាក់ Cឡើយ។[146]

---

[142] Email from Melissa Sabatier, UNDP, 15 July 2009.
[143] Article 5 deadline Extension Request, 30 April 2009, p. 46.
[144] Ibid, pp. 55–56.
[145] Telephone interview with Melissa Sabatier, UNDP, 13 July 2009.
[146] Article 5 deadline Extension Request, 30 April 2009, Annex 4, p. 72.

## ការបោសសំអាតមីន

ប្រតិបត្តិការដោះមីនបានបន្តដោះមីននៅក្នុងឆ្នាំ២០០៨ បានដីប្រហាក់ប្រហែលគ្នានឹងឆ្នាំមុនៗ បង្កើននូវការបោសសំអាតតាមតំបន់ដែលមានគ្រាប់មីនប្រហែល៤%លើសឆ្នាំ២០០៧ ទោះបីជាចំនួនគ្រឿងផ្ទុះដែលបានបោសសំអាតទាបជាងក៏ដោយ។ បរិមាណដីដែលបានកាត់បន្ថយ ឬលុបចោលក៏បានធ្លាក់ចុះដល់ ៤៨២ គ.ម$^{២}$ នៅឆ្នាំ២០០៨ ពី ៩៥៧ គ.ម$^{២}$ នៅឆ្នាំមុនផងដែរ។[147]

ការពិភាក្សាបានបន្តក្នុងចំណោមប្រតិបត្តិករ អង្គភាពផែនការសកម្មភាពមីន(MAPUs)និងភាគីពាក់ព័ន្ធផ្សេងទៀតថាតើការបោសសំអាតគួរតែផ្តោតទៅលើដីដែលមានគ្រាប់មីនច្រើនជាងគេឬកិច្ចការគាំទ្រសហគមន៍និងអភិវឌ្ឍន៍ជាអាទិភាព។[148] ភាពតានតឹងរវាងថៃ និងកម្ពុជាបាននាំអោយមានការរំខានក្នុងការដោះស្រាយបញ្ហាព្រំដែន។ នៅឆ្នាំ២០០៩ លោកទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** បានថ្លែងថាអាជ្ញាធរមីនកម្ពុជានិងក្រសួងការពារជាតិបានយល់ព្រមថា គ្មានការបញ្ជាណាមួយដើម្បីឱ្យផ្អាកសកម្មភាពដោះមីននៅតាមព្រំដែននោះទេ តំបន់ព្រំដែននៅមិនទាន់បានកំណត់ច្បាស់ ប្រតិបត្តិការដោះមីនតំរូវឱ្យមានការយល់ព្រមពីគណៈកម្មការព្រំដែនចម្រុះរួមនៃប្រទេសទាំងពីរ និងការដោះមីនគួរតែផ្តោតលើតំបន់អាទិភាពផ្សេងៗទៀតជាជាងតំបន់ដែលកំពុងមានជម្លោះ។[149]

មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ដែលមានបុគ្គលិក២៤០០នាក់ បានធ្វើសេចក្តីរាយការណ៍ពីទំហំដីដោះមីនរួចដែលជាគោលដៅជិត៣០គ.ម$^{២}$ នៅឆ្នាំ២០០៨ ហើយតួរលេខនេះជាលទ្ធផលចំបងនៃអ្នកជំនាញដោះមីន៦៥០នាក់ ដែលបានទទួលការហ្វឹកហ្វឺនជាច្រើនមុខជំនាញ ដោយរួមមានក្រុមកំទេចគ្រឿងផ្ទុះ ការបោសសំអាតតំបន់មានសង្គ្រាម ការគូសផែនទីនិងការគ្រប់គ្រងតំបន់ដែលមានមីន។ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា រំពឹងថា ការបណ្តុះបណ្តាលដើម្បីបង្កើនផលិតភាព ហើយក្នុងឆ្នាំ២០០៩ គោលដៅបោសសំអាតមីនបានផ្ទៃដី ៣៥.១គ.ម$^{២}$។ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ក៏បានធ្វើការជាមួយអង្គការជំនួយប្រជាជនន័រវេ (NPA) ដើម្បីធ្វើការស្រាវជ្រាវបែបបច្ចេកទេស និង ពិធីសារដាក់ដីឱ្យប្រើប្រាស់ក្រោយដោះមីនរួចក្នុងគោលបំណងបំពេញតាមបទដ្ឋានអន្តរជាតិ និង បង្កើនអត្រានៃការផ្តល់ដីប្រើប្រាស់ដែលក្រោយបោសសំអាតរួចផងដែរ។ GICHD ក៏បានផ្តល់ជំនួយផ្នែកស្រាវជ្រាវបែបបច្ចេកទេស និងការដាក់ដីឱ្យប្រើប្រាស់ក្រោយដោះមីនរួចផងដែរ។[150] នៅឆ្នាំ២០០៩ GICHD បានរៀបចំផែនការយុទ្ធសាស្ត្រ៥ឆ្នាំរបស់ខ្លួន (២០០៩-២០១៣) ស្របគ្នានឹងការជាប់ពាក់ព័ន្ធរបស់ខ្លួនក្នុងការពិភាក្សាលើសំណើរពន្យាពេលដោះមីនតាមមាត្រាទី៥ និងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនថ្មី (NMAS)។[151]

មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា បានបានបង្កើតក្រុមបោសសំអាតមីនតាមតំបន់មានជម្លោះចំនួន៨ក្រុមនៅឆ្នាំ២០០៧ សំរាប់កុងត្រាឱ្យក្រុមហ៊ុន BHP Billiton របស់ខ្លួន។ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ក៏បានមើលឃើញនូវតួនាទីរយៈ

[147] See *Landmine Monitor Report 2008*, p. 213.
[148] Interviews with operators, Phnom Penh and Siem Reap, 30 March–1 April 2009.
[149] CMAA, "Minutes from Stakeholders' Workshop on a National Mine Action Strategy," Phnom Penh, undated but July 2009.
[150] Email from Pascal Rapillard, GICHD, 4 September 2009.
[151] CMAC, "Integrated Work Plan 2009," Phnom Penh, undated but 2009, pp. 6, 9–13.

ពេលវែងក្នុងការដោះស្រាយបញ្ហាគ្រោះថ្នាក់ដោយសារកាកសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមថាជាការអភិវឌ្ឍន៍សេដ្ឋកិច្ច និងត្រូវការពង្រីកផ្ទៃដីចូលក្នុងតំបន់ដែលរងការប៉ះពាល់ជាចំបងដោយសំណល់ជាតិផ្ទុះសល់ពីសម័យសង្គ្រាម និងដើម្បីឆ្លើយតបទៅនឹងលទ្ធផលការយកចិត្តទុកដាក់ខ្លាំងក្លានៃអន្តរជាតិពីអនុសញ្ញាគ្រាប់បែកចង្កោម។ នៅឆ្នាំ២០០៨មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា បានផ្លាស់ប្តូរក្រុមអ្នកដោះមីនពីព្រំដែនភាគខាងលិចជាមួយថៃទៅកម្ពុជាភាគខាងកើត ដើម្បីឆ្លើយតបទៅនឹងចំណាប់អារម្មណ៍របស់សហរដ្ឋអាមេរិច នៅក្នុងការផ្តល់មូលនិធិបោសសំអាតមីន សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម ដែលជាលទ្ធផលនៃការទំលាក់គ្រាប់បែករបស់សហរដ្ឋអាមេរិចនៅទសវត្សរ៍ឆ្នាំ៧០។[152]

អង្គការ HALO ដែលមានបុគ្គលិកអន្តរជាតិ៥នាក់ និងបុគ្គលិកជាតិ១២០០នាក់ បានចុះប្រតិបត្តិការបោសសំអាតមីនដែលមានគ្នា៨នាក់ចំនួន១០០ក្រុម ដែលរួមមានក្រុមសំអាតដោយប្រើម៉ាស៊ីន២ក្រុម ក្រុមកំទេចគ្រឿងផ្ទុះ(EOD) ៣ក្រុម និងក្រុមស្រាវជ្រាវ៨ក្រុម។ អង្គការ HALO បានផ្តោតការប្រតិបត្តិការនៅតំបន់ជិតព្រំដែនកម្ពុជាថៃ ដែលផ្តោតសំខាន់លើគ្រាប់មីន រួមមានផ្នែកនានានៃខ្សែក្រវ៉ាត់មីន**ក៥**[153] ហើយទទួលបានច្រើនជាងពាក់កណ្តាល (៥៤%) នៃចំនួនសរុបគ្រាប់មីនប្រឆាំងមនុស្សដែលបានសំអាតរួចនៅឆ្នាំ២០០៨(សូមមើលតារាងខាងក្រោម)។ ផលិតភាពការងារបានជំនួយពីការប្រើប្រាស់ឧបករណ៍រាវមីនឈ្មោះ HSTAMID ដែលបានកាត់បន្ថយនូវសញ្ញាសម្រាប់ការអង្កេត និងបច្ចុប្បន្នត្រូវបានប្រើប្រាស់ដោយក្រុមបោសសំអាតរបស់ខ្លួនចំនួន២០ផ្នែក។[154]

អង្គការ MAG បានបន្តប្រតិបត្តិការនៅភាគពាយ័ព្យនៃប្រទេសកម្ពុជាដែលមានបុគ្គលិកប្រមាណ៥០០នាក់ ដោយដាក់ពង្រាយក្រុមបោសសំអាតដោយដៃចំនួន២១ក្រុម, ក្រុមឆ្កែហិតមីន៣ក្រុម, ក្រុមស្រាវជ្រាវបែបបច្ចេកទេស១ក្រុម ក្រុមទំនាក់ទំនងសហគមន៍៧ក្រុម,ក្រុមកាប់គុម្ពោតព្រៃ៣ក្រុម,ក្រុមគូសផែនទី៦ក្រុម, និងក្រុមស្រាវជ្រាវរុករកនិងអភិវឌ្ឍន៍៣ក្រុម។ អង្គការ MAG បានបង្កើនចំនួនក្រុមកំទេចគ្រឿងផ្ទុះពី៥ទៅ៧ក្រុម ដោយឆ្លុះបញ្ចាំងពីតំរូវការប្រមូលនូវយុទ្ធភណ្ឌពីអ្នកភូមិ។ ប្រតិបត្តិការដោះមីនបានទទួលនូវផលប្រយោជន៍ពីការប្រើប្រាស់នូវឧបករណ៍កាត់គុម្ពោតព្រៃបានទូលំទូលាយជាងមុន និងមនុស្ស២ក្រុម ប្រើប្រាស់ឧបករណ៍រុករកគ្រាប់មីនឈ្មោះ HSTAMIDS។ អង្គការ MAG ក៏បានវិនិយោគទៅលើឧបករណ៍រុករកគ្រាប់មីនថ្មី១បន្ទាប់ពីបានជួបប្រទះការលំបាកជាមួយនឹងការប្រើឧបករណ៍រាវរកគ្រាប់មីន ដែលស្ថិតនៅជំរៅក្រោម ៧ សង់ទីម៉ែត។[155]

ការដោះមីននៅឆ្នាំ២០០៨[156]

| ប្រតិបត្តិករ ដោះមីន | ដីដោះ មីនរួច (គ.ម$^{២}$) | មីនប្រឆាំងមនុស្ស ដែលបានបំផ្លាញ | មីនប្រឆាំង រថក្រោះ | យុទ្ធភណ្ឌមិនទាន់ផ្ទុះ ដែលបាន | ផ្ទៃដីដែលបានកាត់បន្ថយ ឬលុបចោល |
|---|---|---|---|---|---|

[152] Ibid, pp. 5 and 9–13; and interview with Heng Rattana, Director General, CMAC, in Geneva, 26 May 2009.
[153] Interview with Tim Porter, Program Manager, HALO, Siem Reap, 1 April 2009.
[154] HALO, "Mine clearance in Cambodia–2009," January 2009, p. 12.
[155] Interview with Rupert Leighton, Country Programme Manager, MAG, Phnom Penh, 30 March 2009; and email from Rupert Leighton, MAG, 23 March 2009.
[156] Emails from Eang Kamrang, Deputy Database Manager, CMAA, 7 and 20 April 2009; and CMAC, "Integrated Work Plan 2009," Phnom Penh, undated but 2009, p. 63.

| | | | ដែលបានបំផ្លាញ | បំផ្លាញ* | (គ.ម²) |
|---|---|---|---|---|---|
| មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (CMAC) | ២៧.៦៥ | ២៥,៩៤៣ | ៤៩៧ | ១១៤,១០១ | ២០១,៥២ |
| អង្គការ HALO | ៦.៩៧ | ៣៧,៩៤២ | ២១៥ | ៨,៣០៨ | ៩០,៣៥ |
| អង្គការ MAG | ៣.២៤ | ៤,៥៣៨ | ១១៩ | ១៩,៨១៣ | ១៩០,២៩ |
| សរុបអង្គការក្រៅរដ្ឋាភិបាល | ៣៧.៨៦ | ៦៧,៦២៣ | ៨៣១ | ១៤២,២២២ | ៤៨២,១៦ |
| កងយោធពលខេមរភូមិន្ទ (RCAF) | ២៧.៥០ | ១,៨៧៨ | ៣៧ | ៩,៨២២ | 0 |
| **សរុប** | ៦៥.៣៦ | ៦៩,៥០១ | ៨៦៨ | ១៥២,០៤៤ | ៤៨២,១៦ |

* ប្រតិបត្តិករដោះមីនមិនបានចង្អុលបង្ហាញភាពខុសគ្នារវាងគ្រាប់ UXO និងយុទ្ធភណ្ឌផ្ទុះក្នុងរបាយការណ៍របស់គេ

** គេមិនបានដឹងថាតើចំនួនប៉ុន្មានដែលជាតំបន់មានមីនថយចុះ ឬ លុបចោលថាលែងមានមីន ប៉ុន្តែវាទំនងជាច្រើនគួរសម ។

***ការធានាលើគុណភាព/ការត្រួតពិនិត្យគុណភាព***

អាជ្ញាធរមីនកម្ពុជា ទទួលខុសត្រូវផ្នែកការធានានូវគុណភាពដោះមីន(QA) តាមរយៈការគាំទ្រពីកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) ដែលនៅឆ្នាំ២០០៧ អាជ្ញាធរមីនបានចុះកុងត្រាជាមួយក្រុមហ៊ុនឈ្មោះ BACTEC ដើម្បីផ្តល់នូវជំនួយផ្នែកបច្ចេកទេស ។ កុងត្រាជាមួយក្រុមហ៊ុន BACTEC បានបញ្ចប់នៅពាក់កណ្តាលខែកក្កដា ឆ្នាំ២០០៩ នៅពេលដែលកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) បានជ្រើសរើសទីប្រឹក្សាបច្ចេកទេសសំរាប់គាំទ្រការធានានូវគុណភាព ។[157] នៅខែកុម្ភៈ ឆ្នាំ២០០៨ អាជ្ញាធរមីនកម្ពុជាបានបង្កើននូវក្រុមធានាគុណភាពពី២ទៅ៤ក្រុម ដែលមាន២ក្រុមធ្វើការប្រចាំនៅខេត្តបាត់ដំបងនិងកំពង់ចាម ។[158] ប្រតិបត្តិករដោះមីនបានរាយការណ៍ថាក្រុមធានាគុណភាព កាន់តែមានប្រសិទ្ធភាពឡើងពេលណាដែលពួកគេទទួលបានបទពិសោធន៍ ។[159] នៅក្នុងរបាយការណ៍ចុងក្រោយស្តីពីកិច្ចព្រមព្រៀងរបស់ខ្លួន ក្រុមហ៊ុន BACTEC សង្កេតឃើញថា "ការជាប់ពាក់ព័ន្ធរៀបចំរបស់អាជ្ញាធរមីនកម្ពុជា គឺជាការជំរុញឱ្យមានប្រតិកម្មតបជាជាងការចាត់វិធានការជាមុន" និង ទទួលរងនូវកង្វះខាតមូលនិធិ និងខ្សោយផ្នែករដ្ឋបាល និងភស្តុភា ។[160]

[157] Telephone interview with Melissa Sabatier, UNDP, 13 July 2009.
[158] Interview with Amb. Sam Sotha, CMAA, in Geneva, 2 June 2008; and see *Landmine Monitor Report 2008*, pp. 208–209.
[159] Interviews with operators, Phnom Penh, 28–30 April 2008.
[160] BACTEC, "End of Project Report," Phnom Penh, March/April 2009, pp. 6, 56.

***ដំណើរការចាប់តាំងពីក្លាយជាភាគីរដ្ឋ***

តាមមាត្រាទី៥នៃសន្ធិសញ្ញាហាមឃាត់ការប្រើប្រាស់មីន កម្ពុជាត្រូវអោយបោសសំអាតគ្រាប់មីនប្រភេទដែលប្រឆាំងនឹងមនុស្សឱ្យអស់ពីតំបន់ដែលមានគ្រាប់មីនក្រោមយុត្តាធិការ និងការគ្រប់គ្រងរបស់ខ្លួនអោយបានឆាប់តាមតែអាចធ្វើទៅបានក៏ប៉ុន្តែក៏មិនអោយយឺតជាងថ្ងៃទី១ខែមករាឆ្នាំ២០១០។

ខែមេសាឆ្នាំ២០០៩ កម្ពុជាបានដាក់សំណើរស្នើសុំការពន្យាពេលដោះមីនរយៈពេល១០ឆ្នាំទៀត "គឺចាប់ផ្តើមពីខែមករាឆ្នាំ២០១០ដល់ខែធ្នូឆ្នាំ២០១៩"។ សំណើរនេះបានប៉ាន់ស្មានថាតំបន់ដែលត្រូវការការបោសសំអាតទាំងអស់មានផ្ទៃដី៦៧២គ.ម² ដែលទាមទារអោយមានការបោសសំអាតជាប្រចាំឆ្នាំនូវផ្ទៃដីប្រហែល ៨០គ.ម² ចាប់ពីឆ្នាំ២០១១ទៅ គឺច្រើនជាងការបោសសំអាតដែលធ្វើដោយអង្គការមិនមែនរដ្ឋាភិបាលនៅឆ្នាំថ្មីៗនេះទ្វេរដង ហើយគ្រោងនឹងចំណាយទឹកប្រាក់សរុប ៥២៩លានដុល្លា។[161] ៤ខែក្រោយមកនៅខែសីហាឆ្នាំ២០០៩ កម្ពុជាបានដាក់ស្នើសំណើរកែប្រែឡើងវិញ ដែលបានប៉ាន់ស្មាននូវផ្ទៃដីដែលត្រូវដោះមីន ប្រមាណ ៦៤៨.៨គ.ម² និងគ្រោងចំណាយទឹកប្រាក់អស់ចំនួន៣៣០លានដុល្លា។

សំណើរកែប្រែឡើងវិញនេះ បានកត់សំគាល់ថា លទ្ធភាពបច្ចុប្បន្ននៃអង្គភាពដោះមីនអាចនឹងដោះមីនបានផ្ទៃដីចំនួន ៤៧០គ.ម² ហេតុដូចនេះហើយទើបគ្មានសមត្ថភាពបោសសំអាតអោយបានចប់ក្នុងរយៈពេល១០ឆ្នាំ។ សំណើរនោះបានបន្ថែមថា "ជាមួយនឹងការកើនឡើង៣៨%នៃធនធានហិរញ្ញវត្ថុដែលមាននៅតាមផ្នែក និងការជាប់ពាក់ព័ន្ធច្រើនឡើងនៃកងយោធពលខេមរភូមិន្ទក្នុងការបង្ហាញពីបញ្ហាដែលនៅសល់នោះ អត្រាផលិតភាពអាចត្រូវបានកើនឡើងដែលប្រហែលជាធ្វើអោយបញ្ចប់ទាំងស្រុងនូវការបោសសំអាតមីននៅតាមចំការមីនដែលគេដឹងក្នុងតាមរយៈពេលដែលសុំពន្យានេះបាន"។ ទោះបីយ៉ាងណាក៏ដោយ គេបានឱ្យដឹងជាមុនថាយោងតាមការប៉ាន់ស្មាននាពេលបច្ចុប្បន្ន "បញ្ហាសំរាប់កម្ពុជានឹងបន្តរហូតដល់ក្រោយឆ្នាំ២០១៩ ប្រសិនបើកំរិតមូលនិធិមិនកើនឡើង" ហើយបានទទួលស្គាល់ថាការដោះមីនទាមទារនូវការផ្តល់មូលនិធិទាំងក្នុងស្រុកនិងអន្តរជាតិ "នឹងធ្វើឱ្យវាមានការប្រណាំងប្រជែងជាខ្លាំងសំរាប់ផ្នែកដោះមីនកម្ពុជាដើម្បីរក្សានូវសមត្ថភាពដោះមីនបច្ចុប្បន្ន"។[162]

ក្រុមយុទ្ធនាការប្រឆាំងគ្រាប់មីនអន្តរជាតិ (ICBL) បានសន្និដ្ឋានថាកម្ពុជាគ្រាន់តែអាចផ្តល់ឱ្យរដ្ឋសមាជិកជាមួយនឹងការប៉ាន់ស្មានប្រកបដោយអត្ថន័យនៃគ្រោះថ្នាក់ដោយសារតែគ្រាប់មីនដែលនៅសល់, គំរោងផែនការ, និងការប៉ាន់ស្មានក្នុងការចំណាយបន្ទាប់ពីបានលទ្ធផលនៃការស្រាវជ្រាវមូលដ្ឋាននៅដំណាក់កាលទី១។ យុទ្ធនាការប្រឆាំងនឹងគ្រាប់មីនអន្តរជាតិឱ្យយោបល់ថា រដ្ឋសមាជិកគួរទុករយៈពេលពីរឆ្នាំសំរាប់កម្ពុជាដើម្បីអនុញ្ញាតឱ្យកម្ពុជាបានបញ្ចប់នូវការស្រាវជ្រាវដំណាក់កាលទីមួយ និង ការវិភាគនូវការរកឃើញរបស់ខ្លួន។[163]

ការដោះមីនពីឆ្នាំ១៩៩៩-២០០៨

[161] Article 5 deadline Extension Request, 30 April 2009, pp. 8, 54, 56–59.
[162] Article 5 deadline Extension Request (Revision), 24 August 2009, pp. 6, 56.
[163] ICBL, "ICBL critique of Cambodia's Article 5 Deadline Extension Request," May 2009, www.icbl.org.

| **ឆ្នាំ** | **ការបោសសំអាតមីន**(គ.ម$^{២}$)* | **ដីដែលបានកាត់បន្ថយ ឬលុបចោល**(គ.ម$^{២}$) |
|---|---|---|
| ២០០៨ | ៣៧.៨៦ (៦៣.២៦) | ៤៨២.១៦ |
| ២០០៧ | ៣៦.៣៤ (៥៥.៣) | ៥៥៧.០២ |
| ២០០៦ | ៣៥.៤ (៥១.៩) | ៣០៣ |
| ២០០៥ | ៣០.៨ (៤០.៦) | ៨៥.៤ |
| ២០០៤ | ១៨.៩ (៣២.០) | 0 |
| ២០០៣ | ១៧.៣ (៤១.៧) | 0 |
| ២០០២ | ១៧.៦ (៣៤.៧១) | 0 |
| ២០០១ | ១៥.៤ (២១.៨៧) | 0 |
| ២០០០ | ១២.១៨ (៣២.១៩) | 0 |
| ១៩៩៩ | ១២.៥៣ (គ្មានរបាយការណ៍) | 0 |
| **សរុប** | ២៣៤.៣១ (៣៧៣.៥៣) | ១.៤២៧.៥៨ |

*(ក្នុងងវង់ក្រចកបង្ហាញពីការបោសសំអាតរួម ដែលរួមមានលទ្ធផលរាយការណ៍ពីកងយោធពលខេមរភូមិន្ទ)

## ការអប់រំអំពីគ្រោះថ្នាក់ដោយគ្រាប់មីន

មានវិធីសាស្ត្រសំខាន់ៗចំនួន៤សំរាប់ការអប់រំអំពីគ្រោះថ្នាក់មីននៅកម្ពុជាវិធីសាស្ត្រផ្អែកតាមការផ្ញើរសារ(ផ្សព្វផ្សាយការយល់ដឹង, លើកកម្ពស់ការយល់ដឹង, ព័ត៌មានសាធារណះនិងការអប់រំ) វិធីសាស្ត្រដោះមីនចម្រុះគ្នា/ការចិញ្ចឹមជីវិត ការពង្រឹងច្បាប់ និងការត្រួតពិនិត្យជំនួញកំទេចលោហធាតុ និងការចូលរួមរបស់សហគមន៍ក្នុងដំណើរការដោះមីន។[164] នៅឆ្នាំ ២០០៨ ការអប់រំពីគ្រោះថ្នាក់មីនបានធ្វើឡើងដោយមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ក្រសួងអប់រំយុវជន និងកីឡា (MoEYS) ប៉ូលីសជាតិ កាកបាទក្រហមកម្ពុជា អង្គភាពប្រតិបត្តិការបោសសំអាតមីន និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗទៀត។ នៅតាមខេត្ត មានគណៈកម្មាធិការដោះមីនថ្នាក់ខេត្តរៀបចំកំណត់អាទិភាព និង សម្របសម្រួលសារអប់រំទាំងនោះ។[165] ទិន្នន័យប្រព័ន្ធព័ត៌មានជនរងគ្រោះដោយគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះនៅកម្ពុជាផ្តល់ជាព័ត៌មានសកម្មភាពប្រតិបត្តករដោះមីន។[166]

ទោះជាយុទ្ធសាស្ត្រអប់រំពីគ្រោះថ្នាក់មីន មានគោលបំណងផ្តល់អំណាចទៅអោយសហគមន៍ដែលរងការប៉ះពាល់ដើម្បីធ្វើអត្តសញ្ញាណអំពីវិធីសាស្ត្រអប់រំ ឬកាត់បន្ថយហានិភ័យសមស្របនិងមានប្រសិទ្ធភាពក៏ដោយ ក៏ការវាយតំលៃរបស់អាជ្ញាធរមីនកម្ពុជានិងអង្គការយូនីសេហ្វបង្ហាញថា "សកម្មភាពអប់រំពីគ្រោះថ្នាក់មីនដោយផ្ទាល់នៅតែដើរតួយ៉ាងសំខាន់

[164] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008, p. 24.
[165] Interview with Oum Sang Onn, CMAC, in Geneva, 28 April 2009.
[166] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008, p. 8.

ក្នុងការផ្សព្វផ្សាយទោះបីជាមានការផ្តោតទៅលើការបញ្ចៀសពីហានិភ័យក៏ដោយ។ យុទ្ធសាស្ត្រចំបងគឺការផ្សព្វផ្សាយព័ត៌មានដែលគោលដៅគឺឱ្យដល់ក្រុមប្រជាជនឱ្យបានច្រើន ទោះបីជាការធ្វើផ្សងនឹងគ្រោះថ្នាក់ចំៗខ្លះត្រូវបានដាក់បញ្ចូលទៅក្នុងសារនោះក៏ដោយ។"[167]

វិធីសាស្ត្រផ្សព្វផ្សាយការអប់រំពីគ្រោះថ្នាក់មីនមួយទៀត គឺតាមរយៈកម្មវិធីរបស់មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា "ការអប់រំនិងកាត់បន្ថយគ្រោះថ្នាក់នៃគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ តាមរយៈប៉ូលីសជាតិនិងចលភាពធនធានសហគមន៍"។[168] ចាប់តាំងពីចុងឆ្នាំ២០០១មក មជ្ឈមណ្ឌលកំចាត់មីនកម្ពុជាអនុវត្តបណ្តាញពីសហគមន៍ទៅអាជ្ញាធរស្រុក។ គណៈកម្មាធិការគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ (MUCs) ដែលមានសមាជិកជាបុគ្គលិករដ្ឋាភិបាល និងអ្នកស្ម័គ្រចិត្តរបស់សហគមន៍ បង្កើតនូវទំនាក់ទំនងគ្នាជាមួយក្រុមបង្គោលរបស់ស្រុក ដែលជាសមាជិកនៃអាជ្ញាធរក្នុងតំបន់។ នៅភាគពាយ័ព្យ វិធីសាស្ត្រនេះត្រូវបានគេហៅថា ការកាត់បន្ថយគ្រោះថ្នាក់មីនតាមសហគមន៍(CBMRR)។[169] នៅភាគអាគ្នេយ៍ ក្រុមនេះគេហៅថា ការកាត់បន្ថយគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ (CBURR) ប៉ុន្តែដំណើរការមិនសូវបានល្អទេនៅកម្រិតសហគមន៍។[170] គណៈកម្មាធិការគ្រាប់មីន គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ (MUCs) ប្រើប្រាស់នូវការសិក្សាបែបចូលរួមដើម្បីស្វែងយល់ពីបញ្ហា និងក្រោយមកបានធ្វើការជាមួយភ្នាក់ងារដៃគូអភិវឌ្ឍន៍ និងអាជ្ញាធររដ្ឋាភិបាល ដើម្បីបញ្ចូលសកម្មភាពកំចាត់មីនទៅក្នុងផែនការអភិវឌ្ឍន៍សហគមន៍។ របាយការណ៍ស្តីពីតំបន់គ្រោះថ្នាក់មីនបានបញ្ជូនទៅក្រុមបង្គោលរបស់ស្រុកដែលជាអ្នកស្នើរសុំឱ្យមានការបោសសំអាតមីនពីក្រុមប្រតិបត្តិករដោះមីន។ ការកើនឡើងនៃក្រុមកាត់បន្ថយគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ (CBURRs) ក្នុងឆ្នាំ២០០៨ នាំអោយមានការកើនឡើងនូវរបាយការណ៍ពីទីកន្លែងគ្រោះថ្នាក់ដោយគ្រាប់មិនទាន់ផ្ទុះដែលជាទូទៅបានត្រូវគេឆ្លើយតប។[171] គណៈកម្មាធិការគ្រាប់មីន-គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ ក៏បានចែកចាយសារអប់រំពីគ្រោះថ្នាក់នៅតាមសាលារៀន និងរក្សានូវគំនូសសំគាល់ពីតំបន់មានមីន។[172] សារទាំងនោះនិយាយពីបញ្ហាចម្រុះ ដែលរួមមាន បញ្ហាមេរោគហ៊ីវ បញ្ហាផ្លូវភេទជាដើម។[173] មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា មានបំណងចង់អោយគ្រប់ស្រុកទាំងអស់នៅក្នុងប្រទេសមានសមត្ថភាពផ្នែកការអប់រំកាត់បន្ថយគ្រោះថ្នាក់តាមសហគមន៍។[174]

ការអប់រំអំពីគ្រោះថ្នាក់មីនបានបញ្ចូលនៅក្នុងកម្មវិធីសិក្សារបស់សាលារៀន នៅក្នុងគំរោងដែលអនុវត្តដោយក្រសួងអប់រំយុវជន និងកីឡា ដោយមានការគាំទ្រពីប្រតិបត្តិករអប់រំពីគ្រោះថ្នាក់មីន។[175] នៅឆ្នាំ២០០៨ នាយកគ្រប់គ្រង និង

---

[167] Ibid, p. 6.
[168] CMAA, "Annual Activity Report, 1 January–31 December 2008, National Mine/UXO Risk Education and Risk Reduction Coordination in Cambodia," Phnom Penh, 2009, p. 8.
[169] Interview with Oum Sang Onn, CMAC, in Geneva, 28 April 2009.
[170] Ibid.
[171] Ibid.
[172] Ibid.
[173] Ibid.
[174] Ibid.
[175] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008, p. 24; and Interview with Oum Sang Onn, CMAC, in Geneva, 28 April 2009.

អ្នកត្រួតពិនិត្យនៅតាមសាលារៀន បានទទួលការហ្វឹកហ្វឺន និងទទួលការគាំទ្រដើម្បីស៊ើបអង្កេតការអនុវត្តន៍ក្នុងការបង្រៀនសំភាសន៍កូនៗនិងឪពុកម្តាយ ដើម្បីវាយតំលៃពីការផ្លាស់ប្តូរចរិកលក្ខណៈ និងជួបគ្រូបង្រៀនដើម្បីផ្តល់នូវដំបូន្មាន និងរំលឹកឡើងវិញនូវការបណ្តុះបណ្តាល ។[176]

យុទ្ធនាការអប់រំពីគ្រោះថ្នាក់មីនក៏មានបញ្ចូលនៅតាមស្រុកតាមរយៈទូរទស្សន៍ និង វិទ្យុផងដែរ ។[177]

ការអប់រំពីគ្រោះថ្នាក់មីនត្រូវបានបញ្ចូលយ៉ាងល្អទៅក្នុងផ្នែកផ្សេងៗទៀតនៃសកម្មភាពមីន ។[178] ភ្នាក់ងារដោះមីនអនុវត្តនូវទំនាក់ទំនងសហគមន៍ (CL) ។ អង្គការ MAG ក៏បានអនុវត្តនូវទំនាក់ទំនងសហគមន៍ ជាសកម្មភាពចំបងដែលធានាថាសហគមន៍ដែលរងការប៉ះពាល់គ្រាប់មីន ត្រូវបានប្រឹក្សា និងជាប់ពាក់ព័ន្ធទៅគ្រប់ជំហានទាំងអស់នៃដំណើរការសកម្មភាពមីន ។ ក្រុមកំទេចគ្រឿងផ្ទុះ (EOD) ផ្តល់នូវការអប់រំពីគ្រោះថ្នាក់មីនក្រៅផ្លូវការជាប្រចាំទៅលើការអនុវត្តន៍ផ្សេងៗ ដូចជារបៀបធ្វើសេចក្តីរាយការណ៍ពីមីន ឬ គ្រាប់មិនទាន់ផ្ទុះ ក៏ដូចជាការសង្ខេបគោលៗពីសុវត្ថិភាពក្នុងពេលចុះប្រតិបត្តិការបោសសំអាតមីន ។[179] បញ្ហាដែលជួបប្រទះនៅឆ្នាំ២០០៨ រួមមាន កង្វះខាតធនធាន និងការប្រមូលរបាយការណ៍ពីក្រសួងអប់រំយុវជននិងកីឡា ។[180]

សកម្មភាពអប់រំអំពីគ្រោះថ្នាក់ដោយគ្រាប់មីននៅឆ្នាំ២០០៨[181]

| **អង្គការ** | **ប្រភេទ** | **ប្រភេទសកម្មភាព** | **ទីកន្លែង** | **ចំនួនអ្នកទទួលបានផល** |
|---|---|---|---|---|
| មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា (CMAC) | អង្គការជាតិ | មាន៩កម្មវិធី : ការកាត់បន្ថយ និងការអប់រំអំពីគ្រោះថ្នាក់មីន, ការកាត់បន្ថយហានិភ័យដោយសារមីនតាមសហគមន៍, ប្រព័ន្ធផ្សព្វផ្សាយ (ទូរទស្សន៍ និង វិទ្យុ), ការកាត់បន្ថយគ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមរយៈឈ្មួញទិញអេតចាយ | ខេត្តដែលរងការប៉ះពាល់ទាំង១៧ : បន្ទាយមានជ័យ , បាត់ដំបង , កំពង់ចាម, កំពង់ស្ពឺ, កំពង់ធំ, កណ្តាល, ក្រចេះ, មណ្ឌលគីរី, ឧត្តរមានជ័យ, ប៉ៃលិន, ព្រះវិហារ, ព្រៃវែង, រតនៈគីរី, សៀមរាប, ស្ទឹងត្រែង និងស្វាយរៀង | បណ្តាញ CBMRR ចំនួន៤៣៤ (ចំនួនអ្នកទទួលផលសរុបមិនទាន់ មាន), បណ្តាញ CBURR មានអ្នកទទួលផលចំនួន៨៩៩០៨នាក់ ដោយក្នុងនោះរួមមានឈ្មួញ / អ្នកប្រមូល ៣៩៧នាក់ |

[176] CMAA, "Annual Activity Report, 1 January–31 December 2008, National Mine/UXO Risk Education and Risk Reduction Coordination in Cambodia," Phnom Penh, 2009, p.17.
[177] Interview with Oum Sang Onn, CMAC, in Geneva, 28 April 2009.
[178] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008, p. 34.
[179] Response to Landmine Monitor questionnaire by Ruth Bottomley, MAG, 6 July 2009.
[180] CMAA, "Annual Activity Report, 1 January–31 December 2008, National Mine/UXO Risk Education and Risk Reduction Coordination in Cambodia," Phnom Penh, 2009, p. 6.
[181] Ibid, pp. 15, 17, 21, 23, 25, 26, 28, 36.

| | | | | |
|---|---|---|---|---|
| | | និង ការកាត់បន្ថយ គ្រោះថ្នាក់គ្រាប់មិនទាន់ផ្ទុះតាមសហគមន៍ | | |
| កាកបាទក្រហម កម្ពុជា (CRC) | **អង្គការជាតិ** | អ្នកស្ម័គ្រចិត្តដែលធ្វើការជាមួយអ្នកនេសាទ អ្នកប្រមាញ់ អ្នកចំណូលថ្មី អ្នករកអុស-ឈើ អតីតយុទ្ធជន អ្នកប្រមូលកំទេចលោហធាតុ និង កូនសិស្សក្នុងនិង ក្រៅសាលា. បុគ្គលិកគំរោងប្រព័ន្ធព័តិមានជនរងគ្រោះដោយគ្រាប់មីននៅកម្ពុជា (ជួលដោយកាកបាទក្រហមកម្ពុជា) ការអប់រំអំពីហានិភ័យបន្ទាន់ នៅកន្លែងដែលពួកគេប្រមូលទិន្នន័យ និងកន្លែងដែលឧប្បត្តិហេតុបានកើនឡើង និង ឆ្លើយតបទៅតាមសំណើរ ពីប្រតិបត្តិករផ្សេងទៀតនៅតាមតំបន់ដាច់ស្រយ៉ាល | គ្រប់ខេត្ត | ៣១៩៥៨ នាក់ |
| អង្គការ HALO Trust | អង្គការមិនមែន រដ្ឋាភិបាល | ការអប់រំអំពីហានិភ័យដោយរួមជាមួយសកម្មភាពបោសសំអាតមីន | បន្ទាយមានជ័យ បាត់ដំបង ឧត្តរមានជ័យ ប៉ៃលិន និងសៀមរាប | ៣៥៩១៥ នាក់ |

| | | | | |
|---|---|---|---|---|
| អង្គការជនពិការអន្តរជាតិ (HI) | អង្គការមិនមែន រដ្ឋាភិបាល | ការអប់រំអំពីគ្រោះថ្នាក់មីន ក្រោមកិច្ចសហប្រតិបត្តការជាមួយ ប៉ូលីសជាតិ និង ប្រតិបត្តិករអភិវឌ្ឍន៍ ផ្តោតលើជំនួញ អេតចាយ | ប៉ៃលិន រតនៈមណ្ឌល **សាលាគ្រូ** និងសំឡូត | ១៩៣៤ នាក់ |
| ក្រុមប្រឹក្សាយោបល់ស្តីពីគ្រាប់មីន (MAG) | អង្គការមិនមែន រដ្ឋាភិបាល | ការអប់រំក្រៅប្រព័ន្ធស្តីពីគ្រោះថ្នាក់មីន តាមរយៈបុគ្គលិកផ្នែក ទំនាក់ទំនងសហគមន៍, មុនពេលការងាររបស់ ក្រុមកំទេចគ្រឿងផ្ទុះ | បន្ទាយមានជ័យ បាត់ដំបង កំពង់ចាម ប៉ៃលិន និងព្រះវិហារ | -ការអប់រំអំពីគ្រោះថ្នាក់មីន ផ្តល់ដល់មនុស្ស ២៥១៧១ នាក់<br>-ក្រុមទំនាក់ទំនងសហគមន៍ ទៅដល់មនុស្ស ២៧២៣៣នាក់ |
| ក្រសួងអប់រំយុវជន និងកីឡា (MoEYS) | រដ្ឋាភិបាល | បណ្តុះបណ្តាលសមាជិកប្រព័ន្ធអប់រំ : នាយកសាលា , មន្ត្រីអប់រំថ្នាក់ស្រុក, អ្នកត្រួតពិនិត្យ, និងបុគ្គលិកបណ្តុះ បណ្តាលគ្រូបង្រៀន, នាយកដ្ឋានផែនការ និងគរុកោសល្យ | បន្ទាយមានជ័យ បាត់ដំបង, កំពង់ចាម, កំពង់ស្ពឺ, ក្រចេះ, ឧត្តរមានជ័យ, ប៉ៃលិន, ព្រះវិហារ និង ពោធិសាត់ | គ្រូ ២១៩៥ នាក់ និងសិស្ស ១៤៥៣៧៧ នាក់ |
| ប៉ូលីសជាតិ (National Police) | រដ្ឋាភិបាល | ច្បាប់អប់រំអំពីគ្រោះថ្នាក់មីនដែល ជាប់ទាក់ទងនឹងការអប់រំអំពីហានិភ័យ នៃកំទេចលោហធាតុ និង សំណល់ជាតិផ្ទុះ សល់ពីសង្គ្រាម, ក្រុម UXO របស់ប៉ូលីសដែលធ្វើការ ប្រមូលពតិមាន | គោលដៅមាន៧ខេត្ត គឺ បន្ទាយមានជ័យ បាត់ដំបង កំពង់ស្ពឺ កណ្តាល ឧត្តរមានជ័យ ប៉ៃលិន និងសៀមរាប | ៣៥៥១៦ នាក់ |

| | | | | |
|---|---|---|---|---|
| | | អំពីគ្រោះថ្នាក់ | | |
| កងយោធពលខេមរភូមិន្ទ (RCAF) | កងយោធា | ការអប់រំពីគ្រោះថ្នាក់មីន រួមជាមួយសកម្មភាពបោសសំអាតមីន, ការបណ្តុះបណ្តាល | ខេត្តដែលកំពុងតែធ្វើការដោះមីន | |
| អង្គការ Spirit of Soccer | អង្គការមិនមែន រដ្ឋាភិបាល | ការអប់រំអំពីហានិភ័យតាមរយៈការបង្វឹកទាត់បាល់នៅតាមសាលារៀន, ការចែកចាយការអប់រំពីហានិភ័យ ដោយប្រយោលតាមរយៈសមាគមន៍បាល់ទះជនពិការ ដោយយោងតាមមជ្ឈមណ្ឌលកំចាត់មីននៅកម្ពុជា | បន្ទាយមានជ័យ បាត់ដំបង និងប៉ៃលិន | សិស្ស ១២៧២៦ នាក់ |
| អង្គការទស្សនៈពិភពលោកប្រចាំនៅកម្ពុជា (World Vision Cambodia) | អង្គការមិនមែន រដ្ឋាភិបាល | ការអប់រំអំពីគ្រោះថ្នាក់មីននៅក្នុងសហគមន៍តាមរយៈអ្នកតំណាងអប់រំពីគ្រោះថ្នាក់ចុះដល់ផ្ទះនិងការប្រជុំអប់រំអំពីគ្រោះថ្នាក់មីននៅក្នុងសហគមន៍ | ស្រុករតនៈមណ្ឌល ស្រុកសំឡូតនៃខេត្តបាត់ដំបង និងស្រុករវៀងនៃខេត្តព្រះវិហារ | ១៥ឃុំ ៩៣គ្រួសារ តាមរយៈការចុះដល់ផ្ទះ |

ឯកសារអប់រំអំពីគ្រោះថ្នាក់មីនជាភាសាខ្មែរ ត្រូវបានចែកចាយក្នុងចំណោមអង្គការដែលអនុវត្តកម្មវិធីអប់រំពីគ្រោះថ្នាក់មីន។ ការវាយតំលៃក្រៅផ្លូវការអំពីឯកសារទាំងនោះ ត្រូវបានធ្វើឡើងនៅក្នុងអង្គប្រជុំក្រុមការងារបច្ចេកទេសសំរាប់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន (MRE **TWG**)។ អាជ្ញាធរមីនកម្ពុជា រៀបចំឯកសារសំរាប់កងកំលាំងប្រដាប់អាវុធ និងប៉ូលីស ខណៈពេលដែលប្រតិបត្តិករផ្សេងទៀតកំពុងតែរៀបឯកសាររបស់ខ្លួនដែរ។[182]

[182] Interview with Khuon Pheng, MRE Officer, CMAA, Phnom Penh, 2 July 2009.

ការវាយតំលៃខាងក្រៅរបស់អាជ្ញាធរមីនកម្ពុជា/យូនីសេហ្វ (CMAA/UNICEF) នាខែតុលា ឆ្នាំ២00៨ បានសន្និដ្ឋានថា : "ផ្នែកការអប់រំពីគ្រោះថ្នាក់ដោយសារគ្រាប់មីន (MRE) នៅកម្ពុជាបានសម្របខ្លួនឆ្លើយតបនៅនឹងដំណាក់កាលផ្សេងៗគ្នាគួរឱ្យកត់សម្គាល់។ ជារួមការងារនេះមានលក្ខណៈល្អប្រសើរនៅតាមគោលដៅនៃតំបន់រងផលប៉ះពាល់។ កម្មវិធីនេះក៏មានប្រសិទ្ធភាពផងដែរក្នុងការបង្កើនការយល់ដឹង និង ចំណេះដឹងអំពីយុទ្ធសាស្ត្របញ្ចៀសនូវគ្រោះថ្នាក់ដោយសារមីន។ ពាក់ព័ន្ធនឹងសារទាំងឡាយផលិតពីមុនៗរបស់កម្មវិធី គឺមានទាក់ទងតិចតួចនៅក្នុងបរិបទបច្ចុប្បន្ន និង ត្រូវការពិនិត្យឡើងវិញដើម្បីធានាថាវាមានលក្ខណៈកាន់តែជាក់លាក់តាមបរិការណ៍។ ផលប៉ះពាល់ធ្វើអោយកាន់តែពិបាកដល់ការវាយតំលៃនិងពិបាកវាស់វែងនូវវិសាលភាពនៃការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន បាននាំឱ្យមានការផ្លាស់ប្តូរឥរិយាបថដែលនាំទៅរកការកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ។ វិធីសាស្ត្រដែលមានគោលដៅច្បាស់លាស់ និងមានច្រើនផ្នែកផ្អែកតាមគោលការណ៍នៃការទំនាក់ទំនងនឹងឥទ្ធិពលនៃឥរិយាបថផ្លាស់ប្តូរ។ ក្រុមការងារបច្ចេកទេសសំរាប់ការអប់រំពីគ្រោះថ្នាក់ដោយគ្រាប់មីន ក៏គួរតែបញ្ចូលគ្នាឱ្យបានកាន់តែច្រើនឡើងនិងទូលំទូលាយទៅក្នុងការអភិវឌ្ឍន៍ និងអន្តរាគមន៍បោសសំអាតមីនក្នុងគោលបំណងអោយគេយល់ថាបញ្ហាគ្រាប់មីន/គ្រាប់មិនទាន់ផ្ទុះ ជាបញ្ហាអន្តរវិស័យដែលត្រូវបានបញ្ចូលទៅក្នុងយុទ្ធសាស្ត្រសុវត្ថិភាពទូទៅ និងត្រូវបានចាត់ចែងក្រោមរចនាសម្ព័ន្ធរដ្ឋាភិបាលក្នុងតំបន់ដែលមានស្រាប់។ នេះគឺជាកំលាំងដ៏ចំបងមួយនៃវិធីសាស្ត្រកាត់បន្ថយគ្រោះថ្នាក់ដោយគ្រាប់មីនតាមសហគមន៍ ដែលអាចជួយឱ្យមានភាពម្ចាស់របស់ជាតិ"។[183]

ការយល់ដឹងដ៏ទំលំទូលាយអំពីគ្រាប់មីនត្រូវបានធ្វើឡើងនៅកម្ពុជាអស់រយៈពេលជាង១0ឆ្នាំ។ មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា បានធ្វើការសម្របសម្រួលនូវការអប់រំអំពីគ្រោះថ្នាក់នេះរហូតដល់ឆ្នាំ២000 ហើយជាពេលដែលការសម្របសម្រួលនេះបានក្លាយជាជាតួនាទីរបស់អាជ្ញាធរមីនកម្ពុជា។ ការអប់រំអំពីគ្រោះថ្នាក់ដោយសារមីនបានវិវត្តជាមួយនឹងការទទួលស្គាល់ថាការបង្កើនការយល់ដឹងតែមួយគឺមិនគ្រប់គ្រាន់ទេ ខណៈពេលដែលប្រជាជនបានទទួលរងនូវហានិភ័យតាមរយៈសារសំខាន់នៃវិស័យសេដ្ឋកិច្ច។[184] ការយល់ដឹងពីដើមៗអំពីមីន តំរូវអោយពង្រីកបន្ថែមនូវវិធីសាស្ត្ររបស់ខ្លួនសំរាប់កសាងសមត្ថភាពនៃសហគមន៍ដើម្បីឱ្យមានការចូលរួមពេញលេញនៅក្នុងសកម្មភាពមីន និងផ្តល់នូវការអប់រំអំពីហានិភ័យមីន។ នៅឆ្នាំ២00៤ អង្គការ UNICEF បានចាប់ផ្តើមផ្តល់មូលនិធិដល់អ្នកសម្របសម្រួលការអប់រំអំពីគ្រោះថ្នាក់មីនធ្វើការពេញម៉ោងនៅក្នុងអាជ្ញាធរមីនកម្ពុជា។[185] នៅឆ្នាំ២00៥ យុទ្ធសាស្ត្រត្រូវបានបង្កើតដើម្បីធ្វើអោយកាន់តែប្រសើរឡើងនូវការដាក់បញ្ចូលគ្នានៃការអប់រំអំពីគ្រោះថ្នាក់ដោយសារមីនក្នុងសកម្មភាពមីន និងការអភិវឌ្ឍន៍សហគមន៍ដើម្បីពង្រឹងការសម្របសម្រួលថ្នាក់ជាតិ និងដើម្បីបញ្ចូលការអប់រំនេះទៅក្នុងកម្មវិធីសិក្សារបស់សាលារៀន។[186] ដោយសារតែអាត្រាគ្រោះថ្នាក់នៅតែបន្តកើនឡើង យុទ្ធសាស្ត្រឆ្នាំ២00៦-២0១២ ត្រូវបានកែប្រែឡើងវិញ និងបានបង្កើតឡើងក្នុងគោលបំណងផ្តល់នូវអំណាចទៅដល់សហគមន៍ដែលរងការប៉ះពាល់ដើម្បីធ្វើការកំណត់ទៅលើវិធីសាស្ត្រកាត់បន្ថយ ឬ ការអប់រំអំពីគ្រោះថ្នាក់សមស្របនិងមានប្រសិទ្ធភាព

[183] "Evaluation of Mine Risk Education in the Kingdom of Cambodia," CMAA/UNICEF, October 2008, p. 7.
[184] See *Landmine Monitor Report 2001*, p. 446; and *Landmine Monitor Report 1999*, p. 403.
[185] See *Landmine Monitor Report 2004*, p. 259.
[186] See *Landmine Monitor Report 2005*, p. 220.

ហើយដាក់បញ្ចូលកិច្ចខិតខំប្រឹងប្រែងទាំងនេះឱ្យបានទូលំទូលាយជាមួយនឹងសកម្មភាពមនុស្សធម៌និងអភិវឌ្ឍន៍។ នៅឆ្នាំ២០០៦ សមត្ថភាពអប់រំអំពីគ្រោះថ្នាក់នេះបានកើនឡើង ប៉ុន្តែចំនួនអ្នកទទួលផលបែរជាធ្លាក់ចុះ ខណៈដែលការអប់រំនេះកាន់តែផ្តោតទៅលើក្រុមអ្នករងគ្រោះថ្នាក់ តាមរយៈការដាក់បញ្ចូលការអប់រំនេះជាមួយការអភិវឌ្ឍន៍សហគមន៍ និងសកម្មភាពបង្កើតប្រាក់ចំណូលតូចៗ។[187]

## ជំនួយដល់អ្នកដែលមានជីវិតពីគ្រាប់មីន

ផែនការជាតិផ្តល់ជំនួយដល់អ្នករស់រានជីវិតពីគ្រាប់មីនបានលើកឡើងថា គ្រួសារមួយដែលមានមេដឹកនាំជា "ជនពិការដោយសារសង្គ្រាម ឬ គ្រាប់មីន រស់នៅក្នុងភាពក្រីក្រច្រើនជាងជនពិការដោយសារមូលហេតុផ្សេងជិតបីដង។"[188]

ជាទូទៅការផ្តល់សេវាវេជ្ជសាស្ត្រគឺត្រូវបង់លុយ និងថ្លៃនៃការថែទាំសុខភាពបន្តនេះគឺមិនមានឡើយ។ សេវាដឹកជញ្ជូនបន្ទាន់ពុំទាន់បានទូលំទូលាយ ហើយកង្វះខាតផ្នែកគមនាគមន៍ក៏ជាឧបសគ្គសំរាប់តំបន់ដាច់ស្រយាលដែរ។ ការផ្តល់សេវាថែទាំបន្ទាន់ចំពោះអ្នករស់ជីវិតពីគ្រាប់មីន/សំណល់ជាតិផ្ទុះសល់ពីសង្គ្រាម នៅមានកម្រិតចំពោះបរិក្ខារកិច្ចរបស់រដ្ឋាភិបាល។ ការថែទាំរបួស/ដំបៅរ៉ាំរ៉ៃពេញលេញមួយ, សង្គ្រោះបន្ទាន់ មានតែអង្គការក្រៅរដ្ឋាភិបាលរបស់អ៊ីតាលីមួយគត់ស្ថិតក្នុងខេត្តបាត់ដំបង។ ការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលគឺផ្តល់តែគោលៗហើយការសម្របសម្រួលក្នុងផ្នែកនេះក៏មានកម្រិត។ ក្រោមមូលនិធិសមធម៌សុខភាព (Health Equity Fund) ការចំណាយលើផ្នែកឱសថមួយចំនួនត្រូវបានទទួលរាប់រង ប៉ុន្តែនេះពុំមែនមានសម្រាប់ជនពិការទាំងអស់ទេ។[189]

សេវាកម្មនៃការស្តារនីតិសម្បទា ដែលទទួលបានការគាំពារដោយប្រតិបត្តិករអន្តជាតិចំនួន៥ បានដំណើរការល្អ និងមានគុណភាពល្អ ជាពិសេសចំពោះអ្នកពិការដៃឬជើងទាំងពីរដោយសារគ្រាប់មីន។ ការផ្តល់ការស្នាក់នៅ ការធ្វើដំណើរ និងចំណីអាហារក៏អាចត្រូវរួមបញ្ចូលផងដែរ។[190] ជាញឹកញាប់ទោះបីជាតម្លៃធ្វើដំណើរត្រូវបានទូទាត់សងតាមក្រោយក៏ដោយ ក៏បញ្ហានេះនៅតែកើតមានសំរាប់អ្នកជំងឺទាំងនោះដដែល។[191] ការសម្របសម្រួលក្នុងចំណោមអ្នកផ្តល់សេវាទាំងនេះល្អប្រសើរ។

ផ្នែកស្តារកាយនីតិសម្បទាក្នុងព្រះរាជាណាចក្រកម្ពុជា គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) ដែលតែងបានផ្តល់នូវកិច្ចសង្គ្រោះមានកម្រិត ដូចជាផ្តល់បុគ្គលិករដ្ឋាភិបាលបែងចែកថវិកាបន្តិចបន្តួច ហើយផ្តោតទៅលើចំណាយប្រតិបត្តិការជាច្រើន ផ្តល់ការលើកលែងពន្ធ ដីធ្លីនិងសំណង់អាគារទាំងអស់។

---

[187] See *Landmine Monitor Report 1999*, p. 403; *Landmine Monitor Report 2001*, p. 446; *Landmine Monitor Report 2004*, p. 259; *Landmine Monitor Report 2005*, p. 220; *Landmine Monitor Report 2006*, p. 259; and *Landmine Monitor Report 2007*, p. 277.
See *Landmine Monitor Report 2007*, p. 277.
[188] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 6.
[189] Ibid, p. 13.
[190] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 18.
[191] Landmine Monitor interviews with survivors, Pursat, 5 April 2009; and Kampong Thom, 9 April 2009; and interview with Sok Sophorn, HI-B, Siem Reap, 8 April 2009.

យ៉ាងណាក៏ដោយ ក៏សេវាទាំងឡាយត្រូវបានផ្តល់ដោយប្រតិបត្តិករអន្តរជាតិយ៉ាងច្រើនលើសលុប ។[192] ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា បានចាប់ផ្តើមទទួលបន្ទុកផ្នែកស្តារនីតិសម្បទា នៅចុងឆ្នាំ ២០១០ (សូមមើលផ្នែកគំរោងខាងលើ) ប៉ុន្តែផ្នែកស្តារនីតិសម្បទាបានបន្តដំណើរការដោយស្ទើរតែគ្មានបញ្ចូលមូលនិធិអន្តរជាតិ ។

តាមរបាយការណ៍ឆ្នាំ២០០៨ បានបង្ហាញថា ការគ្រប់គ្រងហិរញ្ញវត្ថុ និង កិច្ចការបច្ចេកទេសរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទាបានសម្រេចលទ្ធផលជាមធ្យមត្រឹមតែ ៥០% ឬតិចជាងនេះ ចំណែកឯអ្នកអនុវត្តន៏ការងារបានដាក់ពិន្ទុខ្ពស់ជាងលទ្ធផលជាក់ស្តែងយ៉ាងខ្លាំង ។[193] ប្រត្តិបត្តិករបានកត់សំគាល់ថាក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MoSVY) មិនទាន់ផ្តើមចំណាយនូវវិភាគទានហិរញ្ញវត្ថុខ្នាតតូចរបស់ខ្លួន (តិចជាង៥%) ដល់ការចំណាយរបស់មជ្ឈមណ្ឌលនៅខែមេសា ឆ្នាំ២០០៩ នោះទេ។ ប៉ុន្តែពួកគេព្រួយបារម្ភនិងលើកឡើងជាចំបងលើការរក្សាទុកបុគ្គលិក ដែលទទួលប្រាក់បៀវត្សដូចទៅនឹងកំរិតប្រាក់បៀវត្សបុគ្គលិករបស់រដ្ឋាភិបាលដែលទាបជាងប្រាក់បៀវត្សដែលពួកគេបានទទួលកាលពីមុនដែលមើលទៅមិនសមស្របទៅតាមលក្ខ័ណ្ឌការងាររមន្ត្រីរាជការស៊ីវិល ។[194] គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ (ICRC) បានដឹងជាមុនពីផលវិបាកមួយចំនួនដែលអង្គការនេះបានធ្វើការជាមួយបុគ្គលិករបស់រដ្ឋាភិបាលក្នុងលក្ខខ័ណ្ឌប្រាក់បៀវត្សរបស់រដ្ឋាភិបាលទោះបីអង្គការបានចំណាយប្រាក់បន្ថែមក៏ដោយ ។[195]

ដូចឆ្នាំមុនៗដែរ មានណ្ឌលស្តារកាយនីតិសម្បទាចំនួន ១១ កន្លែង និងរោងជាងកែច្នៃអវៈយវៈគ្របដណ្តប់ទាំង ២៤ ខេត្ត-ក្រុង។ ប៉ុន្តែប្រតិបត្តិករបានកត់សំគាល់ថាចំនួនមណ្ឌលនិងរោងជាងទាំងនោះនឹងធ្លាក់ចុះបន្ទាប់ពីឆ្នាំ ២០១១ ដោយយោលទៅតាមកត្តាធ្លាក់ចុះនូវការប្តេជ្ញាចិត្តរបស់អ្នកផ្តល់ជំនួយ ។ ប្រតិបត្តិករប្រមាណថា ក្រសួងសង្គមកិច្ច អតីត យុទ្ធជន និង យុវនីតិសម្បទា (MoSVY) នឹងពុំមានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីគ្រប់គ្រងមណ្ឌលទាំងនោះក្រោយឆ្នាំ ២០១១ ហើយតម្រូវឱ្យមានជំនួយពីអន្តរជាតិជាបន្តទៀត ។[196] មានតែអង្គការជនពិការអន្តរជាតិប៊ែលហ្ស៊ិក (HI-B) ទេ ដែលគេមើលឃើញថានឹងចាកចេញនៅអំឡុងឆ្នាំ២០១១ ហើយអង្គការជនពិការអន្តរជាតិបារាំង(HI-F)បានប្រគល់មណ្ឌលស្តារខួរឆ្អឹងខ្នង( Spinal Cord Injury Centre) ទៅអោយក្រសួងសង្គមកិច្ច អតីត យុទ្ធជន និង យុវនីតិសម្បទា (MoSVY) គ្រប់គ្រងនៅក្នុងខែធ្នូ ឆ្នាំ២០០៨។ ទោះជាយ៉ាងណាក៏ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MoSVY) ទើបបានចាប់ផ្តើមដាក់ហិរញ្ញវត្ថុរបស់ខ្លួនក្នុងខែមេសាឆ្នាំ២០០៩តែប៉ុណ្ណោះ[197] ដែលជាឧបសគ្គដល់កិច្ចប្រតិបត្តិការរបស់មណ្ឌល ។[198] ប្រតិបត្តិករ

---

192 Email from Krisztina Huszti Orban, Legal Attaché, Arms Unit, Legal Division, ICRC, 7 September 2009.

193 "The 3-Year Physical Rehabilitation Working Project (Review of responsibilities to be completed in 2008)," Phnom Penh, 26 March 2009.

194 Interviews with VI, Phnom Penh, 6 April 2009; HI-B, Siem Reap, 8 April 2009; HI-B, Phnom Penh, 10 April 2009; and UNICEF, Phnom Penh, 7 April 2009.

195 Interview with Yann Drouet, ICRC, Phnom Penh, 7 April 2009.

196 Interviews with VI, Phnom Penh, 6 April 2009; HI-B, Siem Reap, 8 April 2009; HI-B, Phnom Penh, 10 April 2009; ARC, Phnom Penh, 6 April 2009; and UNICEF, Phnom Penh, 7 April 2009.

197 Email from Marie-Pierre Guicherd, HI-F, 4 September 2009.

198 Interview with Ung Sambath, Program Officer, DAC, Phnom Penh, 10 April 2009.

ទាំងនោះក៏បានកត់សំគាល់ផងដែរថាមានការយកចិត្តទុកដាក់លើសលុបទៅលើមណ្ឌលដែលនៅជិតទីក្រុងភ្នំពេញ[199]ជាង ហើយការធ្វើអោយប្រសើរអាចធ្វើទៅបានតាមការចុះដល់សហគមន៍និងការបញ្ជូន ។[200]

សេវាស្តារតាមសហគមន៍ក្រោមការអនុវត្តន៍របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MoSVY) និងមានការគាំទ្រហិរញ្ញវត្ថុនិងបច្ចេកទេសពីអង្គការ UNICEF បានពង្រីកទៅដល់១៩ខេត្តក្រុងក្នុងឆ្នាំ២០០៩។ អង្គការ UNICEF ក៏កំពុងបញ្ចប់គោលការណ៍ណែនាំសំរាប់អង្គការស្តារតាមសហគមន៍ផងដែរ ។[201] សេវាស្តារកាយនីតិសម្បទា ក៏បានពង្រីកសេវារបស់ខ្លួនដើម្បីដាក់បញ្ចូលសកម្មភាពស្តារតាមសហគមន៍រួមមាន ដូចជាជួសជុលឧបករណ៍ជួយជនពិការបានភ្លាមៗ តាមដាននិងបញ្ជូននិងការថែទាំនៅតាមផ្ទះ ។[202]



មកដល់ឆ្នាំ ២០០៨ ពុំទាន់មានយន្តការជាតិដើម្បីផ្តល់សេវាពិគ្រោះជំងឺផ្លូវចិត្ត ឬ ប្រព័ន្ធចិត្តសាស្ត្រឡើយ ។ តាមរយៈ ក្រសួងសុខាភិបាលផ្នែកសុខភាពផ្លូវចិត្ត ឬក៏មន្ទីរពេទ្យពិគ្រោះយោបល់ផ្លូវចិត្ត សេវាមួយចំនួនដែលបានផ្តល់ជូននៅមានកម្រិត ប៉ុន្តែអង្គភាពទាំងនោះពុំដំណើរការទៅបានល្អឡើយ ។ មានតែមធ្យោបាយមួយគត់គឺ ការផ្តល់វគ្គបណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលផ្នែកបញ្ហាផ្លូវចិត្តមូលដ្ឋាន ។ បន្ទាប់ពីពិនិត្យការអនុវត្តន៍សារឡើងវិញរបស់សាខាខេត្តនិងស្រុកនៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MoSVY) ការបណ្តុះបណ្តាលត្រូវបានគេគិតថាមានសារៈសំខាន់ដើម្បីបង្កើតគោលនយោបាយទ្រទ្រង់ផ្នែកចិត្តសង្គម ។ អង្គការក្រៅរដ្ឋាភិបាលបានកំពុងផ្តល់សេវាគាំពារផ្នែកចិត្តសង្គម ហើយសកម្មភាពទាំងនោះបានពង្រីកតាមរយៈបណ្តាញសហគមន៍ស្តារនីតិសម្បទា និងការវិវឌ្ឍន៍ក្រុមជួយខ្លួនឯង ។[203] ចំនួនក្រុមជួយខ្លួនឯងជាច្រើនក្រុម បានដំណើរការរីកចំរើន ហើយកំពុងផ្តល់សេវាអប់រំផ្នែកចិត្តសង្គមឱ្យគ្នាទៅវិញទៅមក បង្កើតផលប្រយោជន៍សេដ្ឋកិច្ច និងការយល់ដឹងពីចិត្តសង្គម ។ ក្រុមជួយខ្លួនឯងភាគច្រើនទទួលបានការគាំពារដោយអង្គការមិនមែនរដ្ឋាភិបាល ប៉ុន្តែការងារនេះពុំបានសម្របសម្រួលឱ្យមានប្រសិទ្ធិភាពទេ ហើយមានកង្វះខាតការផ្លាស់ប្តូរបទពិសោធន៍រវាងពីគ្នា ។[204]

---

[199] Interviews with VI, Phnom Penh, 6 April 2009; HI-B, Siem Reap, 8 April 2009; and ICRC, Phnom Penh, 7 April 2009.
[200] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 19.
[201] Interview with Plong Chhaya, UNICEF, Phnom Penh, 7 April 2009.
[202] Email from Krisztina Huszti Orban, ICRC, 7 September 2009.
[203] Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, p. 22; and see *Landmine Monitor Report 2008*, p. 220.
[204] Interviews with UNICEF, Phnom Penh, 7 April 2009; VI; Phnom Penh, 6 April 2009; DDSP, Pursat, 5 April 2009; and with survivors in Pursat, 5 April 2009, and Kampong Thom, 9 April 2009.

ជនពិការមួយចំនួនតូចបានទទួលការអប់រំ ហើយអ្នកដែលរស់ជីវិតពីគ្រាប់មីនជាច្រើនមិនមានលទ្ធភាពផ្គត់ផ្គង់ដល់ដល់សិក្សាអប់រំកូនៗរបស់ពួកគេឡើយ។ កិច្ចខិតខំប្រឹងប្រែងត្រូវបានគេធ្វើឡើងឱ្យបានប្រសើរ តាមរយៈក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា (MoSVY)។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈគឺជាអ្នកទទួលខុសត្រូវមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ប៉ុន្តែសេវាសំរាប់ជនពិការនៅមណ្ឌលនេះត្រូវការពង្រឹងបន្ថែមទៀត។ ការបណ្តុះបណ្តាលវិជ្ជាជីវៈនិងការធ្វើសមាហរណកម្មសេដ្ឋកិច្ចជាថ្មីសំរាប់អ្នករស់រានមានជីវិតពីគ្រាប់មីន គឺភាគច្រើនផ្តល់ជូនដោយអង្គការក្រៅរដ្ឋាភិបាល ប៉ុន្តែអត្រាជោគជ័យនៃការទទួលបានការងារធ្វើនៅមានកម្រិតទាប។[205] ប្រទេសកម្ពុជាបានកត់សំគាល់នៅក្នុងរបាយការណ៍មាត្រាទី៧សម្រាប់ឆ្នាំ២០០៨ របស់ខ្លួនថា "គំរោងការធ្វើសមាហរណកម្មសេដ្ឋកិច្ចឡើងវិញត្រូវបានពន្យាពេលឬបញ្ចប់ដោយសារការខ្វះខាតមូលនិធិ។"[206]

ថ្ងៃទី ០៣ ខែកក្កដា ឆ្នាំ ២០០៩ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាបានឡាយព្រះហស្ថលេខា លើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ។[207] ពង្រាងច្បាប់លើកដំបូងបានធ្វើឡើងក្នុងឆ្នាំ២០០០ ហើយពង្រាងច្បាប់នេះបានធ្វើឡើងម្តងទៀតក្នុងឆ្នាំ២០០៤ និង បានបញ្ជូនទៅកាន់រាជរដ្ឋាភិបាលក្នុងឆ្នាំ២០០៦។[208] គ្រប់ស្ថាប័នពាក់ព័ន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាបានលើកឡើងថា វាជាការសំខាន់ដែលមានច្បាប់សំរាប់ការពារនិងលើកកម្ពស់សិទ្ធិជនពិការដើម្បីជាជំនួយដល់អ្នកដែលមានជីវិតរស់ពីគ្រាប់មីនឱ្យបានកាន់តែប្រសើរឡើង និងការអនុវត្តន៍កិច្ចការពិការភាព។ អង្គការជនពិការកម្ពុជា (CDPO) បានសាទរចំពោះច្បាប់នេះថ្វីបើនៅមានចំនុចខ្វះតម្រូវឱ្យធ្វើវិសោធនកម្មដើម្បីឱ្យស្របទៅតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនពិការក៏ដោយ។[209] ប្រទេសកម្ពុជាបាន ចុះហត្ថលេខាលើអនុសញ្ញានេះនិងពិធីសារបន្ថែមនៃអនុសញ្ញានេះ នៅថ្ងៃទី ០១ ខែតុលា ឆ្នាំ២០០៧ ប៉ុន្តែពុំទាន់ផ្តល់សច្ចាប័ននៅឡើយគិតមកដល់ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០០៩នេះ។ ការរើសអើងក្នុងសង្គមនិងអាជីពការងារនៅតែជាកត្តា គួរអោយពិចារណា។[210] អាគារជាច្រើននៅតែពុំផ្តល់ភាពងាយស្រួលចេញ-ចូលដល់ជនពិការនៅឡើយ។[211]

---

[205] Statement by Thong Vinal, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 26 May 2009; and Kingdom of Cambodia, "National Plan of Action for Persons with Disabilities, including Landmine/ERW Survivors 2009–2011," Phnom Penh, February 2009, pp 25–26, 31.

[206] Article 7 Report (for calendar year 2008), Form J. Co-Chairs of the Standing Committee on Victim Assistance and Socio-Economic Reintegration (Cambodia and New Zealand), "Status of Victim Assistance in the Context of the AP Mine Ban Convention in the 26 Relevant States Parties 2005–2008," Geneva, 28 November 2008, pp. 10–11.

[207] Email from Thong Vinal, DAC, 8 July 2009.

[208] See *Landmine Monitor Report 2008*, p. 221; and *Landmine Monitor Report 2006*, p. 272.

[209] Interview with Ngin Saorath, CDPO, Phnom Penh, 7 April 2009.

[210] US Department of State, "2008 Country Reports on Human Rights Practices: Cambodia," Washington, DC, 25 February 2009.

[211] Statement by Thong Vinal, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 26 May 2009.

**ដំណើរការប្រព្រឹត្តទៅនៃការបំពេញតាមគោលដៅជំនួយដល់អ្នករងគ្រោះថ្នាក់មីនក្នុងចំណោមរដ្ឋទាំង២៦**

ប្រទេសកម្ពុជាជាប្រទេសមួយក្នុងចំណោមរដ្ឋទាំង២៦ ដែលមានតួរលេខដ៏ច្បាស់លាស់ស្តីអំពីអ្នកមានជីវិតពីគ្រាប់មីនច្បាស់លាស់ ហើយនិង "មានសកម្មភាពទទួលខុសត្រូវខ្ពស់បំផុត ប៉ុន្តែវាក៏មានតំរូវការនិងក្តីរំពឹងទុកច្រើនបំផុតសំរាប់ការជួយ" ផ្តល់សេវាថែទាំអោយបានគ្រប់គ្រាន់ និងការស្តារនីតិសម្បទានិងសមាហរណកម្មអ្នកមានជីវិតរស់ពីគ្រាប់មីនទៅក្នុងសង្គម ។[212] ជាផ្នែកមួយនៃការប្តេជាចិត្តទៅនឹងផែនការសកម្មភាពក្រុងណៃរ៉ូប៊ី (Nairobi Action Plan ) ប្រទេសកម្ពុជាបានបង្ហាញគោលដៅរបស់ខ្លួនក្នុងឆ្នាំ២០០៥[213] ដែលភាគច្រើនគោលដៅទាំងនេះមិនមានលក្ខណៈឆ្លាត (SMART) (ចំ៧ specific, អាចវាស់វែងបាន measurable, អាចសម្រេចបាន achievable, សមហេតុផល relevant, ពេលវេលាជាក់លាក់ time-bound) ។[214] នៅចុងឆ្នាំ២០០៨ គេបានកែប្រែឡើងវិញនូវគោលដៅនិងផែនការ ដើម្បីសម្រេចលើគោលដៅដែលបានដាក់ចេញនៅក្នុងទំរង់នៃផែនការជាតិសំរាប់ជនពិការ រួមបញ្ចូលទាំងអ្នករស់រានជីវិតពីមីនឆ្នាំ២០០៩-២០១១ ។[215]

ដូចផែនការជាតិជួយជនរងគ្រោះថ្នាក់មីនឆ្នាំ២០០៩-២០១១ ដែលទើបតែបានបញ្ចប់នៅដើមឆ្នាំ២០០៩ ប្រតិបត្តិករមួយចំនួនដែលបានចូលរួមប្រឹក្សាពុំទាន់ទទួលបានផែនការចុងក្រោយនេះនៅឡើយ ។[216] មានអ្នកមួយចំនួនទៀតយល់ឃើញថាវាឆាប់រហ័សពេកក្នុងការផ្តល់អនុសាសន៍ចំពោះការអនុវត្តន៍របស់ច្បាប់នេះ។ ទោះជាយ៉ាងណា គេក៏បានសំគាល់ឃើញថាសកម្មភាពរបស់ពួកគេសមស្របជាមួយនឹងផែនការនេះ ។[217] មានអ្នកខ្លះបានកត់សំគាល់ថាផែនការអនុវត្តបន្តគឺត្រូវការជាចាំបាច់ ហើយការអនុវត្តន៍គំរោងនោះអាចនឹងមានកំណត់ទៅតាមអ្វីដែលយើងអាចមើលឃើញជាក់ស្តែង ។[218] ឧបសគ្គផ្សេងមួយទៀតដែលអាចនឹងមានគឺការស្វែងរកមូលនិធិសំរាប់អនុវត្តផែនការ ។[219]

នៅពេលយើងមើលទៅគោលដៅពីឆ្នាំ២០០៥-២០០៩ មានដំណើរការរីកចំរើនមិនដូចគ្នាទេ:

- ការប្រមូលទិន្នន័យ : សកម្មភាពរបស់ CMVIS បានបន្តទូទាំងប្រទេស ប៉ុន្តែគេពុំបានធ្វើការអង្កេតលើជំនួយដែលអ្នកដែលរស់ពីគ្រាប់មីនបានទទួលឡើយ ។
- ការសង្គ្រោះបន្ទាន់និងការបន្តផ្តល់ឱសថថែទាំ : ពុំមានរបាយការណ៏វឌ្ឍនភាពជាក់លាក់ពីយុទ្ធសាស្ត្រអភិវឌ្ឍន៏ផ្នែកសុខភាព ឬ ផែនការផ្តល់សេវាសុខភាពដោយមិនគិតថ្លៃដល់អ្នករស់ជីវិតពីគ្រាប់មីន ។

---

[212] UN, "Final Report, First Review Conference," Nairobi, 29 November–3 December 2004, APLC/CONF/2004/5, 9 February 2005, p. 99.
[213] "Final Report of the Sixth Meeting of States Parties/Zagreb Progress Report," Zagreb, 28 November–2 December 2005, APLC/MSP.6/2005/5, 5 April 2006, Part II, Annex V, pp. 122–128.
[214] Statement of Cambodia on Victim Assistance and National Objectives, Ottawa Convention Implementation and Universalization Workshop, Bali, Indonesia, 25–27 February 2008.
[215] Statement of Cambodia, Ninth Meeting of States Parties, Geneva, 27 November 2008.
[216] Interview with Pheng Samnang, Director, DDSP, Pursat, 5 April 2009.
[217] Interviews with DDSP, Pursat, 5 April 2009; HI-B, Phnom Penh, 10 April 2009; AAR, Phnom Penh, 6 April 2009; and Rudi Kohnert, then Country Representative, Austcare, Phnom Penh, 6 April 2009; and email from Meas Vicheth, OEC, 10 July 2009.
[218] Interviews with UNICEF, Phnom Penh, 7 April 2009; DAC, Phnom Penh, 10 April 2009; and CMAA, Phnom Penh, 6 April 2009.
[219] Interview with Teresa Carney, ARC, Phnom Penh, 6 April 2009.

- ការស្តារកាយនីតិសម្បទា ៖ សេវាកម្មទាំងនេះបានដំណើរការបានគ្រប់គ្រាន់ ប៉ុន្តែនិរន្តរភាពជាតិរយៈពេលវែងនៅតែចោទជាសំនួរ (សូមមើលខាងលើ)។
- ការទ្រទ្រង់ផ្នែកចិត្តសង្គមនិងសមាហរណកម្មសង្គមឡើងវិញ ៖ គ្មានផែនការនិងគោលការណ៍ណែនាំសម្រាប់ទ្រទ្រង់ផ្នែកចិត្តសង្គមបង្កើតឡើងទេ។
- សមាហរណកម្មសេដ្ឋកិច្ច ៖ ក្រុមជួយខ្លួនឯងត្រូវបានបង្កើតឡើង ប៉ុន្តែការរកចំណូល, ការងារនិងឱកាសការសិក្សាមិនមានការកើនឡើង។
- ច្បាប់និងគោលនយោបាយសាធារណៈ ៖ ពង្រាងច្បាប់ស្តីពីពិការភាពត្រូវបានអនុម័ត ហើយផែនការសកម្មភាពជួយសង្គ្រោះជនពិការដោយសារមីនត្រូវបានបង្កើតឡើង ក៏ប៉ុន្តែច្បាប់ផ្សេងៗមិនស្ថិតនៅក្រោមការកែប្រែហើយការយល់ដឹងអំពីពិការភាពនៅមានកំរិត។

នៅឯកិច្ចប្រជុំគណៈកម្មាការអចិន្ត្រៃយ៍ក្នុងខែឧសភាឆ្នាំ២០០៩ ប្រទេសកម្ពុជាបានបង្ហាញពីភាពរីកចំរើនលើការបង្កើតគណៈកម្មការសម្របសម្រួលជាតិជនពិការ (National Disability Coordination Committee: NDCC) ការជ្រើសរើសទីប្រឹក្សាផ្នែកពិការភាព, អនុស្សារណៈយោគយល់រវាង CMAA និង CMVIS ហើយនឹងដំណើរការតាក់តែងច្បាប់។ ផលវិបាកប្រឈមក៏ត្រូវបានលើកឡើងផងដែរ ប៉ុន្តែពុំមានការពិភាក្សាពីការអនុវត្តន៍នោះទេ។[220]

នៅក្នុងកិច្ចប្រជុំរដ្ឋសមាជិកនាខែវិច្ឆិកា ឆ្នាំ២០០៧ ប្រទេសកម្ពុជាមានតួនាទីជាសហប្រធានរបស់គណៈកម្មាការអចិន្ត្រៃយ៍ស្តីពីជំនួយជនរងគ្រោះថ្នាក់មីននិងការធ្វើសមាហរណកម្មសេដ្ឋកិច្ចសង្គមឡើងវិញ។ ប្រទេសកម្ពុជាបានបញ្ចូលអ្នកជំនាញខាងជួយជនរងគ្រោះថ្នាក់មីន/ពិការភាព ទៅក្នុងគណៈប្រតិភូរបស់ខ្លួន នាកិច្ចប្រជុំរដ្ឋសមាជិកពីឆ្នាំ២០០៦ ដល់ ២០០៨ ហើយនៅឯកិច្ចប្រជុំរបស់គណៈកម្មាការអចិន្ត្រៃយ៍ ក្នុងឆ្នាំ២០០៥ ឆ្នាំ២០០៧ ឆ្នាំ២០០៨ និងឆ្នាំ២០០៩។ ក្នុងកិច្ចប្រជុំនេះគេក៏បានរាយការណ៍ពីរបាយការណ៍មាត្រា៧ ប្រចាំឆ្នាំផងដែរ និងនៅក្នុងកិច្ចប្រជុំរៀងរាល់ឆ្នាំចាប់ពីឆ្នាំ២០០៥ដល់២០០៩។[221]

***សកម្មភាពជួយដល់អ្នករស់មានជីវិតពីគ្រាប់មីន***

អង្គការជាច្រើនធ្វើការយ៉ាងសកម្មក្នុងផ្នែកកិច្ចការជនពិការ/ជំនួយដល់ជនរងគ្រោះដោយសារមីន។ មានតែអង្គការទាំងនោះទេដែលបានផ្តល់ព័ត៌មានថ្មីៗសំរាប់ឆ្នាំ២០០៨ដែលមានរាប់បញ្ចូលក្នុងតារាងខាងក្រោម។ សំរាប់ព័ត៌មានលំអិតបន្ថែមស្តីពីសកម្មភាពអង្គការនេះ និងអង្គការដទៃទៀត មានលើកឡើងក្នុងរបាយការណ៍ត្រួតពិនិត្យមីនពីឆ្នាំមុនៗ ហើយចំពោះតារាងឈ្មោះអាចរកបាននៅក្រុមប្រឹក្សាសកម្មភាពជនពិការ។[222]

---

[220] Statement by Thong Vinal, DAC, Standing Committee on Victim Assistance and Socio-Economic Reintegration, Geneva, 26 May 2009.

[221] Co-Chairs of the Standing Committee on Victim Assistance and Socio-Economic Reintegration (Cambodia and New Zealand), "Status of Victim Assistance in the Context of the AP Mine Ban Convention in the 26 Relevant States Parties 2005–2008," Geneva, 28 November 2008, pp. 10–11. A VA expert also participated at the Bangkok Workshop on Achieving a Mine-Free South East Asia.

[222] See *Landmine Monitor Report 2008*, p. 224.

សកម្មភាពជួយដល់ជនរងគ្រោះដោយសារមីន ឆ្នាំ ២០០៨[223]

| ស្ថាប័ន | ប្រភេទស្ថាប័ន | សកម្មភាព | ចំនួនជនរងគ្រោះដែលបានជួយ |
|---|---|---|---|
| កាកបាទក្រហមអូស្ត្រាលី | អង្គការមិនមែនរដ្ឋាភិបាល | គាំទ្រដៃគូរមានកាកបាតក្រហមកម្ពុជា ប្រព័ន្ធព័តិមានជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា និង មូលនិធិជំនួយជនរងគ្រោះថ្នាក់មីន (មូលនិធិខ្នាតតូច) | សូមមើលដៃគូ កាកបាទក្រហមកម្ពុជា និង ប្រព័ន្ធព័តិមានជនរងគ្រោះដោយសារមីន និងគ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា |
| អង្គការ Association for Aid and Relief (AAR) | អង្គការមិនមែនរដ្ឋាភិបាល | បណ្តុះបណ្តាលវិជ្ជាជីវៈ | ៦៤៩ នាក់ជាជនពិការ (២៨៩ អ្នកមានជីវិតរស់ពីមីន) ជីវភាពរស់នៅកើនឡើង ៧០% |
| អង្គការAustcare | អង្គការមិនមែនរដ្ឋាភិបាល | បញ្ជូនបន្ត, សមាហរណកម្មសេដ្ឋកិច្ច ក្រុមជួយខ្លួនឯង(ជាមួយអង្គការ CDPO) ការយល់ដឹង | ៣៣៨ នាក់ជាអ្នកមានជីវិតរស់ពីមីន (២១៥នាក់ រកប្រាក់ចំនួល និង ១២៣ នាក់ បញ្ជូនបន្ត) សរុបចំនួនទទួលផល ៣៨៥ នាក់ |
| អង្គការCambodia Trust (CT) | អង្គការមិនមែនរដ្ឋាភិបាល | ស្តារនីតិសម្បទា, បណ្តុះបណ្តាល និងសមាហរណកម្មសេដ្ឋកិច្ចឡើងវិញ | ឧបករណ៍ចល័តសម្រាប់អ្នកមានជីវិតរស់ ចំនួន ៦២៥ នាក់ ស្តារនីតិសម្បទាៈ ១៩៩០ នាក់ បង្កើតប្រាក់ចំនួល ១៨៥ នាក់ បណ្តុះបណ្តាលវិជ្ជាជីវៈ ១៤៩ នាក់ ជួយផ្នែកអប់រំ ៣៦៥ នាក់ (អ្នកនៅមានជីវិតរស់ពី សង្គ្រាមទាំងអស់) សរុបអ្នកទទួលផលៈ ៦៤៣២ នាក់ |
| អង្គការបេសកកម្មអភិវឌ្ឍន៍ | អង្គការមិនមែន | ស្តារនីតិសម្បទានៅតាមសហគមន៍ | អ្នកមានជីវិតរស់ ៤៨ នាក់ |

[223] Email from Teresa Carney, ARC, 3 July 2009; ICRC, "Physical Rehabilitation Programme: Annual Report 2008," Geneva, 7 May 2009, pp. 36–37; information provided by email from Plong Chhaya, UNICEF, 13 July 2009; interview with Josefina McAndrew, VI, Phnom Penh, 6 April 2009; MoSVY-DAC, "Physical Rehabilitation Statistics 2008," VI, July 2009; interview with Sok Sophorn, HI-B, Siem Reap, 8 April 2009; annual rehabilitation statistics for 2008 provided by Sok Sophorn, 8 April 2009; email from Prum Sovann, Rehabilitation Programme Manager, CT, Phnom Penh, 13 July 2009; email from Meas Vicheth, OEC, 10 July 2009; interview with David Aston, Founder, CWARS, Phnom Penh, 5 April 2009; email from Mao Kong, Assistant Managing Director, CWARS, 14 July 2009; email from Ket Chanto, WVC, Phnom Penh, 14 July 2009; information provided by sectors of Jesuit Service and received by email from Denise Coghlan, Country Director, Jesuit Service, Phnom Penh, 25 April 2009; interview with and email from Huoy Socheat, AAR, Phnom Penh, 6 April and 8 July 2009; interview with and email from Pheng Samnang, DDSP, Pursat, 5 April and 8 July 2009; email from Theap Bunthourn, Provincial Coordinator (Oddar Meanchey), Austcare, 2 July 2009; email from Dara Chan, Community-based Rehabilitation Coordinator; CDMD, 9 July 2009; interview with and email from Ngin Saorath, CDPO, Phnom Penh, 7 April and 13 July 2009; email from Stan Brabant, Head of Policy Unit, HI-B, 8 September 2009; and email from Marie-Pierre Guicherd, HI-F, 4 September 2009.

| | | | |
|---|---|---|---|
| ជនពិការកម្ពុជា | រដ្ឋាភិបាល | | សរុបអ្នកទទួលផលៈ ៩៩៤៨ នាក់ |
| អង្គការ Cambodian War Amputees Rehabilitation Society | អង្គការមិនមែនរដ្ឋាភិបាល | សមាហរណកម្មសេដ្ឋកិច្ច | ការបណ្តុះបណ្តាលវិជ្ជាជីវៈសម្រាប់អ្នកមានជីវិតរស់ ៧១៦ និងឥណទានដល់មនុស្ស ១០១ នាក់ សរុបអ្នកទទួលផលៈ ៩៩១ នាក់ |
| អង្គការ Capacity Building of People with Disabilities in Community Orgs. | អង្គការមិនមែនរដ្ឋាភិបាល | ការបញ្ជូនបន្ត, លើកកំពស់ការយល់ដឹង និងការគាំទ្រផ្នែកសេដ្ឋកិច្ច | |
| អង្គការជនពិការកម្ពុជា | អង្គការជនពិការ | សម្របសម្រួលថ្នាក់ជាតិ | គោលនយោបាយ និងអ្នកតំណាងជាជនពិការទូទាំងប្រទេសនិងក្នុង ២០ ខេត្ត តាមរយៈតំណាងក្រុមជួយខ្លួនឯងចំនួន៣៤ សមាជិក ៩៦០៣ នាក់ (អ្នកមានជីវិតរស់ពីគ្រាប់មីនចំនួន ១២៦៧ នាក់) |
| ប្រព័ន្ធព័ត៌មានជនរងគ្រោះដោយសារមីន និង គ្រាប់មិនទាន់ផ្ទុះនៅកម្ពុជា | ស្ថាប័នជាតិ | ការបញ្ជូនបន្ត ជំនួយសម្ភារៈ មធ្យោបាយធ្វើដំណើរ ថ្លៃសុខាភិបាល និងការយល់ដឹងពីពិការភាព | អ្នករស់រានជីវិតពីគ្រាប់មីនចំនួន ២១ នាក់ ទទួលបានថ្លៃធ្វើដំណើរ ឬតំហែទាំសុខភាព, ផ្ទះ៩ខ្នងបានជួសជុល បញ្ជូនបន្តមាន៨០នាក់ ផ្តល់ម្ហូបអាហារសង្គ្រោះបន្ទាន់មាន ៤១ និងការយល់ដឹងអំពីមីន ៤១២ |
| កាកបាទក្រហមកម្ពុជា | ស្ថាប័នជាតិ | ឥណទានមីក្រូហិរញ្ញវត្ថុ និង ជំនួយសម្ភារៈ | អ្នកទទួលផលឥណទាន ១០០នាក់, បង្គន់ និងធុងចំរោះទឹក ៨០ និងធុងទឹក ៦០ |
| អង្គការសេវាកម្មអភិវឌ្ឍន៍ជនពិការខេត្ត ពោធិសត់ | អង្គការមិនមែនរដ្ឋាភិបាល | ក្រុមជួយខ្លួនឯង, សមាហរណកម្មសេដ្ឋកិច្ច, បញ្ជូនបន្ត, ស្តានីតិសម្បទាតាមសហគមន៍ | សេវាកម្មផ្សេងៗ សម្រាប់អ្នករស់រានជីវិតពីគ្រាប់មីនចំនួន ៩៨នាក់, (ការស្តានីតិសម្បទានៅតាមសហគមន៍២០, សមាហរណកម្មសង្គម៩៨នាក់, សកម្មភាពរកប្រាក់ចំណូល៣២នាក់) សរុបអ្នកទទួលផលមាន ចំនួន១០១៥នាក់ |
| អង្គការ Economic and Social Relaunch of Northwest Provinces in Cambodia | អង្គការមិនមែនរដ្ឋាភិបាល | ការបណ្តុះបណ្តាលកសិកម្ម | អ្នករស់រានជីវិតពីគ្រាប់មីនចំនួន៣១ នាក់ សរុបអ្នកទទួលផល (មិនដឹង) |
| អង្គការ Emergency | អង្គការមិនមែនរដ្ឋាភិបាល | ការថែទាំវេជ្ជសាស្ត្រ | អ្នករស់រានជីវិតពីគ្រាប់មីនចំនួន៩៥ នាក់ សរុបអ្នកទទួលផល (មិនដឹង) |

| | | | |
|---|---|---|---|
| អង្គការ HI-B | អង្គការមិនមែនរដ្ឋាភិបាល | ស្តារនីតិសម្បទា, ការគាំទ្រដៃគូ ស្តារនីតិសម្បទាតាមសហគមន៍ | ឧបករណ៍ចល័តដែលបានផលិត ១២៦៣ ជួសជុល ២៤៨៤ (៥៥% សម្រាប់អ្នករស់រានជីវិតពីគ្រាប់មីន នៅខេត្តសៀមរាប) អ្នករស់រានជីវិតពីគ្រាប់មីនចំនួន៧១ នាក់ រួមទាំងក្រុមជួយខ្លួនឯង។ អ្នកទទួលផលសរុប: ៥០៣៧ នាក់ |
| អង្គការ HI-F | អង្គការមិនមែនរដ្ឋាភិបាល | ស្តារនីតិសម្បទា, គម្រោង ចិញ្ចឹមជីវិត | អ្នករស់រានជីវិតពីគ្រាប់មីនចំនួន៤៣៦នាក់ បានទទួលសេវានៅមជ្ឈមណ្ឌលស្តារនីតិសម្បទា (អវៈយវៈសិប្បនិម្មិត ១៧០) អ្នករស់រានជីវិតពីគ្រាប់មីន ចំនួន ២៥៤ នាក់ ជាផ្នែកមួយនៃគម្រោងជីវភាព |
| កាកបាទក្រហមកម្ពុជា | អង្គការអន្តរជាតិ | ស្តារនីតិសម្បទា | អវៈយវៈសិប្បនិម្មិតចំនួន ១៦៧៥ (៨៦%ជាអ្នករស់រានជីវិតពីគ្រាប់មីន) គ្រឿងរណបចំនួន ១៣៩៤ (២,៥% ជាអ្នករស់រានជីវិតពីគ្រាប់មីន) អ្នកទទួលផលសរុប: ១០២០១ នាក់ |
| អង្គការ Jesuit Service Cambodia | អង្គការមិនមែនរដ្ឋាភិបាល | សមាហរណកម្មសេដ្ឋកិច្ច, ស្តារនីតិសម្បទា, គាំទ្រមិត្តជួយមិត្ត លើកកំពស់ការយល់ដឹង, ជំនួយសម្ភារៈ, និងសេវាបញ្ជូនបន្ត | ជនពិការ ១០ នាក់ ទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ, ៩០២ ក្រុមមួយនិងមួយ, ៨៥ នាក់ទទួលបានការអប់រំ/ការស្នាក់នៅ, ១០១២ នាក់ ទទួលរទេះជនពិការ, ៦៣រទេះកង់បី, បញ្ជូនបន្ត ១៥១២ នាក់ សរុបអ្នកទទួលផលៈ មិនដឹង ។ |
| មជ្ឈមណ្ឌលជាតិជនពិការ | អង្គការមិនមែនរដ្ឋាភិបាល | ការបញ្ជូនបន្ត, ការអប់រំ, ការលើកកំពស់ការយល់ដឹង, ក្រុមជួយខ្លួនឯង | លើកកំពស់ការយល់ដឹងៈ ១៨៣២ នាក់ និងគាំទ្រក្រុមជួយខ្លួនឯង ៣០ ក្រុម។ |
| អង្គការ Opération Enfants du Cambodge | អង្គការមិនមែនរដ្ឋាភិបាល | ស្តារនីតិសម្បទាតាមផ្ទះ,ផ្តល់ការអប់រំ និង សមាហរណកម្មសេដ្ឋកិច្ច | អ្នករស់រានជីវិតពីគ្រាប់មីន ៨២៥ នាក់ ទទួលបានសេវាកម្មចំរុះ និង កុមារ ១៥៧១ នាក់បានជួយសង្គ្រោះ សរុបៈ ២៩២៦ នាក់ |
| អង្គការ Veterans International | អង្គការមិនមែនរដ្ឋាភិបាល | ស្តារនីតិសម្បទា, ក្រុមជួយខ្លួនឯង សមាហរណកម្មសេដ្ឋកិច្ច | ឧបករណ៍ចល័តចំនួន៣៦៨៦ រួមទាំងការជួសជុលចំនួន ១៩៦០ (៤៥% សម្រាប់ |

| | | | |
|---|---|---|---|
| | | | អ្នករស់រានជីវិតពីគ្រាប់មីន) សរុប: ៥៨៧០នាក់ |
| អង្គការទស្សនៈពិភពលោក កម្ពុជា | អង្គការមិនមែន រដ្ឋាភិបាល | ក្រុមជួយខ្លួនឯង | ជនពិការ ១០៥ នាក់ សរុប: ១០៥៩ គ្រួសារ |

### ការគាំទ្រសកម្មភាពមីន

របាយការណ៍ត្រួតពិនិត្យមីនមិនបានដឹងទូលំទូលាយអំពីចំនួនថវិកាប៉ាន់ប្រមាណសម្រាប់ផ្នែកដោះមីនទេ ដោយរួមទាំងថវិកាការអប់រំពីគ្រោះថ្នាក់មីន, ជួយអ្នករងគ្រោះថ្នាក់មីននៅក្នុងប្រទេសកម្ពុជា។ គេបានកែប្រែសំណើរសុំពន្យាពេលដោះមីនតាមមាត្រាទី៥នៃសន្ធិសញ្ញា ហើយប៉ាន់ស្មានថា ការដោះមីនឹងត្រូវចាយអស់ថវិកាចំនួន ៣២៩លានដុល្លា ក្នុងទំហំដីមានគ្រាប់មីនចំនួន ៤៧០ គ.ម² គិតរហូតដល់ឆ្នាំ២០១៩ ដែលនឹងកើនពីចំនួន ២២លានដុល្លានាឆ្នាំ២០១០ ទៅ២៨,៧លានដុល្លានាឆ្នាំ២០១៤, ៣៥,២លានដុល្លា នាឆ្នាំ២០១៧ និង ៤០,៣លានដុល្លានាឆ្នាំ២០១៩។ តម្លៃសរុបក្នុងការចំណាយដោះមីនលើផ្ទៃដីទំហំ ៦៤៨,៨ គ.ម² នៃដីដែលនៅមានការគំរាមកំហែងពីគ្រាប់មីន ត្រូវបានគេដាក់ថាអស់ចំនួន ៤៥៥លានដុល្លា។[២២៤] ដោយសារតែការពន្យាពេលនិងសភាពនៃគ្រោះថ្នាក់មីននៅកម្ពុជា នៅតែត្រូវបានគេកំណត់, តំលៃប៉ាន់ស្មានរំពឹងថានឹងផ្លាស់ប្តូរខណៈដែលលទ្ធផលនៃការស្រាវជ្រាវមូលដ្ឋានឈានដល់ការបញ្ចប់។ សំណើរសុំពន្យាពេលដោះមីនមិនបានរាប់បញ្ចូលលំអិតពីយុទ្ធសាស្រ្តចលនភាពធនធានឬផែនការទេ។

### ថវិកាជាតិគាំទ្រសកម្មភាពមីន

នៅក្នុងរបាយការណ៏របស់អនុសញ្ញាហាមប្រើអាវុធ (CCW) មាត្រាទី១៣ ដែលកម្ពុជាបានដាក់ជូនអង្គការសហប្រជាតិក្នុងខែមេសាឆ្នាំ២០០៨នេះ ប្រទេសកម្ពុជាបានរាយការណ៍ពីការផ្តល់មូលនិធិជាតិក្នុងសកម្មភាពដោះមីនចំនួន ១,៥៩០,០០០ដុល្លាអារមេរិកនាឆ្នាំ២០០៧ ដែលចំនួននេះមានដូចគ្នានឹងចំនួនដែលបានរាយការណ៏នៅឆ្នាំ២០០៦។[225] កម្ពុជាបានកែប្រែសំណើរសុំពន្យាពេល ដោះមីនម្តងទៀតតាមមាត្រាទី៥ឱ្យដឹងថា ថវិកាបដិភាគរបស់ជាតិបានកើនឡើង ដែលពីដំបូងមាន ២០០,០០០ដុល្លាអាមេរិក នាឆ្នាំ២០០៣ រហូតដល់ ៣,៥លានដុល្លាអាមេរិកក្នុងឆ្នាំ ២០០៩ ហើយចំណាយសរុបជិត ១១ លានដុល្លាអាមេរិកពីឆ្នាំ ២០០៣ ដល់ឆ្នាំ២០០៩។ សំណើរសុំនោះបន្ថែមថា មូលនិធិអន្តរជាតិ "នឹងបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការទ្រទ្រង់សកម្មភាពដោះមីន។"[226]

### កិច្ចសហប្រតិបត្តិការ និងជំនួយអន្តរជាតិ

ឆ្នាំ២០០៨ មាន១៤ប្រទេសបានរាយការណ៏ថាបានផ្តល់ជំនួយ ២៨,០៧២,៣០៤ដុល្លា (€19,063,088) មកដល់សកម្មភាពដោះមីនក្នុងព្រះរាជាណាចក្រកម្ពុជា ដែលតិចជាងឆ្នាំ២០០៧ចំនួន៨%។ ខណៈវិសាលភាពនៃផ្ទៃដីរងគ្រោះថ្នាក់មីននិងចំនួនអ្នករស់មានជីវិតពីគ្រាប់មីនមិនត្រូវបានគេដឹងចំនួនពិតប្រាកដនោះ ក៏រីតនៃការផ្តល់មូលនិធិក្នុងឆ្នាំ២០០៨ ដែលបានរួម

---

[224] Article 5 deadline Extension request (Revision), 24 August 2009, p. 55.
[225] CCW Article 13 Report, Form E, submitted 2 April 2008.
[226] Article 5 deadline Extension Request (Revision), 24 August 2009, pp. 38, 56.

បញ្ចូលនូវមូលនិធិជាតិនិងអន្តរជាតិ មិនបានគ្រប់គ្រាន់នឹងតម្រូវការសំរាប់ឆ្នាំ២០១០-២០១៩ ដែលបានដកស្រង់ក្នុងសំណើរសុំពន្យាពេលដោះមីនរបស់ប្រទេសកម្ពុជាតាមមាត្រាទី៥ ឬ លើកឡើងពីនិរន្តភាពសមស្របសំខាន់ៗនៃតម្រូវការរបស់ជនរងគ្រោះនៃប្រទេសនេះបានឡើយ ។

ជំនួយអន្តរជាតិសម្រាប់សកម្មភាពមីននៅកម្ពុជាឆ្នាំ២០០៨ (ជាសាច់ប្រាក់) [227]

| ម្ចាស់ជំនួយ | ភ្នាក់ងា/ស្ថាប័នអនុវត្ត | សេចក្តីលំអិតពីគំរោង | បរិមាណ |
|---|---|---|---|
| ប្រទេសអូស្ត្រាលី | ភ្នាក់ងារ UNDP,<br>អង្គការ Austcare,<br>អង្គការអ្នកស្ម័គ្រចិត្តអន្តរជាតិអូស្ត្រាលី,<br>កាកបាទក្រហមអូស្ត្រាលី,<br>អង្គការទស្សនះពិភពលោក<br>ភ្នាក់ងារអភិវឌ្ឍន៍នារីអន្តរជាតិ | ការដោះមីន<br>ការកសាងសមត្ថភាព<br>សកម្មភាពមីនរួមបញ្ចូល<br>និងជំនួយដល់ជនរងគ្រោះ<br>ដោយសារមីន | ៦,១៦៣,៨៦២ដុល្លាអាមេរិក<br>(A$7,220,173) |
| ប្រទេសជប៉ុន | អង្គការ CMAC,<br>អង្គការ HALO,<br>អង្គការJapan Mine Action Service | ការដោះមីន<br>ក្រុមកំទេចគ្រឿងផ្ទុះ(EOD)<br>ការកសាងសមត្ថភាព | ៥,៩៣៦,៩៥៦ ដុល្លាអាមេរិក |
| សហរដ្ឋ អាមេរិច | អង្គការ CMAC/CMAA,<br>អង្គការHALO, អង្គការMAG,<br>អង្គការGolden West,<br>អង្គការNPA,<br>អង្គការSpirit of Soccer | ការដោះមីន/ មីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម,<br>ការកសាងសមត្ថភាព<br>ការអប់រំពីគ្រោះថ្នាក់មីន<br>ជំនួយដល់ជនរងគ្រោះ | ៤,១១៧,000ដុល្លាអាមេរិក |

[227] Emails from Kathleen Bombell, Mine Action Unit, AUSAID, 21 July 2009; and Hayashi Akihito, Japan Campaign to Ban Landmines (JCBL), 4 June 2009, with translated information received by JCBL from the Humanitarian Assistance Division, Multilateral Cooperation Department, and Conventional Arms Division, Non-proliferation; US Department of State, "To Walk the Earth in Safety 2009," Washington, DC, July 2009; emails from Amy White, Deputy Program Manager, DfID, 17 March 2009; Kim Henrie-Lafontaine, Second Secretary, Foreign Affairs and International Trade, Canada, 6 June 2009 and 19 June 2009; and Sirpa Loikkanen, Secretary, Ministry of Foreign Affairs, 27 February 2009; Germany Article 7 Report, Form J, 27 April 2009; Spain Article 7 Report, Form J, 30 April 2009; emails from David Keating, Disarmament and Non-Proliferation, Department of Foreign Affairs, 12 March 2009; and Daniel Gengler, Ministry of Foreign Affairs, 5 March 2009; Belgium Article 7 Report, Form J, 30 April 2009; and emails from Dimitri Fenger, Humanitarian Aid Section, Ministry of Foreign Affairs, 8 June 2009; Ingunn Vatne, Senior Advisor, Ministry of Foreign Affairs, 4 June 2009; and Stacy Davis, Public Engagement, Office of Weapons Removal and Abatement, US Department of State, 2 September 2009.

| | | | |
|---|---|---|---|
| | | បច្ចេកវិទ្យាទំនើប ( HSTAMIDS & explosive harvesting ) | |
| ចក្រភពអង់គ្លេស | អង្គកាMAG, អង្គកាHALO | ការដោះមីន | ៣,៥១០,៣៥៩ដុល្លាអាមេរិក (£1,892,887) |
| ប្រទេសកាណាដា | អង្គការ Geospatial International, អង្គការUNDP | ការដោះមីន ការអភិវឌ្ឍន៍កសិកម្មក្នុងតំបន់មានមីន | ២,៧០២,២៤០ដុល្លាអាមេរិក (C$2,880,546) |
| ប្រទេស ហ្វាំងឡង់ | អង្គការFinnChurchAid, អង្គការHALO, អង្គការHI | ការដោះមីន ជំនួយដល់ជនរងគ្រោះដោយសារមីន | ១,៥៦៨,៣១៩ដុល្លាអាមេរិក (€1,065,000) |
| ប្រទេសអាឡឺម៉ង់ | អង្គការ CMAC | ការដោះមីន | ១,១៩៧,២៨៣ដុល្លាអាមេរិក (€813,040) |
| ប្រទេស អេស្បាញ | អង្គការUNDP | ការដោះមីន | ១,១០៤,៤៥០ ដុល្លាអាមេរិក (€750,000) |
| ប្រទេស អៀរឡង់ | អង្គការHALO | ការដោះមីន | ៧៣៦,៣០០ ដុល្លាអាមេរិក (€500,000) |
| ប្រទេស ហូឡង់ | អង្គការNPA | មិនបញ្ជាក់ច្បាស់ | ៥១៥,៤១០ ដុល្លាអាមេរិក (€350,000) |
| ប្រទេស បែលហ្សិក | អង្គការHI | ជំនួយដល់ជនរងគ្រោះដោយសារមីន | ២៩៤,៥២០ ដុល្លាអាមេរិក (€200,000) |
| ប្រទេស លុចហ្សំបួរ | អង្គការHI | ជំនួយដល់ជនរងគ្រោះដោយសារមីន | ១៥៤,៦០៥ ដុល្លាអាមេរិក (€104,988) |
| ប្រទេស ន័រវេ | មិនបញ្ជាក់ច្បាស់ | បរិកញ្ញមីន កម្ពុជា | ៧០,៩៦០ ដុល្លាអាមេរិក (NOK400,000) |
| សរុប | | | ២៨,០៧២,៣០៤ ដុល្លាអាមេរិក (€19,063,088) |

បន្ថែមទៅលើថវិកាខាងលើ ប្រទេសញូវែលហ្សេឡង់ បានរាយការណ៍ថាផ្តល់ជំនួយទៅដល់ការអភិវឌ្ឍន៍សមត្ថភាពតាមរយៈមជ្ឈមណ្ឌលបណ្តុះបណ្តាលស៊ីម៉ាក់ ក្នុងឆ្នាំ ២០០៨ ប៉ុន្តែមិនបានផ្តល់ចំនួនតួរលេខនៃថវិកាវិភាគទាននេះឡើយ។[228] អង្គការជនពិការអន្តរជាតិបារាំង(HI-F) បានរាយការណ៍ពីការផ្តល់មូលនិធិដើម្បីជួយទ្រទ្រង់កម្មវិធីជួយជនរងគ្រោះពីគណៈ

[228] Article 7 Report (for calendar year 2008), Form J.

កម្មការអ៊ឺរ៉ុប (EC) ($439,589) និងពីប្រទេសបារាំង ($64,412)ក្នុងឆ្នាំ ២០០៨។[229] ទាំងប្រទេសបារាំង ឬក៏គណៈកម្មាការអ៊ឺរ៉ុបទាំងពីរមិនបានរាយការណ៍ពីចំនួនផ្តល់មូលនិធិរបស់ខ្លួនអោយកម្ពុជាក្នុងឆ្នាំ២០០៨ឡើយ។

នៅខែមិនា ឆ្នាំ២០០៩ ប្រទេសជប៉ុនបានរាយការណ៍ថា បានផ្តល់មូលនិធិថ្មីចំនួន 548 លានយ៉េន (ប្រហែល 5.5លានដុល្លា) ដើម្បីទ្រទ្រង់ក្នុងការទិញឧបករណ៍បោសសំអាតមីនក្នុងប្រទេសកម្ពុជា។ ការផ្តល់មូលនិធិឈានដល់ជំហ៊ាន ទី៥ ក្នុងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលជប៉ុននិងអង្គការស៊ីម៉ាក់ ហើយឧបករណ៍ទាំងនោះរួមមាន ឧបករណ៍រាវរកមីន/គ្រាប់មិនទាន់ផ្ទុះ និងគ្រឿងបន្លាស់ផ្សេងៗទៀត។[230]

### ***ការគាំទ្រជាអន្តរជាតិរបស់កម្ពុជាក្នុងសកម្មភាពមីន***

កម្ពុជាបានបញ្ជូនក្រុមទាហានដោះមីនចំនួន៣ក្រុម ទៅចូលរួមប្រតិបត្តិការរក្សាសន្តិភាពអង្គការសហប្រជាជាតិ នៅប្រទេស ស៊ូដង់ ចាប់ពីឆ្នាំ២០០៦ (សូមមើលផ្នែកដោះមីនខាងលើ)។[231] នៅខែមិថុនា ឆ្នាំ២០០៩ ក្រុមទាហានដោះមីន១ក្រុម មានគ្នា៥២នាក់ បានបញ្ជូនទៅប្រទេសស៊ូដង់ដើម្បីជំនួសក្រុមដែលបានបញ្ជូនទៅមុនៗ។[232] ប្រទេសកម្ពុជាទទួលជំនួយមូលនិធិចំណាយពីនាយកដ្ឋានប្រតិបត្តិការរក្សាសន្តិសន្តិភាពនៃអង្គការសហប្រជាជាតិ (DPKO) (ឯករាជ្យភាពរបស់ម្ចាស់ជំនួយដែលបានមកពីសកម្មភាពដោះមីន)ដើម្បីជំនួសរាល់ចំណាយលើសកម្មភាពដោះមីនរបស់ខ្លួនក្នុងប្រទេសស៊ូដង់។[233] ប្រទេសកម្ពុជាទទួលជំនួយមូលនិធិចំណាយពីនាយកដ្ឋានប្រតិបត្តិការរក្សាសន្តិសន្តិភាពអង្គការសហប្រជាជាតិ (UN DPKO) (ឯករាជ្យភាពរបស់ម្ចាស់ជំនួយដែលបានមកពីសកម្មភាពដោះមីន) ដើម្បីជំនួសរាល់ចំណាយលើសកម្មភាពដោះមីនរបស់ខ្លួនក្នុងប្រទេសស៊ូដង់។[234] ប្រទេសកម្ពុជាមិនបានឱ្យដឹងពីចំនួនថវិកាដែលបានចូលរួមវិភាគទានក្នុងកម្មវិធីនេះនាឆ្នាំ ២០០៨ ឬ ២០០៩ទេ។

---

[229] Email from Marie-Pierre Guicherd, HI France, 4 September 2009.

[230] "Exchange of Notes for Japan's ODA Loan and Grant Aid," 18 March 2009, Japan Embassy in Cambodia, www.kh.emb-japan.go.jp.

[231] "2nd batch of Cambodian deminers return from UN peacekeeping missions in Sudan," *Xinhua* (Phnom Penh), 10 June 2008, news.xinhuanet.com.

[232] "52 Cambodian soldiers join demining operations in Sudan," *Sudan Tribune* (Phnom Penh), 10 June 2009, www.sudantribune.com.

[233] Email from Pascal Rapillard, GICHD, 4 September 2009.

[234] Ibid.